**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiqes

Royal Unitersity of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អគ្គការអយ្យការ

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក.ជា សៀកម៉ី**

**ក. ថុន សុវណ្ណដាលីន**

សាស្ត្រាចារ្យណែនាំ

**ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំទាំងពីររូប ជានិស្សិតកម្រិតឆ្នាំទី៤ ផ្នែកនីតិសាស្ត្រ ឆ្នាំសិក្សា ២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

លោកឪពុក និងអ្នកម្តាយ ដែលបានលះបង់ទាំងកម្លាំងកាយចិត្ត ញើសស្រស់ ឈាមស្រស់ក្នុងការចិញ្ចឹមបីចាច់ថែរក្សា លើកទឹកចិត្ត និងផ្គត់ផ្គង់ដល់ការរៀនសូត្រដល់រូបយើងខ្ញុំទាំងពីររូបជារៀងរហូតមកដោយគ្មានឡើយនូវពាក្យត្អូញត្អែរ ។

សាកលវិទ្យាធិការ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់យ៉ាងពេញទំហឹងទៅលើដំណើរការប្រព័ន្ធអប់រំនៅក្នុងសាកលវិទ្យាល័យ អោយប្រព្រឹត្តទៅបានយ៉ាងប្រសើរជាទីបំផុត ។

លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ទាំងអស់នៃសាកលវិទ្យល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេសលោកសាស្ត្រចារ្យ ជួន ប៊ុនធី ដែលជានិច្ចជាកាលតែងតែលះបង់នៅកម្លាំងកាយចិត្ត នៅក្នុងការបណ្តុះបណ្តាលផ្ទេរនៅចំណេះដឹង នឹងព្រមទាំងបានចែករំលែកនៅបទពិសោធន៍យ៉ាងមានតម្លៃបំផុតដល់និស្សិតគ្រប់ជំនាន់ ក៏ដូចជាយើងខ្ញុំទាំងពីររូបផងដែរ ។

ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ ចំពោះលោកឪពុក អ្នកម្តាយ និងលោកអ្នកមានគុណទាំងអស់ដែលបានបង្ហាត់បង្រៀន និងតម្រង់ទិសដល់ពួកយើង ឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ ។

# អារម្ភកថា

ជាការចាប់ផ្តើមយើងខ្ញុំ ឈ្មោះជា សៀកម៉ី និងថុន សុវណ្ណដាលីន ជានិស្សិតផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចជំនាន់ទី ២២(ម្ភៃពីរ) ។ យើងខ្ញុំបានឆ្លងកាត់ការសិក្សា និងទទួលបានការបណ្តុះបណ្តាលលើជំនាញនីតិសាស្ត្រ អស់រយៈពេល ៤(បួន)ឆ្នាំ មកហើយ។ ការសិក្សារយៈពេល បួនឆ្នាំនេះ យើងខ្ញុំបានឆ្លងកាត់នូវបទពិសោធជាច្រើនដែលបទពិសោធន៍ ទាំងនេះជាចំណែកមួយក្នុងការធ្វើយើងខ្ញុំបានអភិវឌ្ឍខ្លួនកាន់តែប្រសើរឡើងរហូតឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

សារណានេះ គឺជាផ្នែកមួយនៃការពិពណ៌នា "**អគ្គការអយ្យការ**" នៃប្រទេសកម្ពុជាដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែង នៅក្នុងដំណើរការនៃនីតិវិធីរបស់ស្ថាប័នអយ្យការដែលកើតឡើង នាពេលបច្ចុប្បន្ននេះ ។ ទាំងអស់នេះហើយ គឺជាសមិទ្ធផលដែលកើតពីការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវ និងរៀបចំចងក្រងឡើងតាមបែបវិទ្យាសាស្ត្រ ដោយផ្អែកលើមូលដ្ឋានគតិយុត្តិហើយក៏ត្រូវបានដកស្រង់ពីអត្ថបទច្បាប់នានា ដែលបានជាប់ពាក់ព័ន្ធក្នុងគោលបំណងដើម្បីលើកស្ទួយដល់ការអភិវឌ្ឍផ្នែកច្បាប់ក៏ដូចជាចែករំលែកចំណេះដឹងផ្នែកច្បាប់ផងដែរ ។

នាងខ្ញុំទាំងពីរ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយលើកទឹកចិត្ត និងបង្ហាត់បង្រៀនក៏ដូចជាពន្យល់ណែនាំយ៉ាងយកចិត្តទុកដាក់ ជាការជំរុញដល់រូបយើងខ្ញុំទាំងពីរ ។

យ៉ាងណាមិញ ការស្រាវជ្រាវលើប្រធានបទមួយនេះ គឺពិតជានៅមានចំណុចខ្វះខាត ទាំងពាក្យពេចន៍ និងអត្ថន័យខ្លឹមសារ អាស្រ័យហេតុនេះ សូម លោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិតព្រមទាំងមិត្តអ្នកអានទាំងអស់ សូមមេត្តាខន្តីអភ័យទោសដល់ការខ្វះខាតរបស់នាងខ្ញុំទាំងពីរផង ។ នាងខ្ញុំទាំងពីរ មានសេចក្តីត្រេកអរយ៉ាងក្រៃលែង ក្នុងការទទួលយកនូវការរិះគន់ន័យស្ថាបនាពីសំណាក់ លោក លោកស្រី សាស្ត្រចារ្យ សិស្សនិស្សិត ព្រមទាំងប្រិយមិត្តអ្នកអានទាំងអស់ ។ ជាចុងក្រោយ នាងខ្ញុំទាំងពីរ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ ដែលមាននៅក្នុងលោកនេះ សូមជួយតាមថែរក្សាលោកឪពុកម្តាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាស្ត្រាចារ្យ និងមិត្តភក្តិរួមជំនាន់ទាំងអស់ឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈព្រមទាំងទទួលបាននូវសុខសុភមង្គល និងទទួលបានជោគជ័យគ្រប់ភារកិច្ច ។

## មាតិកា

ទំព័រ

**សេចក្តីផ្តើម**...........................................................................................................១
១. លំនាំបញ្ហានៃការស្រាវជ្រាវ..........................................................................................១
២.ចំណោទបញ្ហានៃការដោះស្រាយ....................................................................................១
៣.គោលបំណង និងសារៈសំខាន់សម្រាប់ការស្រាវជ្រាវ.........................................................២
៤.វិធីសាស្ត្រនៃការស្រាវជ្រាវ.............................................................................................២
៥.កម្រិតនៃការស្រាវជ្រាវ..................................................................................................២
៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ..........................................................................................២

**ជំពូកទី១**

**ប្រវត្តិ និងការរៀបចំនៃអង្គការអយ្យការ**

**ផ្នែកទី១៖ ប្រវត្តិនៃអង្គការអយ្យការកម្ពុជា**.......................................................................៣
**កថាខណ្ឌទី១៖ ការបង្កើតអង្គការអយ្យការនៅកម្ពុជា**..........................................................៣
១. ពីឆ្នាំ១៩៣៧ មកដល់ ១៩៧០.......................................................................................៣
២. ការជ្រើសតាំងនិងការតែងតាំងរដ្ឋអាជ្ញា-អគ្គរដ្ឋអាជ្ញា........................................................៤
៣. អំណាចនិងតួនាទីរបស់អយ្យការ-មហាអយ្យការអម.............................................................៥
**កថាខណ្ឌទី២៖ ឯករាជ្យភាពនៃអង្គការអយ្យការ**.................................................................៥
១. ឯករាជ្យចំពោះមុខតុលាការ...........................................................................................៥
២. ឯករាជ្យក្នុងការបំពេញមុខងារ.......................................................................................៥
**ផ្នែកទី២៖ ការរៀបចំនៃអង្គការអយ្យការ**.........................................................................៥
**កថាខណ្ឌទី១៖ ឋានានុក្រមនៃអង្គការអយ្យការ**..................................................................៦
១. អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត...................................................................៦
២. អង្គការមហាអយ្យការអមសាលាឧទ្ធរណ៍...........................................................................៦
៣.អង្គការមហាអយ្យការអមតុលាការកំពូល...........................................................................៧
**កថាខណ្ឌទី២៖ ទំនាក់ទំនងរវាងអយ្យការ នឹងលេខាធិការដ្ឋានរដ្ឋបាល**....................................៧
១. លេខាធិការដ្ឋានរដ្ឋបាលជានរណា ?...............................................................................៧
២. ឋានានុក្រមនៃលេខាធិការដ្ឋានរដ្ឋបាល............................................................................៨
៣. តួនាទី និងភារៈកិច្ចរបស់លេខាធិការដ្ឋានរដ្ឋបាល.................................................................៨

**ជំពូកទី២**

**អំពី អង្គការអយ្យការ**

**ផ្នែកទី១៖ តំណាងអយ្យការ**...........................................................................................៩
**កថាខណ្ឌទី១៖ ការចូលបម្រើការជាតំណាងអយ្យការ**............................................................៩

១. គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ ..................... ៩
២. ការជ្រើសរើសតំណាងអយ្យការឬព្រះរាជអាជ្ញា និងក្រឡាបញ្ជី..................... ១០
៣. ការធ្វើកម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ..................... ១១
៤. ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ..................... ១២
៥. ការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញា ..................... ១២
**កថាខណ្ឌទី២៖ ភារកិច្ច និងការទទួលខុសត្រូវក្នុងនាមជាតំណាងអយ្យការ**... ១៤
១. ភារកិច្ចតំណាងអយ្យការ ..................... ១៤
២. ទណ្ឌកម្មវិន័យ..................... ១៤
៣.ការចោទប្រកាន់តាមផ្លូវតុលាការ..................... ១៥
៤.ការចូលនិវត្តន៍..................... ១៦
**ផ្នែកទី២៖ មុខការនៃអង្គការអយ្យការ** ..................... ១៧
**កថាខណ្ឌទី១៖ អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត** ..................... ១៧
១. អំណាច ..................... ១៧
២. សមត្ថកិច្ចតាមដែនដី..................... ១៧
**កថាខណ្ឌទី២៖ អង្គការអយ្យការអមតុលាការជាន់ខ្ពស់** ..................... ១៧
១.អង្គការមហាអយ្យការអមសាលាឧទ្ធរណ៍ ..................... ១៨
២.អង្គការមហាអយ្យការអមតុលាការកំពូល..................... ១៩
**ផ្នែកទី៣៖ ការអនុវត្តបណ្តឹងអាជ្ញា** ..................... ១៩
**កថាខណ្ឌទី១៖ បណ្តឹងអាជ្ញា** ..................... ១៩
១. តើអ្វីទៅជាបណ្តឹងអាជ្ញា?..................... ១៩
២. ការរំលត់នៃបណ្តឹងអាជ្ញា ..................... ២០
**កថាខណ្ឌទី២៖ បណ្តឹងរដ្ឋប្បវេណីក្នុងបទល្មើសព្រហ្មទណ្ឌ** ..................... ២០
១. បណ្តឹងរដ្ឋប្បវេណី..................... ២១
២. ដើមបណ្តឹងរដ្ឋប្បវេណី ..................... ២១
៣.ការចូលរួមរបស់អយ្យការក្នុងរឿងក្តីរដ្ឋប្បវេណី..................... ២២
**ជំពូកទី៣**
**ការចោទប្រកាន់ និងមិនចោទប្រកាន់របស់តំណាងអយ្យការ**
**ផ្នែកទី១៖ ការមិនចោទប្រកាន់របស់តំណាងអយ្យការ** ..................... ២៣
**កថាខណ្ឌទី១៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ**..................... ២៣
១. នត្ថិភាពនៃបទល្មើស..................... ២៤
២. មូលហេតុគតិយុត្តិ ..................... ២៥

៣. ការចោទប្រកាន់ដែលមិនបានផ្តល់ផលប្រយោជន៍.......................................................................៣១
**កថាខណ្ឌទី២៖ នីតិវិធី ទម្រង់ការ និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ**៣២
១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ.......................................................................៣២
២. ទម្រង់ការនៃការតម្កល់រឿងទុកឥតចាត់ការ.......................................................................៣៣
៣. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ.......................................................................៣៣
**កថាខណ្ឌទី៣៖ យន្តការជំរុញឱ្យមានការចោទប្រកាន់ឡើងវិញ**.......................................................................៣៤
១. ការលើកើកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា.......................................................................៣៤
២. បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍.......................................................................៣៥
៣. អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ.......................................................................៣៦
៤. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ.......................................................................៣៧
**ផ្នែកទី២៖ ការចោទប្រកាន់របស់តំណាងអយ្យការ**.......................................................................៣៨
**កថាខណ្ឌទី១៖ ការបើកការស៊ើបអង្កេត**.......................................................................៣៩
១.លក្ខខណ្ឌដែលនាំឱ្យមានការបើកការស៊ើបសួរ.......................................................................៣៩
២.នីតិវិធីនៃការបញ្ជូនរឿងឱ្យស៊ើបសួរ.......................................................................៤១
៣.ទម្រង់ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ.......................................................................៤២
៤.អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ.......................................................................៤៤
**កថាខណ្ឌទី២៖ ការបញ្ជូនរឿងទៅជំនុំជម្រះ**.......................................................................៤៥
១. លក្ខខណ្ឌបទល្មើស.......................................................................៤៦
២. នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះ.......................................................................៤៧
៣. ទម្រង់ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះ.......................................................................៤៩
៤. អានុភាពនៃការបញ្ជូនរឿងទៅជំនុំជម្រះ.......................................................................៥០
**កថាខណ្ឌទី៣៖ ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម**.......................................................................៥១
១. លក្ខខណ្ឌនៃនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម.......................................................................៥១
២. នីតិវិធីនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម.......................................................................៥២
៣. អានុភាពនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម.......................................................................៥៥

**ជំពូកទី៤**

**អយ្យការក្នុងដំណើរការនៃការអនុវត្តទោស**

**ផ្នែកទី១៖ ការឃុំខ្លួន និងការដោះលែង**.......................................................................៥៦
**កថាខណ្ឌទី១៖ វិធានការទាក់ទងនឹងការឃុំខ្លួន**.......................................................................៥៦
១. ការគ្រប់គ្រងពន្ធនាគា.......................................................................៥៧
២.ការធ្វើអធិការកិច្ចពន្ធធានាគារ.......................................................................៥៨
**កថាខណ្ឌទី២៖ ការដោះលែងដោយមានលក្ខខណ្ឌ**.......................................................................៥៩

១. លក្ខខណ្ឌផ្សេងៗក្នុងការដោះលែងទណ្ឌិត ...... ៥៩
២. សេចក្ដីសម្រេចទាក់ទងនឹងការដោះលែងដោយមានលក្ខខណ្ឌ...... ៦០
**ផ្នែកទី២៖ ការបង្ខំរូបកាយ និងការផ្ដល់នីតិសម្បទាឡើងវិញ** ...... ៦១
**កថាខណ្ឌទី១៖ ករណីអនុវត្តការបង្ខំដល់រូបកាយ** ...... ៦១
១.ថេរវេលានៃការបង្ខំដល់រូបកាយ ...... ៦១
២.ការរួចខ្លួនពីការបង្ខំដល់រូបកាយ ...... ៦២
**កថាខណ្ឌទី២៖ ការផ្ដល់នីតិសម្បទាឡើងវិញ** ...... ៦២
១.ការផ្ដល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ...... ៦៣
២.ការមាននីតិសម្បទឡើងវិញដោយពេញលក្ខខណៈច្បាប់...... ៦៥
**សេចក្ដីសន្និដ្ឋាន និងអនុសាសន៍** ...... ៦៦
**គន្ថនិទេស**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

យើងដឹងហើយថានៅលើពិភពលោក យើងឃើញថាប្រព័ន្ធច្បាប់សម្រាប់រដ្ឋនីមួយៗបានបង្កើតឡើងមានលក្ខណៈខុសពីគ្នា ។ ក្នុងនោះដែលមានប្រព័ន្ធច្បាប់ពីរប្រភេទប៉ុណ្ណោះដែលគេយកមកប្រើ ។ ចំណែកកម្ពុជាយើងវិញបានជ្រើសរើសយកប្រព័ន្ធច្បាប់ Civil law ដើម្បីដឹកនាំប្រទេសដោយសារស្ថិតនៅក្រោមអាណានិគមបារាំងអស់រយៈពេលច្រើនឆ្នាំ ។ ចំពោះការបង្កើតច្បាប់នីតិវិធីព្រហ្មទណ្ឌ គឺយើងត្រូវតែបង្កើតនូវនីតិវិធីមួយដែលសមស្របទៅនឹងប្រព័ន្ធច្បាប់ ដែលយើងបានជ្រើសរើស ។ ដោយសារតែប្រទេសកម្ពុជាបានជួបនឹងសង្គ្រាមធ្វើអោយបាត់បង់អ្នកប្រាជ្ញជាច្រើន រួមទាំងបាត់បង់នូវប្រជាពលរដ្ឋដែលមានចំណេះដឹងជាច្រើនទៀតនោះ ធ្វើអោយប្រព័ន្ធច្បាប់នៅកម្ពុជាជួបផលលំបាក ដូចនេះទើបយើងសម្រចបង្កើតនូវអង្គការអយ្យការឡើងដើម្បីដោះស្រាយជូនភាគីដែលរងគ្រោះក្នុងរឿងក្ដីព្រហ្មទណ្ឌផងដែល ។ ស្ថាប័នអយ្យការ មានសិទ្ធិធ្វើបណ្ដឹងអាជ្ញាហើយអាចចោទប្រកាន់ជនល្មើសបាន តាមរយៈការធ្វើបណ្ដឹងអាជ្ញា ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ អយ្យការមានសិទ្ធិគ្រប់គ្រាន់ដើម្បីស្វែររកភស្តុតាង ក្នុងគោលដៅធានាដល់ការចោទប្រកាន់នៅពេលជំនុំជម្រះ ។ ព្រះរាជអាជ្ញា ឬ ហៅម្យ៉ាងទៀតថា តំណាងអយ្យការ ពិតជាមានតួនាទី និងភារកិច្ចសំខាន់ណាស់នៅក្នុងនីតិវិធីដំណើរការរឿងក្ដីព្រហ្មទណ្ឌ ជាពិសេសគឺការចេញដីកា និងធ្វើការចោទប្រកាន់ផ្សេងៗ ទៅលើជនសង្ស័យណាមួយ ។ សារណានេះនឹងបង្ហាញពីការស្វែងយល់ពី អង្គការអយ្យការ ស្វែងយល់ពីការចោទប្រកាន់ និងមិនចោទប្រកាន់របស់តំណាងអយ្យការ ក៏ដូចជាដំណើរការនីតិវិធីជំនុំជម្រះ និងដំណើរការនៃការអនុវត្តទោស។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ចំពោះការយល់ដឹងពីស្ថាប័នអយ្យការពុំបានទូលំទូលាយនោះទេ មានន័យថាការយល់ដឹងអំពីស្ថាប័ននេះគឺនៅមានកម្រិតនៅឡើយទេ ។ ទើបនាងខ្ញុំ ខំប្រឹងស្រាវជ្រាវអំពីស្ថាប័នអយ្យការ តាមកម្រិត នៃការយល់ដឹងដើម្បីចែករំលែកចំណេះដឹងមួយផ្នែកដល់មិត្តអ្នកអានទាំងឡាយណា ដែលចង់ស្វែងយល់ពីស្ថាប័នអយ្យការ ។ ហើយនាងខ្ញុំសង្ឃឹមថាសារណាមួយនេះនឹងបញ្ជាក់ច្បាស់ពីការអនុវត្ត ការដឹកនាំ ក៏ដូចជាការចូលរួមរបស់ស្ថាប័នអយ្យការក្នុងដំណាក់ការនិវិធីនីមួយៗ ។ ដើម្បីជាគន្លឹះឲ្យកាន់តែយល់ច្បាស់នូវអង្គការអយ្យការ យើងត្រូវដឹងថា

តើអ្វីជាអង្គការអយ្យការ? តើកាតព្វកិច្ច និងមុខងារ អង្គការអយ្យការមានអ្វីខ្លះ? តើអង្គការអយ្យការ ចូលរួមនៅក្នុងកិច្ចនីតិវិធីតុលាការអ្វីខ្លះ?

## ៣.គោលបំណង និងសារៈសំខាន់សម្រាប់ការស្រាវជ្រាវ

### ៣.១.គោលបំណងសម្រាប់ការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវ អំពីស្ថាប័នអយ្យការនេះ មានគោលបំណងស្វែងយល់អំពី ការរៀបចំអង្គការអយ្យការ ការចូលរួមរបស់អយ្យការក្នុងដំណើរនីតិវិធីតុលា និងការអនុវត្តទោស នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ។

## ៣.២.សារៈសំខាន់សម្រាប់ការស្រាវជ្រាវ

ការសិក្សាលើប្រធានបទ អង្គការអយ្យការ បានផ្តល់នូវ ពុទ្ធិដោយផ្ទាល់ដល់និស្សិត ក៏ដូចជាអ្នកស្រាវជ្រាវជំនាន់ក្រោយ ឱ្យកាន់តែយល់ច្បាប់អំពី អង្គការអយ្យការ ដែលដើរតួយ៉ាងសំខាន់ក្នុងវិស័យ យុត្តិធម៌ និងពង្រីកចំណេះដឹង ដើម្បីបំពេញមុខងារក្នុងស្ថាប័នអយ្យការ ។

## ៤.វិធីសាស្ត្រនៃការស្រាវជ្រាវ

- អង្កេតទៅលើរដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ
- អង្កេតទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ
- អនុសាសន៍ផ្ទាល់ពីលោកសាស្ត្រាចារ្យ **ជួន ប៊ុនធី**
- អនុសាសន៍ផ្ទាល់ពីលោកមេធាវី **ឆាន ចិរៈ**
- ការពិភាក្សាជាមួយមិត្តរួមក្រុម
- ការវិភាគ និងសំយោគទៅលើប្រធានបទ

## ៥. ករម្រិតនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ មានដែនកំណត់ដោយផ្តោតទៅលើការសិក្សាដែលទាក់ទងទៅនឹង ស្ថាប័នអយ្យការទាំងឡាយណាដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា សិក្សាអមពីការចូលរួមរបស់ស្ថាប័នអយ្យការ ក្នុងដំណើរការស៊ើបអង្កេត កិច្ចស៊ើបសួរ ការជម្រះក្តី និងការអនុវត្តទោស។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះ ចែកចេញជា ៤(បួន) ជំពូក ។ ជំពូកទី១ លើកឡើងពីប្រវត្តិ និងការរៀបចំអង្គការអយ្យការ ។ ជំពូកទី២ រៀបរាប់អំពី អង្គអយ្យការ មានដូចជា តំណាងអយ្យការ មុខការ និងការអនុវត្តបណ្តឹងអាជ្ញា ។ រីឯជំពូកទី៣ វិញ យើងខ្ញុំសំដៅដល់ ការមិនចោទប្រកាន់ និងមិនចោទប្រកាន របស់តំណាងអយ្យការ ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ និងជំពូកទី៤ សិក្សាពី អយ្យការក្នុងដំណើរការនៃការអនុវត្តទោស ។

# ជំពូកទី១
# ប្រវត្តិនឹងការរៀបចំនៃអង្គការអយ្យការ

## ផ្នែកទី១៖ ប្រវត្តិនៃអង្គការអយ្យការ

អង្គការអយ្យការគឺជាស្ថាប័នមួយរបស់រដ្ឋសំរាប់ដំណើរការបណ្ដឹងសាធារណៈ ឬ បណ្ដឹងព្រហ្មទណ្ឌ ។ អង្គការអយ្យការ គឺជាស្ថាប័នមួយដែលមានព្រះរាជអាជ្ញាធ្វើការដើម្បីឲ្យបានសម្រេចបេសកម្មរបស់អង្គការនេះ ។ តាមន័យសមញ្ញនៃពាក្យ "ព្រះរាជអាជ្ញា" គេអាចយល់ថាបានថា បុគ្គលនេះគឺតំណាងឲ្យព្រះមហាក្សត្រ ដោយខ្លួនបាន " អាជ្ញា" ឬ អំណាចពីព្រះរាជា ។ អង្គការអយ្យការ មិនមែនជាស្ថាប័នដែលទទួលបន្ទុកក្នុងការជម្រះក្ដីដូចតុលាការឡើយ តែអយ្យការគឺជាភាគីនៃរឿងក្ដីព្រហ្មទណ្ឌដែលជាអ្នកតំណាងអោយផលប្រយោជន៍ទូទៅ ដោយមានសិទ្ធិក្នុងការធ្វើបណ្ដឹងអាជ្ញា ។[1]

### កថាខណ្ឌទី១៖ ការបង្កើតអង្គការអយ្យការនៅកម្ពុជា

ដើម្បីងាយស្រួលក្នុងការសិក្សាទៅលើការបង្កើតអង្គការអយ្យការនៅកម្ពុជាយើងនឹងសិក្សាទៅលើចំនុចធំៗចំនួន បី គឺ **(១)**ការបង្កើតពីឆ្នាំ១៩៣៧មកដល់ ១៩៧០ **(២)**ការជ្រើសតាំងនិងការតែងតាំងរដ្ឋអាជ្ញា-អគ្គរដ្ឋអាជ្ញា **(៣)**អំណាចនិងតួនាទីរបស់អយ្យការ-មហាអយ្យការអម ។

#### ១. ការបង្កើតពីឆ្នាំ១៩៣៧មកដល់ ១៩៧០

អង្គការអយ្យការត្រូវបានបង្កើតឡើងដំបូងបង្អស់នៅឆ្នាំ ១៩៣៧ ដោយការបញ្ចូលតំណែងនេះទៅក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ(ភាសាសម័យយើងនេះគេហៅថាក្រមនីតិវិធីព្រហ្មទណ្ឌ ។ មុនឆ្នាំ១៩៣៧ គេហៅថាក្រមលក្ខណពិភាក្សាព្រហ្មទណ្ឌ)។ យោងតាមក្រមនេះ នៅអមសាលាដំបូងនីមួយៗ មានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ហើយនៅអមសាលាជាន់ខ្ពស់មាន "**ព្រះរាជបំរើ**" និង "**ភូឈួយព្រះរាជបំរើ**" ។ ដោយមានការខ្វះខាតថវិកាគេបានជ្រើសយកប្រធានសាលាដំបូងឲ្យដើរតួនាទីពីរគឺ ជាព្រះរាជអជ្ញានៅអមសាលានេះផង និងជា ចៅក្រមជំនុំជំរះផង ។ តួនាទីព្រះរាជាអាជ្ញានេះមកជំនួស តួនាទីរបស់ចៅក្រមស៊ើបសួរសុភាចារបុរស ដែលដើមឡើយជាអ្នកបង្កសំណុំរឿងចោទប្រកាន់ទៅសាលាមជ្ឈឹម (ដែលជាផ្នែកនៃសាលាដំបូង សំរាប់វិនិច្ឆ័យរឿងមជ្ឈឹម ដែលមានទោសពី៥ថ្ងៃ ដល់ ៥ឆ្នាំ) ឬទៅសាលាក្រុមចោទ(ដែលជាសាខាមួយរបស់សាលាឧទ្ធរណ៍ដែលពិនិត្យរឿងឧក្រិដ្ឋនិងរឿងដែលប្ដឹងជំទាស់នឹងដីការបស់សុភាចារបុរស) ។ មន្ត្រីអយ្យការនៅអមសាលាដំបូងមានឈ្មោះថាព្រះរាជអាជ្ញា ចំណែកនៅសាលាឧទ្ធរណ៍ មន្ត្រីនេះមានឈ្មោះថា "ព្រះរាជបំរើ" ។ ចំណែកសាលាវិនិច្ឆ័យាធិគី(សមមូលនឹងតុលាការកំពូលយើងសព្វថ្ងៃ) ពុំមានព្រះរាជអាជ្ញានៅអមទេ។ ប៉ុន្តែក្រោយមកទៀត តំណែងអគ្គព្រះរាជអាជ្ញាអម

[1] កុយ នាម និង ឡុង បញ្ញាវុធ, អង្គការអយ្យការ (ប្រវត្តិ និងការសិក្សាប្រៀបធៀប) បោះពុម្ពលើកទី១ ឆ្នាំ២០០៦, ទំព័រទី៤៥

សាលាវិនិច្ឆ័យត្រូវបានឃើញមាននៅក្នុងច្បាប់ស្តីពីលក្ខន្តិៈស្តីពីយុត្តាធិការ ចៅក្រម និងក្រឡាបញ្ជីខាងផ្នែកតុលាការ ចុះថ្ងៃទី ០៩ មិនា ១៩៥៤ ។ ដូច្នេះ អង្គព្រះរាជអាជ្ញាអមសាលាវិនិច្ឆ័យ យ៉ាងហោចណាស់ មានអត្ថិភាពចាប់តាំងពីឆ្នាំនោះមក ។[2]

**២.ការជ្រើសតាំងនិងការតែងតាំងរដ្ឋអាជ្ញា-អគ្គរដ្ឋអាជ្ញា**

គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុងជាអ្នកជ្រើសរើសរដ្ឋអាជ្ញាអមតុលាការខេត្តក្រុង រួចស្នើសុំការយល់ព្រមពីរដ្ឋមន្រ្តីក្រសួងយុត្តិធម៌។ ក្រោយពីការយល់ព្រមរបស់រដ្ឋមន្រ្តីហើយរដ្ឋអាជ្ញានោះនឹងត្រូវបានតែតាំងដោយក្រុមប្រឹក្សារដ្ឋមន្រ្តី ។ ចំណែករដ្ឋអាជ្ញារងវិញ ការតាក់តែងមានបែបបទខ្លីជាងរដ្ឋអាជ្ញា ។ គណៈកម្មាធិការប្រជាជនខេត្ត-ក្រុងជាអ្នកជ្រើសរួចហើយស្នើរសុំការយល់ព្រមពីរដ្ឋមន្រ្តីក្រសួងយុត្តិម៌ ។ លុះបានការយល់ព្រមហើយរដ្ឋអាជ្ញារងនោះត្រូវបានតែងតាំងដោយគណៈកម្មការនោះតែម្តង (មាត្រា២២ នៃច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការនិងអយ្យការ) ដែលអនុម័តដោយរដ្ឋសភានៃសាធារណប្រជាមានិតកម្ពុជា ថ្ងៃ១០ កុម្ភៈ ១៩៨២ ។ នៅតុលាការថ្នាក់ខេត្ត-ក្រុងនីមួយៗត្រូវមានរដ្ឋអាជ្ញាម្នាក់ និងរដ្ឋអាជ្ញារងម្នាក់ឬពីរនាក់ ។ តុលាការខេត្ត-ក្រុងជាតុលាការតែមួយថ្នាក់ដែលសំរេចសេក្តីជាលើកចុងក្រោយ ។ តុលាការប្រជាជនបានបង្កើតឡើងពិតប្រាកដនៅគ្រប់ខេត្តក្នុងឆ្នាំ១៩៨៣ ។ ការជ្រើសរើសរដ្ឋអាជ្ញាត្រូវធ្វើតាមនីតិវិធិដូចតទៅនេះ ។ ប្រធានមន្ទីរចាត់តាំងខេត្ត-ក្រុងជាអ្នកពិនិត្យមើលប្រវិត្តរូបមន្ត្រីរដ្ឋការនៅក្នុងក្រុងឬខេត្ត ដែលមិនជាប់ពាក់ព័ន្ធជ្រៅនឹងនិន្នាការនយោបាយក្នុងរបបមុនៗ និងជាសមាជិកសកម្មឬក្រុមស្នូលរបស់ប្រជាជនបដិវត្តកម្ពុជា ។ បន្ទាប់មកប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង បញ្ជូនឈ្មោះអ្នកដែលជ្រើសមកក្រសួងយុត្តិធម៌ ។ ចំពោះសម្ថភាពវិញមានការព្យាយាមជ្រើសរើសយកអ្នកមានចំណេះវិជ្ជាខាងច្បាប់ដែរ ប៉ុន្តែដោយសារសម័យនោះអ្នកដែលមានប្រវិត្តអប់រំ វិស័យនេះមិនមាន ការជ្រើសរើសត្រូវផ្តោតទៅលើអ្នកដែលមានចំណេះដឹងទូទៅ ជាពិសេសគ្រូបង្រៀន ។ បន្ទាប់ពីការតែងតាំងមក រដ្ឋអាជ្ញានិងរដ្ឋអាជ្ញារងត្រូវបានបញ្ជូនមកហ្វឹកហ្វឺនពីរវគ្គនៅសាលាកម្មាភិបាលរដ្ឋបាល និងនីតិសាស្រ្ត ។ ឧទាហរណ៍ៈ ក្នុងវិជ្ជាច្បាប់ គេផ្តោតទៅលើបច្ចេកទេសរដ្ឋបាល ការរៀបចំសវនាការ ការសរសេរសាលក្រម របៀបអនុវត្តនីតិវិធីព្រហ្មទណ្ឌ ។[3]

**៣.អំណាចនិងតួនាទីរបស់អយ្យការ-មហាអយ្យការ**

អយ្យការ មានតួនាទីចោទប្រកាន់ លើបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យអនុវត្តច្បាប់ ។ អង្គការ អយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងធានាលើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន ។ ក្នុងការ

[2] កុយ នាម និង ឡុង បញ្ញាវុធ, អង្គការអយ្យការ (ប្រវត្តិ និងការសិក្សាប្រៀបធៀប) បោះពុម្ពលើកទី១ ឆ្នាំ២០០៦, ទំព័រទី៥៤, ៥៥ ។

[3] កុយ នាម និង ឡុង បញ្ញាវុធ, អង្គការអយ្យការ (ប្រវត្តិ និងការសិក្សាប្រៀបធៀប) បោះពុម្ពលើកទី១ ឆ្នាំ២០០៦, ទំព័រទី ៥៨, ៥៩, ៦០ ។

បំពេញភារកិច្ចចៅក្រមអយ្យការ (ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង) មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈ ដោយផ្ទាល់ជាជំនួយ ។ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ចៅក្រមអយ្យការ ត្រូវតែមានវត្តមានក្នុងពេលសវនាការចំពោះរឿងក្តីព្រហ្មទណ្ឌ ។ មហាអយ្យការ ដឹកនាំដោយ អគ្គព្រះរាជអាជ្ញា ហើយមានតួនាទីក្នុងការឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញា នេះក៏អាចធ្វើអធិការកិច្ចនៅអង្គការ អយ្យការអមសាលាដំបូងខេត្ត-រាជធានីទូទាំងប្រទេស ។

**កថាខណ្ឌទី២៖ ឯករាជ្យភាពនៃអង្គការអយ្យការ**

មានទស្សនះពីរ ចំពោះឯករាជ្យភាពនៃអង្គការអយ្យការ ដោយទស្សនះទីមួយយល់ឃើញថា **(១)អយ្យការត្រូវតែមានឯករាជ្យភាពខាងស្ថាប័នផង** និង **(២)ក្នុងការបំពេញមុខងារផង**។

**១. ឯករាជ្យចំពោះមុខតុលាការ**

ឯករាជ្យភាពចំពោះមុខតុលាការមានន័យថា ព្រះរាជអាជ្ញាអមតុលាការណាមួយមិននៅក្រោមអំណាចរបស់តុលាការទេ ។ តុលាការនោះគ្មានអំណាចអ្វីមកត្រួតពិនិត្យកិច្ចការរបស់អយ្យការនៅទីនោះទេ ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការមិនអាចសរសេរិះគន់ ឬ បន្ទោសថាព្រះរាជាធ្វើនេះមិនត្រូវ ដូច្នោះមិនល្អមិនល្អយ៉ាងណានោះទេ ។ តុលាការមិនអាចបង្គាប់បញ្ជាថាឲ្យព្រះរាជអាជ្ញាត្រូវចោទប្រកាន់បទល្មើសនេះ ឬ ចង្អុលថាជននោះត្រូវតែចោទប្រកាន់តាមដែលខ្លួនយល់ឃើញនោះទេ ។ ការធ្វើដូច្នេះជាការបំពានអំណាច តែតុលាការអាចរ៉ាយរ៉ាប់ជាសំងាត់ ពីការមិនសប្បាយចិត្តរបស់ខ្លួនទៅលើរបស់ព្រះរាជអាជ្ញា។

**២. ឯករាជ្យក្នុងការបំពេញមុខងារ**

ដើម្បីយល់ដឹងពីភាពស្មុគស្មាញនៃឯករាជ្យភាពនៃអង្គការអយ្យការខ្មែរ គេគួរតាមដានចរន្តនៃការវិវឌ្ឍន៍ពីតួនាទី និងមុខងាររបស់ស្ថាប័ននេះចាប់តាំងពីការកកើតដំបូងរហូតមកទល់បច្ចុប្បន្ន ព្រោះការអនុវត្តពីអតីតកាលមានឥទ្ធិពលដល់និយាមនាពេលបច្ចុប្បន្ន។[4]

**ផ្នែកទី២៖ ការរៀបចំនៃអង្គការអយ្យការ**

ការរៀបចំនៃអង្គការអយ្យការ ត្រូវបានរៀបចំឡើងដោយមាន **(កថាខណ្ឌទី១) ឋានានុក្រមនៃអង្គការអយ្យការ (កថាខណ្ឌទី២)ទំនាក់ទំនងរវាងអយ្យការ នឹងលេខាធិការដ្ឋានរដ្ឋបាល** ។

**កថាខណ្ឌទី១៖ ឋានានុក្រមនៃអង្គការអយ្យការ**

[4] កុយ នាម និង ឡុង បញ្ញាវុធ, អង្គការអយ្យការ (ប្រវត្តិ និងការសិក្សាប្រៀបធៀប) បោះពុម្ពលើកទី១ ឆ្នាំ២០០៦, ទំព័រទី៨០ ។

ដើម្បីមានភាពងាយស្រួលសិក្សាទៅលើឋានានុក្រមនេះយើងនិងសិក្សាទៅលើអង្គការអយ្យការធំៗចំនួនបី គឺ **(១)អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត (២)អង្គការមហាអយ្យការអមសាលាឧទ្ធរណ៍(៣)អង្គការមហាអយ្យការអមតុលាការកំពូល** ។

### ១. អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

នៅគ្រប់សាលាដំបូងរាជធានី-ខេត្តមានអង្គការអយ្យការមួយគេហៅថា **អង្គការអមសាលាដំបូង** ។ អង្គការអយ្យការអមសាលាដំបូង មានតំណាងអយ្យការដូចជា៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង ។

យោងតាមច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ សមាភាពអយ្យការអមសាលាដំបូង រួមមាន៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអ្នកមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។[5]

### ២. អង្គការមហាអយ្យការអមសាលាឧទ្ធរណ៍

នៅសាលាឧទ្ធរណ៍ គឺមានស្ថាប័នមួយអយ្យការមួយដែលគេហៅថា **មហាអយ្យការអមសាលាឧទ្ធរណ៍** ។ មហាអយ្យការអមសាលាឧទ្ធរណ៍ មានតំណាងអយ្យការដូចជា៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា។

យោងតាមច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ មហាអយ្យការអមសាលាឧទ្ធរណ៍ មានសមាសភាពដូចជា៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី

[5] ច្បាប់ស្តីពីការរៀបចំអង្គការអង្គការតុលាការ នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា២៩ ។

- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាឧទ្ធរណ៍។[6]

**៣.អង្គការមហាអយ្យការអមតុលាការកំពូល**

តុលាការកំពូល មានស្ថាប័នអយ្យការមួយដែលគេហៅថា **មហាអយ្យការអមតុលាការកំពូល** ។ មហាអយ្យការអមតុលាការកំពូល មានតំណាងអយ្យការ ដូចជា៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា។

យោងតាមច្បាប់ ស្តីពីការរៀបចំអង្គការ តុលាការមហាអយ្យការតុលាការកំពូលមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល។[7]

**កថាខណ្ឌទី២៖ ទំនាក់ទំនងរវាងអយ្យការ នឹងលេខាធិការដ្ឋានរដ្ឋបាល**

ទំនាក់ទំនងរវាងអយ្យការ នឹងលេខាធិការដ្ឋានរដ្ឋបាលយើងត្រូវសិក្សាទៅលើបីចំនុចដូចជា **(១)លេខាធិការដ្ឋានរដ្ឋបាលជានរណា ? (២)ឋានានុក្រមនៃលេខាធិការដ្ឋានរដ្ឋបាល (៣)តួនាទី និងភារៈកិច្ចរបស់លេខាធិការដ្ឋានរដ្ឋបាល** ។

**១. លេខាធិការដ្ឋានរដ្ឋបាលជានរណា** ?

លេខាធិការដ្ឋានរដ្ឋបាល គឺជាសេនាធិការឲ្យតុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូល ។[8]

**២. ឋានានុក្រមនៃលេខាធិការដ្ឋានរដ្ឋបាល**

[6] ច្បាប់ស្តីពីការរៀបចំអង្គការអង្គការតុលាការ នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា៤៩ ។

[7] ច្បាប់ស្តីពីការរៀបចំអង្គការអង្គការតុលាការ នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា៦៤ ។

[8] ច្បាប់ស្តីពីការរៀបចំអង្គការអង្គការតុលាការ នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា៧១ ។

- លេខាធិការដ្ឋានរដ្ឋបាល ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ។ អគ្គលេខាធិការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ត្រូវរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន០៧ (ប្រាំពីរ)ឆ្នាំ ។

- អគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និង អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ។ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានត្រូវរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន០៥ (ប្រាំ)ឆ្នាំ។

- មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានថ្នាក់ក្រោមនាយកដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តធម៌ ។ អនុប្រធាននាយកដ្ឋាន ព្រមទាំង ប្រធាន និងអនុប្រធានការិយាល័យ ត្រូវរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន០៣ (បី)ឆ្នាំ ។[៩]

**៣.តួនាទី និងភារៈកិច្ចរបស់លេខាធិការដ្ឋានរដ្ឋបាល**

តួនាទី និងភារៈកិច្ចរបស់លេខាធិការដ្ឋានរដ្ឋបាល មានដូចជា៖

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រងរដ្ឋបាលតុលាការ សម្រាប់ជាជំនួយការបច្ចេកទេសដល់កម្មវិធីការងាររបស់តុលាការ
- ការងារទំនាក់ទំនងសាធារណៈ
- ការងារផ្សេងទៀត ដែលប្រធានតុលាការ និងតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលប្រគល់អោយ
- ការងារបញ្ជូនសាលដីការបស់តុលាការកំពូលជូនទៅក្រសួងយុត្តិធម៌ឲ្យបានទៀងទាត់
- រៀបចំនិងបញ្ជូនរបាយការណ៍ ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ប្រចាំខែ ត្រីមាសឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌។

ក្រោយពីបានបកស្រាយជំពូកទី១ រួចហើយ យើងខ្ញុំនឹងឈានទៅដល់ជំពូកទី២ អំពីអយ្យការ ។ ដែលក្នុងជំពូកទី២ នេះផងដែរ យើងខ្ញុំបានបែងចែកចេញជា ៣ ផ្នែក គឺ៖ **តំណាងអយ្យការ(ផ្នែកទី១) មុខការនៃអង្គការអយ្យការ(ផ្នែកទី២) ការអនុវត្តបណ្តឹងអាជ្ញា(ផ្នែកទី៣) ។**

[៩] ច្បាប់ស្តីពីការរៀបចំអង្គការអង្គការតុលាការ នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៧២ ។

# ជំពូកទី២

# អំពី អង្គការអយ្យការ

## ផ្នែកទី១៖ តំណាងអយ្យការ

តំណាងអយ្យការ គឺជាមន្ត្រីដែលបម្រើការនៅតាមស្ថាប័នអយ្យការនីមួយៗ ដោយតំណាងអយ្យការជាបុគ្គលមានតួនាទីសំខាន់បំផុតនៅក្នុងស្ថាប័នរបស់ខ្លួន។ ដើម្បីឈានទៅដល់ការសិក្សាពីតំណាងអយ្យការ យើងត្រូវដឹងពី **ការចូលបម្រើការជាតំណាងអយ្យការ(កថាខណ្ឌ១) កាតព្វកិច្ចនិងការទទួលខុសត្រូវក្នុងនាមជាតំណាងអយ្យការ(កថាខណ្ឌទី២)** ។

### កថាខណ្ឌទី១៖ ការចូលបម្រើការជាតំណាងអយ្យការ

មុននឹងឈានទៅដល់ការបម្រើការងារ ជាតំណាងអយ្យការព្រះរាជអាជ្ញាត្រូវយល់ដឹងអំពី គោលការណ៍សំខាន់ៗ របស់អង្គការអយ្យការ(១) ការជ្រើសរើសតំណាងអយ្យការ ឬព្រះរាជអាជ្ញានិងក្រឡាបញ្ជី(២) ការធ្វើកម្មសិក្សានិងការតាំងស៊ប់ក្នុងក្របខ័ណ្ឌព្រះរាជអាជ្ញា(៣) ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ(៤) ការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញា(៥) ។

#### ១ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ

គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ រួមមានជាអាទិ៍៖

- ❖ អង្គការអយ្យការជាអង្គឯកភាពដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់ ។ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើកិច្ចការនេះ ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូល ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន ។ ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូងត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន ។

❖ អង្គការអយ្យការ គឺជាអង្គអវិភាគ ដែលតម្រូវឱ្យព្រះរាជអាជ្ញា ត្រូវបំពេញមុខងារនៅអង្គការអយ្យការអមសាលាជម្រះក្តីណាមួយ មានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា នឹងអាចជំនួសគ្នាទៅវិញទៅមកបាន ។ តាមគោលការណ៍នេះ តំណាងអង្គការអយ្យការច្រើនរូប អាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយ តាមការចាត់តាំងរបស់នាយឋានានុក្រម ។

❖ អង្គការអយ្យការ គឺជាអង្គឯករាជ្យ ដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ ។ សាលាជម្រះក្តីនេះ គ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ ។ ទោះបីក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារក៏ដោយ ក៏សាលាជម្រះក្តីមិនត្រូវចុះក្នុងសេចក្តីសម្រេចរបស់ខ្លួន យកការស្តីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ ។ ការហាមឃាត់នេះត្រូវអនុវត្ត ទាំងក្នុងរឿងព្រហ្មទណ្ឌ ទាំងក្នុងរឿងក្តីផ្សេងទៀត ។ ប៉ុន្តែសាលាជម្រះក្តីអាចលើកសំណើទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញា អំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញាបាន។

## ២. ការជ្រើសរើសតំណាងអយ្យការឬព្រះរាជអាជ្ញានិងក្រឡាបញ្ជី

ព្រះរាជអាជ្ញា គឺជាមន្ត្រីដែលស្ថិតនៅក្នុងស្ថាប័នអយ្យការជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌធ្វើការចោទប្រកាន់ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះក្នុងនាមផលប្រយោជន៍សង្គម ។ អង្គការអយ្យការ ធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌរួមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។

### ក.ចំពោះការជ្រើសរើស

សម្រាប់ការជ្រើសរើស និងការបណ្តុះបណ្តាល ព្រះរាជអាជ្ញា ត្រូវអនុវត្តរួមគ្នាជាមួយនឹងការបណ្តុះបណ្តាលចៅក្រម ។ យោងតាមគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា រដ្ឋត្រូវតែធានាថាបុគ្គលដែលត្រូវបានជ្រើសរើសឲ្យធ្វើជាព្រះរាជអាជ្ញា ត្រូវតែជាបុគ្គលដែលមានសុចរិតមានសមត្ថភាព ។

### ខ.ការបណ្តុះបណ្តាល

ដូចគ្នាជាមួយនឹងចៅក្រមដែរ មុននឹងក្លាយជាព្រះរាជអាជ្ញា គឺត្រូវបណ្តុះបណ្តាលបឋមខាងវិជ្ជាជីវៈដែលមានរយៈពេល ២ (ពីរ) ឆ្នាំ នៅសាលាភូមិន្ទចៅក្រម ព្រមទាំងឆ្លងកាត់កម្មសិក្សាដែលត្រូវបានកំណត់។[10]

### គ.ក្រឡាបញ្ជី

ក្រឡាបញ្ជីសំដៅលើឋានន្តរស័ក្តិរបស់មន្ត្រីជាន់កណ្តាលខាងតុលាការជាស្មៀនសម្រាប់កាន់កាប់បញ្ជី និងសំណុំរឿងផ្សេងៗជាដើម។ នៅក្នុងន័យច្បាប់ ក្រឡាបញ្ជី គឺជាលេខាធិការផ្ទាល់របស់ចៅក្រម និងព្រះរាជអាជ្ញាក្នុង

[10] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៨២ ។

ការជួយសម្រួលដល់ការងារបច្ចេកទេសផ្នែកនីតិវិធីរឿងក្តីដែលច្បាប់តម្រូវជាចាំបាច់ត្រូវតែមាន។

- ចំពោះការជ្រើសរើស
  - ក្រឡាបញ្ជីត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែងផ្ទៃក្រៅក្នុងចំណោមនិស្សិតនិងមន្ត្រីរាជការ ។
  - បែបបទលក្ខខណ្ឌនៃការប្រឡងកាលបរិច្ឆេទចំនួនកន្លែង ដែលត្រូវផ្តល់ឲ្យនាសម័យប្រឡងប្រជែងនីមួយៗ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។
  - បេក្ខជន និងក្រឡាបញ្ជី បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល និងបានឆ្លងកាត់ការវាយតម្លៃដោយសាលាភូមិន្ទក្រឡាបញ្ជីនៃរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការនិងអង្គការតុលាការ ឬអយ្យការដែលខ្លួនបានចុះកម្មសិក្សាក្នុងក្របខណ្ឌក្រសួងយុត្តិធម៌ ។

### ៣ ការធ្វើកម្មសិក្សានិងការតាំងស៊ប់ក្នុងក្របខ័ណ្ឌព្រះរាជអាជ្ញា

បន្ទាប់ពីដំណើរការប្រឡងប្រជែងជ្រើសរើស ហើយបានទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈនៅរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ ហើយសិស្សព្រះរាជអាជ្ញាដែលបានបញ្ចប់ការការបណ្តុះបណ្តាល ដោយជោគជ័យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ របស់ព្រះរាជអាជ្ញាកម្មសិក្សាក្នុងឋានន្តរស័ក្តិជា អនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ ។ ព្រះរាជអាជ្ញាកម្មសិក្សាត្រូវធ្វើកម្មសិក្សារយៈពេលមួយឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃការតែងតាំង ។[11] ការធ្វើការសិក្សារបស់ព្រះរាជអាជ្ញារងកម្មសិក្សាត្រូវកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។[12] ចំពោះការតាំងស៊ប់នៅក្នុងក្របខ័ណ្ឌព្រះរាជអាជ្ញាគឺព្រះរាជអាជ្ញា និងមានឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតាំងស៊ប់ ក្នុងក្របខ័ណ្ឌព្រះរាជអាជ្ញានេះតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចឲ្យព្រះរាជអាជ្ញាកម្មសិក្សាបន្តធ្វើកម្មសិក្សា ១ (មួយ) ឆ្នាំ បន្ថែមទៀតកាលបើព្រះរាជអាជ្ញាកម្មសិក្សានោះពុំទទួលបានជោគជ័យក្នុងការធ្វើកម្មសិក្សាឬមានការអាក់ខានមិនបានធ្វើកម្មសិក្សាសរុបទាំងអស់លើសពី៣០ (សាមសិប)ថ្ងៃក្នុងករណីដែល គ្មានការអនុញ្ញាតច្បាប់ឬព្រះរាជអាជ្ញាកម្មសិក្សាដែលមិនបានទទួលជោគជ័យជាថ្មីម្តងទៀតក្នុងការធ្វើកម្មសិក្សាបន្ថែម ត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ។[13]

### ៤. ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ

---

[11] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៨៣ ។

[12] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៨៣ ។

[13] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៨៤ ។

បន្ទាប់ពីព្រះរាជអាជ្ញាបានធ្វើការ បានចុះកម្មសិក្សា តាមរយៈពេលដែលត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ការដំឡើងថ្នាក់និងឋានន្តរស័ក្តិត្រូវធ្វើ តាមវេនជ្រើសរើសនិងតាមវេនអតីតភាព ស្របតាមតារាងនៃថ្នាក់និងឋានន្តរស័ក្តិនីមួយៗ ។ លក្ខខណ្ឌនៃការដំឡើងឋានៈឬឋានន្តរស័ក្តិត្រូវធ្វើតាមវេនជ្រើសរើសនិងតាមអតីតភាពត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។[14] ដើម្បី អាច ចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់បាន ចៅក្រម ឬព្រះរាជអាជ្ញាត្រូវបំពេញកាតព្វកិច្ចចំនួនពីរគឺ៖

ទី១.គាត់ត្រូវបម្រើការងារក្រោយបានទទួលការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ។

ទី២.គាត់ត្រូវស្ថិតក្នុងឋានន្តរស័ក្តិឬថ្នាក់របស់ខ្លួនយ៉ាងតិចពីរឆ្នាំគិតមកទល់ថ្ងៃទី១៣ខែមេសានៃឆ្នាំនីមួយៗ ។ ចំពោះការដំឡើងថ្នាក់និង ឋានន្តរស័ក្តិរបស់ចៅក្រម ត្រូវផ្អែកលើមូលដ្ឋានជាអាទិ៍ដូចជា ៖

- រដ្ឋការគោរពវិន័យការងារបានត្រឹមត្រូវ
- ការសម្រេចភារកិច្ចបានល្អ
- កិរិយាមារយាទនិងសីលធម៌ល្អមិនធ្វើឲ្យប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម
- ឆ្លងកាត់វគ្គបណ្តុះបណ្តាលនានាឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា។[15]

គណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវរៀបចំតារាងទៅតាមជំនាន់ព្រះរាជអាជ្ញា ដែរដំឡើងថ្នាក់និងឋានន្តរស័ក្តិ និងតាមលំដាប់ថ្នាក់ក្នុងតារាងចុះឈ្មោះ ដើម្បីដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យនិងផ្តល់យោបល់ ។ អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវរៀបចំតារាងឈ្មោះ ព្រះរាជអាជ្ញាដែលត្រូវដំឡើងថ្នាក់និងឋានន្តរស័ក្តិទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីរៀបចំសេចក្តីព្រាង ព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ ។

**៥.ការតែងតាំង ការផ្លាស់ប្តូរ ការផ្អាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញា**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រពីការតែងតាំង ការផ្លាស់ប្តូរ ការផ្អាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ហេតុក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានពិគ្រោះយោបល់ជាចាំបាច់ចំពោះសំណើខាងលើ ។[16] ព្រះរាជអាជ្ញា អាចត្រូវបានអនុញ្ញាតឲ្យផ្អាច់ពីមុខងារ ឬដាក់អោយនៅក្រៅ

[14] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ២៧ ។

[15] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ២៨ ។

[16] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៨៩។

ក្របខណ្ឌព្រះរាជអាជ្ញាបានតាមការស្នើសុំ ឬរបស់ស្ថាប័នដោយមានការយល់ព្រមពីសាមីខ្លួន ។[17] ក្នុងករណីចាំបាច់ដែលត្រូវទៅបំពេញការងារ ជាបណ្ដោះអាសន្ននៅក្នុងតំណែងមុខងារសាធារណៈ តំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល រដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬតំណែងទីប្រឹក្សាគ្រប់ឋានានុក្រមព្រះរាជអាជ្ញាអាចសុំផ្ដាច់ពីមុខងារ ។ ការអនុញ្ញាតដោយផ្ដាច់ពីមុខងារនេះ ត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួនឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមរបស់សាមីខ្លួន ។ ក្នុងរយៈពេលនៃការអនុញ្ញាតឱ្យផ្ដាច់ពីមុខងារព្រះរាជអាជ្ញាត្រូវបានបន្តទទួលប្រាក់បៀវត្សរ៍ព្រមទាំងសិទ្ធិក្នុងការឡើងឋានៈ ឬឋានន្តរស័ក្តិនិងស្ថិតក្នុងការចូលនិវត្តន៍របស់ខ្លួនប៉ុន្តែពុំមាន មានប្រាក់បំណាច់មុខងារនិងប្រាក់រង្វាន់ផ្សេងផ្សេងទៀតនៃមុខងារដើមរបស់ខ្លួនទេ ។ ក្នុងករណីចាំបាច់ ដែលត្រូវទៅបំពេញការងារជាបណ្ដោះអាសន្ន នៅក្នុងសហគ្រាសសាធារណៈ ឬក្នុងតាមអង្គការអន្តរជាតិព្រះរាជអាជ្ញាអាចសុំនៅក្រៅក្របខ័ណ្ឌ ។ ការអនុញ្ញាតឲ្យនៅក្រៅក្របខ័ណ្ឌនេះ ត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមរបស់សាមីខ្លួន ។ ព្រះរាជអាជ្ញាដែលត្រូវបានដាក់ឲ្យនៅក្រៅក្របខ័ណ្ឌ ពុំមានសិទ្ធទទួលប្រាក់បៀវត្សរ៍ ប្រាក់បំណាច់មុខងារនិងប្រាក់បំណាច់ផ្សេងៗ ។ ព្រះរាជអាជ្ញា អាចត្រូវបានផ្អាកពីមុខងារជាបណ្ដោះអាសន្នដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងករណីដែលព្រះរាជអាជ្ញានោះកំពុងជាប់នៅក្នុងនីតិវិធីវិន័យ របស់ក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ព្រះរាជអាជ្ញាអាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ក្នុងករណីដែលព្រះរាជអាជ្ញានោះទទួលទណ្ឌកម្មជាវិន័យថ្នាក់ទី២(ពីរ) ឬនៅពេលដែលព្រះរាជអាជ្ញានោះបានបោះបង់ការងារ ឬអវត្តមានលើសពី៣០(សាមសិប)ថ្ងៃ ឬដោយសាមីខ្លួនសុំលាឈប់ជាស្ថាពរ ។ ការលាឈប់របស់ព្រះរាជអាជ្ញា ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយសាមីខ្លួន ពាក្យសុំនេះ ត្រូវជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ នឹងចាត់ការតាមនីតិវិធី ។ ក្នុងករណីចាំបាច់ដោយមូលហេតុផ្ទាល់ខ្លួន គ្រួសារ ឬវិសមិតភាព ព្រះរាជអាជ្ញាដែលស្នើសុំនៅទំនេរគ្មានបៀវត្សរ៍សម្រាប់រយៈពេលកំណត់ណាមួយ តាមពាក្យសុំរបស់សាមីខ្លួន ។ ការអនុញ្ញាតឲ្យនៅទំនេរគ្មានប្រាក់បៀវត្សរ៍ អាចធ្វើឡើងសម្រាប់រយៈពេលម្ដង ១ (មួយ) ឆ្នាំ ឬម្ដង ២ (ពីរ) ឆ្នាំ ។ ការអនុញ្ញាតឲ្យនៅទំនេរនេះ អាចបានតែ ពីរដងគត់ ហើយរយៈពេលសរុបនៃការអនុញ្ញាតនេះមិនឲ្យលើសពី៤(បួន)ឆ្នាំ ឡើយ ។ លក្ខខណ្ឌដែលអាចអនុញ្ញាតឲ្យនៅទំនេរគ្មានបៀវត្សរ៍ តាមការស្នើសុំរបស់សាមីខ្លួនបានលុះត្រាតែ ព្រះរាជអាជ្ញានោះបានបំពេញមុខងារក្នុងក្របខ័ណ្ឌព្រះរាជអាជ្ញាយ៉ាងតិច ៤ (បួន) ឆ្នាំ សិន មិនគិតពីព្រះរាជអាជ្ញាដែលត្រូវទទួលទណ្ឌកម្មការវិន័យថ្នាក់ទី២(ពីរ) ។

[17] ច្បាប់ស្ដីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៩០ ។

ពាក្យសុំដាក់ឲ្យនៅទំនេរ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយសាមីខ្លួនពាក្យសុំនេះត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងចាត់ការ ទៅតាមនីតិវិធី។[18]

## កថាខណ្ឌទី២៖ ភាតព្វកិច្ច និងការទទួលខុសត្រូវក្នុងនាមជាតំណាងអយ្យការ

ក្នុងនាមជាតំណាងអយ្យការ ព្រះរាជអាជ្ញាត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឲ្យ និងគោរពឲ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន ។[19] មានន័យថា ព្រះរាជអាជ្ញាត្រូវតែអនុវត្ត កិច្ចការទាំងឡាយដែលខ្លួនត្រូវបានបំពេញដោយមានទំនួលខុសត្រូវចំពោះកិច្ចការទាំងនោះ ដើម្បីសិក្សាពីការទទួលខុសត្រូវរបស់តំណាងក្នុងនាមជាតំណាងអយ្យការ យើងត្រូវដឹងថាតើ (១)កាតព្វកិច្ចរបស់តំណាងអយ្យការមានអ្វីខ្លះ? (២) និងទណ្ឌកម្មវិន័យ (៣)ការចោទប្រកាន់តាមផ្លូវតុលាការ (៤)ការចូលនិវត្តន៍ ។

### ១.ភាតព្វកិច្ចរបស់តំណាងអយ្យការ

ព្រះរាជអាជ្ញាត្រូវតែបំពេញតួនាទី ក៏ដូចជាភារៈកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវយ៉ាងម៉ឺងម៉ាត់និងមានភាពឆាប់រហ័ស តបទៅតាមច្បាប់កំណត់ និងដើម្បីការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស ក៏ដូចជាការលើកកម្ពស់សិទ្ធិមនុស្សដោយរួមជាវិភាគទានក្នុងការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌ឲ្យបានត្រឹមត្រូវ ។ លើសពីនេះទៅទៀតក្នុងនាមជាតំណាងអយ្យការ ព្រះរាជអាជ្ញាមានកាតព្វកិច្ចទាំងក្នុងជីវភាពរស់នៅប្រចាំថ្ងៃផងដែរ ដូចជា គាត់មិនត្រូវប្រព្រឹត្តអំពើណាមួយដែលរដ្ឋឲ្យអាប់ឱនកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងកិត្យានុភាពនៃអង្គការអយ្យការឡើយ ។[20]

### ២.ទណ្ឌកម្មវិន័យ

យោងតាមច្បាប់ស្តីពីលក្ខន្តិកៈ ចៅក្រម និងព្រះរាជអាជ្ញាបានកំណត់ថា ទណ្ឌកម្មវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ក្នុងន័យនេះប្រសិនបើអំពើដែលព្រះរាជអាជ្ញាបានប្រព្រឹត្តនោះ គឺជាបទល្មើស ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ហើយក៏ជាអំពើដែលផ្ទុយប្រាសចាកនឹងកាតព្វកិច្ចវិជ្ជាជីវៈ នោះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចធ្វើការដាក់ទណ្ឌកម្មវិន័យ ទៅលើព្រះរាជអាជ្ញានោះបាន ប៉ុន្តែការដាក់ទណ្ឌកម្មវិន័យនេះមិនបានធ្វើឱ្យបណ្តឹងអាជ្ញារលត់ឡើយ ។ គឺព្រះរាជអាជ្ញា ត្រូវតែទទួលទណ្ឌកម្មផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត ។ ចំពោះការទទួលទណ្ឌកម្មវិញ ព្រះរាជអាជ្ញាអាចត្រូវផ្អាក

[18] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៩១ ។

[19] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៩៦ ។

[20] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៩៦ ។

មុខងារជាបណ្តោះអាសន្ន ដោយប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សា ។[21] ច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញាមាត្រាហាសិបប្រាំ បានកំណត់អំពីទណ្ឌកម្មវិន័យដែលត្រូវបានបែងចែកជាពីរថ្នាក់មានដូចតទៅៈ

**ក.ទណ្ឌកម្មផ្នែកទីមួយ**

- ការស្តីបន្ទោសដោយផ្ទាល់មាត់
- ការស្តីបន្ទោសដោយចុះសំណុំលិខិតផ្ទាល់ខ្លួន
- ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាងដំឡើងឋានៈ ឬឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឲ្យលើសពី ២(ពីរ) ឆ្នាំទេ ។[22]

**ខ.ទណ្ឌកម្មទីពីរ**

- ការផ្លាស់ប្តូរដោយបង្ខំ
- អាចតម្រូវឲ្យទទួលបានការបណ្តុះបណ្តាលបន្ថែម
- ការព្យួរពីការងារមិនឲ្យមានប្រាក់បៀវត្សរ៍ក្នុងរយៈពេលមិនឲ្យលើសពីមួយឆ្នាំការបន្ថយមួយថ្នាក់ឬច្រើនថ្នាក់ឬ បន្ថយឋានន្តរស័ក្តិការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ ការបណ្តេញចេញពីក្របខណ្ឌ។[23]

**៣ .ការចោទប្រកាន់តាមផ្លូវតុលាការ**

ការចោទប្រកាន់តាមផ្លូវតុលាការរបស់ចៅក្រម ត្រូវយកមកអនុវត្តដូចគ្នាចំពោះព្រះរាជអាជ្ញា ។ ចៅក្រមដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយអាចត្រូវទទួលការចោទប្រកាន់តាមផ្លូវតុលាការ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចផ្ទេរសមត្ថកិច្ចទៅសាលាដំបូងផ្សេងក្រៅពីសាលាដំបូងដែល ចៅក្រមបំពេញ មុខងារ ។ ក្នុងករណីដែលចៅក្រមណាម្នាក់ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌហើយ ត្រូវបានព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ព្រះរាជអាជ្ញា ត្រូវជូនដំណឹងអំពីការចោទប្រកាន់នោះ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ ។ បើមានការចាប់ ឬឃាត់ខ្លួន ចៅក្រមណាម្នាក់ អាជ្ញាធរដែលមានសមត្ថកិច្ចត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អំពីការចាប់ឃាត់ខ្លួន ។[24] រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវជូនព័ត៌មានខាងលើនេះជាបន្ទាន់ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។[25] ចៅក្រម ដែលទទួលការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្អាកដោយស្វ័យប្រវត្តិ មិនអាចបំពេញមុខងារជាបណ្តោះអាសន្ន រហូតដល់មានសេចក្តីសម្រេចរបស់តុលាការអំពី

[21] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៩៩ ។

[22] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៥៥ ។

[23] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៥៥ ។

[24] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៥៧ ។

[25] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៥៨ ។

ទោសជាស្ថាពរ ។ ចៅក្រមនេះត្រូវទទួលប្រាក់បៀវត្សរ៍ជាធម្មតា រហូតដល់មានសាលក្រមសម្រេច របស់តុលាការថាមានទោស ។ ប្រាក់បៀវត្សរ៍នេះត្រូវផ្អាកជាបណ្តោះអាសន្ន តាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាប់ពីថ្ងៃដែលសាលក្រមតុលាការសម្រេចថាមានទោស ទោះបីមានបណ្តឹងឧទ្ធរណ៍ពីសាលក្រមនេះក៏ដោយ ។[26] ក្រោយករណីដែលចៅក្រមជាប់ចោទតាមផ្លូវតុលាការទទួលបានការលើកលែងចោទប្រកាន់ ឬត្រូវបានសម្រេចឲ្យរួចផុតពីការចោទប្រកាន់ជាស្ថាពរ ចៅក្រមនោះត្រូវទទួលឲ្យចូលធ្វើការវិញភ្លាម ដោយគិតពីអតីតភាពថ្នាក់ និងឋានន្តរស័ក្តិ សោធននិវត្តន៍ និងបៀវត្សរ៍ដែលត្រូវផ្អាកជាបណ្តោះអាសន្នពីមុនមកវិញទាំងអស់ ។ ទោះបីមានសេចក្តីសម្រេចពីតុលាការលើកលែងចោទប្រកាន់ ឬសម្រេចឲ្យរួចផុតពីបទចោទប្រកាន់ ឬផ្តន្ទាទោសក្តី បើសាមីខ្លួនបានប្រព្រឹត្តខុសនឹងក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា សាមីខ្លួនអាចដាក់ឲ្យចោទប្រកាន់ជាប់ពិន័យថែមទៀតដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។[27] ការផ្តន្ទាទោស ជាបទមជ្ឈិមប្រព្រឹត្តដោយចេតនាដោយគ្មានការព្យួរទោសបណ្តាលឲ្យមានការលុបឈ្មោះចេញពីក្របខ័ណ្ឌចៅក្រម គិតពីថ្ងៃសាលក្រមឬសាលដីកាចូលជាស្ថាពរ។

**៤.ការចូលនិវត្តន៍**

ព្រះរាជអាជ្ញាទាំងពីរភេទត្រូវចូលនិវត្តន៍នៅពេលគ្រប់អាយុ៦០(ហុកសិប)ឆ្នាំ ។[28] ដោយឡែកព្រះរាជអាជ្ញាទាំងអស់នៃអយ្យការអមតុលាការកំពូល ដែលមានអាយុចាប់ពីហុកសិបឆ្នាំឡើងទៅ ត្រូវចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន ។ ប៉ុន្តែនៅពេលដែលដល់អាយុ ៦៥(ហុកសិបប្រាំ)ឆ្នាំ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវសម្រេចចិត្តពីការបន្តការងាររបស់ព្រះរាជអាជ្ញា ទាំងអស់នៃមហាអយ្យការអមតុលាការកំពូលតាម ការសុំរបស់សាមីខ្លួន ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រអំពីព្រឹត្តិការណ៍ខាងលើនេះ ។ ចៅក្រមដែលបានបម្រើការងារគ្រប់ ៣០(សាមសិប) ឆ្នាំហើយអាចចូលនិវត្តន៍បានមុនអាយុ ៦០(ហុកសិប) ឆ្នាំ ។[29] បញ្ញត្តិចាប់ពីមាត្រា៦៣ ដល់មាត្រា ៦៧ នៃជំពូកទី២ (ចៅក្រម) ផ្នែកទី២ (ការចូលនិវត្តន៍នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា) ដែលអនុវត្តចំពោះចៅក្រម ត្រូវយកមកអនុវត្តដូចគ្នាផងដែលចំពោះព្រះរាជអាជ្ញា។

## ផ្នែកទី២៖ មុខការនៃអង្គការអយ្យការ

---

[26] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៥៩ ។

[27] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ៦១ ។

[28] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ១០១ ។

[29] ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា មាត្រា ១០២ ។

នៅក្នុងមុខការនៃអង្គការអយ្យការ យើងនឹងត្រូវធ្វើការសិក្សាអំពីអង្គការនៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត(កថាខណ្ឌទី១)រហូតដល់ នៃអង្គការអយ្យការអមតុលាការជាន់ខ្ពស់(កថាខណ្ឌទី២) ។

## កថាខណ្ឌទី១៖ អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

### ១. អំណាច

នៅអង្គការអយ្យការសាលាដំបូង មានតែព្រះរាជអាជ្ញាព្រះរាជអាជ្ញារងទេដែលជាតំណាងស្ថាប័នអយ្យការនៅក្នុងដែលអង្គការអយ្យការអមសាលាដំបូង គឺជាអ្នកដែលបើកការស៊ើបអង្កេតជាបឋម ឬដំបូងទៅលើរឿងក្តីព្រហ្មទណ្ឌដែលខ្លួនទទួលបាន ។[30] ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត-រាជធានី មានសិទ្ធិ អំណាចៈ ដឹកនាំសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីខ្លួន ដំបូងប្រើប្រាស់អំណាចដែលក្រមនីតិវិធីព្រហ្មទណ្ឌទទួលស្គាល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ស៊ើបអង្កេត ។ អាចចុះទៅកាន់កន្លែងស៊ើបអង្កេតនិងធ្វើការណែនាំអ្វីដែលមានប្រយោជន៍ដល់មន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌ ។ អាចធ្វើអធិការកិច្ចបានគ្រប់ពេលនៅអង្គភាពនគរបាលយុត្តិធម៌ ។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយអាចត្រួតពិនិត្យវិធានការឃាត់ខ្លួនជាពិសេសគឺ ការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន ។

### ២. សមត្ថកិច្ចតាមដែនដី

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា

- ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចគឺ ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស ។

*ឧទាហរណ៍៖* ដូចជា បទល្មើសត្រូវបានប្រព្រឹត្តនៅខេត្តព្រៃវែង នោះសមត្ថកិច្ចអយ្យការអមសាលាដំបូងខេត្តព្រៃវែង ។

- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស ។

*ឧទាហរណ៍៖* ដូចជាបទជនល្មើសលួចម៉ូតូនៅក្រុងព្រះសីហនុ តែគេដឹងថាជនល្មើសមានទីលំនៅក្នុងខេត្តកំពង់ចាម ។ ដូចនេះ ជនរងគ្រោះអាចដាក់ពាក្យបណ្តឹង អយ្យការអមសាលាដំបូងខេត្តកំពង់ចាមបានប្តឹងករណីនេះអយ្យការអមសាលាដំបូងខេត្តកំពង់ចាមក៏ជាអ្នកមានសមត្ថកិច្ចដែរ ។

- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើសដូចជា បទល្មើសបានប្រព្រឹត្តបទល្មើសសម្លាប់នៅរាជធានីភ្នំពេញ ។ តែជនល្មើសត្រូវចាប់បាននៅខេត្តបាត់ដំបង ដូចនេះ អយ្យការអមសាលាដំបូងខេត្តបាត់ដំបងក៏មានសមត្ថកិច្ចដូចគ្នា ។

## កថាខណ្ឌទី២៖ អង្គការអយ្យការអមតុលាការជាន់ខ្ពស់

---

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៣៨ ។

## ១.អង្គការមហាអយ្យការអមសាលាឧទ្ធរណ៍

មហាអយ្យការអមសាលាឧទ្ធរណ៍តំណាង ដោយអគ្គព្រាជអាជ្ញាអគ្គព្រះរាជអាជ្ញារងនិងព្រះរាជអាជ្ញា ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិអំណាចធ្វើការឃ្លាំមើល និងត្រួតពិនិត្យនគរបាលយុត្តិធម៌ ។ អាច កោះ អញ្ជើញអ្នកទទួលខុសត្រូវ នៃអង្គភាពនគរបាលយុត្តិធម៌មកពិភាក្សាអំពីបញ្ហាដែលទាក់ទងនៃការប្រព្រឹត្តទៅ របស់ អង្គភាពនេះ ។ អាចប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ឲ្យបំពេញភារកិច្ចទាំងឡាយដែល ខ្លួន យល់ថាមានប្រយោជន៍ដល់ការគ្រប់គ្រងឬដំណើរការល្អនៃនគរបាលយុត្តិធម៌ ។ អាចធ្វើអធិការកិច្ចគ្រប់ពេល នៅអង្គភាពនគរបាលយុត្តិធម៌ អាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យវិធានការឃាត់ខ្លួនជាពិសេសការ គោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន ។ ប្រធានអង្គភាព នគរបាលយុត្តិធម៌មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌គ្រប់រូប ត្រូវគោរពតាមអធិបញ្ជារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ នៅពេល មានរឿងព្រហ្មទណ្ឌ តើយើងអាចដាក់ពាក្យបណ្តឹងទៅអង្គការអយ្យការណាមួយ ឬក៏អាចដាក់បណ្តឹង ផ្ទាល់ទៅ មហាអយ្យការអមសាលាឧទ្ធរណ៍?

ដូចបានជម្រាបជូនរួចមកហើយនៅតាមខេត្ត-រាជធានី មានអង្គការអយ្យការអមសាលាដំបូងក្នុងករណីមាន បទល្មើសព្រហ្មទណ្ឌកើតឡើងជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ពាក្យបណ្តឹងទៅអង្គការអយ្យការអម សាលាដំបូងខេត្ត-រាជធានីទាំងនោះ តែពុំអាចដាក់ពាក្យបណ្តឹងផ្ទាល់ មកមហាអយ្យការអមសាលាឧទ្ធរណ៍ទេ ។ ព្រោះមហាអយ្យការអមសាលាឧទ្ធរណ៍ អាចទទួលសំណុំរឿងក្តីព្រហ្មទណ្ឌណាមួយ មកចាត់ការលុះត្រាតែ អយ្យការអមសាលាដំបូងខេត្ត-រាជធានី សម្រេចតម្កល់សំណុំរឿងទុកឥតចាត់ការ ហើយមានបណ្តឹងឧទ្ធរណ៍លើ ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការនោះ ទើបអយ្យការអមសាលាដំបូងខេត្ត-រាជធានី បញ្ជូនមកមហាអយ្យការ អមសាលាឧទ្ធរណ៍ពិនិត្យចាត់ការ ។ នៅពេលបណ្តឹងកំពុងចាត់ការដោយព្រះរាជអាជ្ញា តើស្ថាប័នណាមានសិទ្ធិធ្វើ អធិបញ្ជាមកអយ្យការអមសាលាដំបូងដែលកំពុងកាន់សំណុំរឿងនោះបាន? យោងមាត្រា ២៩ នៃក្រមនីតិវិធី ព្រហ្មទណ្ឌរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិធ្វើអធិបញ្ជាឲ្យចោទប្រកាន់ឬក៏ ចាត់ឲ្យចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ថា ជាការគួរមកអយ្យការអមសាលាដំបូងខេត្ត-រាជធានី ។ ក្នុងករណីមានបណ្តឹងព្រហ្មទណ្ឌណាមួយកំពុងចាត់ការដោយមន្ត្រីនគរបាលយុត្តិធម៌ តើចាំបាច់ទេ ក្នុងការសុំយោបល់ ឬសុំការអនុញ្ញាតពីព្រះរាជអាជ្ញា ? ដូចដែរបានជម្រាបជូនមកហើយព្រះរាជអាជ្ញា ឬព្រះរាជ អាជ្ញារងជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ហេតុនេះទោះជាក្នុង ករណីនៃការបើកស៊ើបអង្កេតបឋម ឬស៊ើបអង្កេតជាក់ស្តែងក៏ដោយមន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវមានការ សុំយោបល់និងការអនុញ្ញាតពីព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង លើកិច្ចការងាររបស់ខ្លួនជាដាច់ខាត ។ តើការដាក់ វិន័យទៅលើមន្ត្រីនគរបាលយុត្តិធម៌ដែលបានប្រព្រឹត្តកំហុសមានកម្រិតណាខ្លះដែរ? អគ្គព្រះរាជអាជ្ញាអមសាលា

ឧទ្ធរណ៍ទទួលដំណឹងពីកំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌ តាមរបាយការណ៍ ពីព្រះរាជអាជ្ញា ឬពីចៅក្រមស៊ើបសួរ បន្ទាប់មកអគ្គព្រះរាជអាជ្ញាប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិដើម្បីចាប់ដំណើរការនីតិវិធីវិន័យ ។ ក្នុងករណីអគ្គព្រះរាជអាជ្ញាយល់ឃើញថា កំហុសប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់មានសភាពធ្ងន់ធ្ងរ អគ្គព្រះរាជអាជ្ញាមានសិទ្ធិប្រកាសចេញនូវវិធានការរួមមាន៖ ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្ដោះអាសន្នក្នុងរយៈពេល ៥ ឆ្នាំយ៉ាងយូរ និងហាមមិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ ។

### ២.អគ្គការមហាអយ្យការអមតុលាការកំពូល

មហាអយ្យការអមតុលាការកំពូល គឺជាស្ថាប័នមួយដែលមានអគ្គព្រះរាជអាជ្ញាអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាដែលជាតំណាងអយ្យការអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាសមត្ថភាពមួយរូបក្នុងចំណោមសមាជិក ១១រូប នៃសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានព្រះមហាក្សត្រជាព្រះរាជទានឲ្យស្ថាប័នមានតួនាទីចម្បង ក្នុងការតែងតាំងការផ្លាស់ប្ដូរ ការដាក់ឲ្យនៅទំនេរ ។[31] ចំណែកនៅក្នុងករណីជំនុំជម្រះវិញ អយ្យការអមតុលាការកំពូល ដើម្បីចូលរួមស្នើសុំឲ្យមានការគោរពច្បាប់នៅក្នុងពេលដែលមកដាក់បណ្ដឹងសារទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងបណ្ដឹងតវ៉ាផ្សេងៗទៀត ដែលបានមកដាក់ជូនតុលាការកំពូលពិនិត្យ ។[32]

## ផ្នែកទី៣៖ ការអនុវត្តបណ្តឹងអាជ្ញា

បណ្ដឹងអាជ្ញា គឺជាបណ្ដឹងព្រហ្មទណ្ឌ ។ ព្រះរាជអាជ្ញា គឺជាម្ចាស់នៃបណ្ដឹងអាជ្ញា ។ មានតែព្រះរាជអាជ្ញាទេដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា ។ ដើម្បីអោយកាន់តែយល់ច្បាស់ យើងនិងសិក្សាទៅលើ **(កថាខណ្ឌទី១) បណ្ដឹងអាជ្ញា (កថាខណ្ឌទី២)បណ្ដឹងរដ្ឋប្បវេណីក្នុងបទល្មើសព្រហ្មទណ្ឌ** ។

### កថាខណ្ឌទី១៖ បណ្តឹងអាជ្ញា

#### ១. តើអ្វីទៅជាបណ្តឹងអាជ្ញា?

បណ្ដឹងអាជ្ញា ជាបណ្ដឹងមួយដើរតួនាទីយ៉ាងសំខាន់ក្នុងរឿងក្ដីព្រហ្មទណ្ឌ ។ ពោលបណ្ដឹងអាជ្ញាបានផ្ដល់សិទ្ធិឱ្យស្ថាប័នអយ្យការជាអ្នកចោទប្រកាន់ ដើម្បីឱ្យរឿងក្ដីព្រហ្មទណ្ឌមានចលនាបើទោះបីរឿងក្ដីព្រហ្មទណ្ឌនោះគូរភាគីនៃជំលោះសម្រុះសម្រួលត្រូវរ៉ូវគ្នាយ៉ាងណាក៏ដោយ ។ មានន័យថា នៅក្នុងរឿងក្ដីព្រហ្មទណ្ឌព្រះរាជអាជ្ញា

[31] ច្បាប់ស្ដីពីការរៀបចំនឹងប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, នស/រកម/០៧១៤/០១៧ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ មាត្រា ៤ ។

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៣២ ។

ជាម្ចាស់ដើមបណ្តឹងអាជ្ញា ក្នុងករណីជនបង្កបានសងជាព្យាសនកម្មដែលជនរងគ្រោះផ្នែករដ្ឋប្បវេណីអស់ហើយក៏ដោយ ព្រះរាជអាជ្ញានៅតែអាចធ្វើការចោទប្រកាន់ឬដាក់ឲ្យដំណើរការបណ្តឹងអាជ្ញាបានដែរ ព្រោះវាជាបណ្តឹងពីរផ្សេងគ្នា ។

## ២. ការរំលត់នៃបណ្តឹងអាជ្ញា

ការរលត់បណ្តឹងអាជ្ញា គឺជាមូលហេតុដែលធ្វើឲ្យតែរាជអាជ្ញា មិនអាចដាក់ឲ្យដំណើរការបណ្តឹងអាជ្ញាដែលត្រូវបញ្ឈប់ការធ្វើដំណើរការបណ្តឹងអាជ្ញា ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថាមូលហេតុនៃការរំលត់បណ្តឹងអាជ្ញាមានដូចតទៅៈ

- មរណៈភាពនៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- ការនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ
- មរណាភាពនៃជនល្មើសៈ ក្នុងករណីដែលជនល្មើសបានទទួលមរណៈភាព មុនពេលមានបណ្តឹងអាជ្ញាឬស្លាប់មុនពេលប្រកាសសេចក្តីសម្រេចស្ថាពរផ្តន្ទាទោសជនល្មើសនោះបណ្តឹងអាជ្ញាត្រូវរលត់ ។[33]
- ការផុតអាជ្ញាយុកាលៈ អាជ្ញាយុកាលនៃបណ្តឹងអជ្ញាមាន១៥ឆ្នាំចំពោះបទឧក្រិដ្ឋ៥ឆ្នាំសម្រាប់បទមជ្ឈឹម និង ១ឆ្នាំបទលហុ។[34]
- ការលើកលែងទោសជាទូទៅៈត្រូវបានអនុវត្តទៅតាមច្បាប់ស្តីពីការលើកលែងទោសដែលមានកំណត់នៅក្នុយមាត្រា៩០នៃរដ្ឋធម្មនុញ្ញ។
- ការនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ៈបណ្តឹងអជ្ញាត្រូវរលត់ទៅតាមបទល្មើសមួយចំនួនដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌចាស់ដែលត្រូវបាននិរាករណ៍ដោយច្បាប់ព្រហ្មទណ្ឌថ្មី។
- អាជ្ញាអស់ជំនុំៈជនណាដែលសម្រេចឲ្យរួចខ្លួនជាស្ថាពរ ហើយជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេ។ [35]

## កថាខណ្ឌទី២ៈ បណ្តឹងរដ្ឋប្បវេណីក្នុងបទល្មើសព្រហ្មទណ្ឌ

---

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ២២ ។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ២៤ ។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៨ ។

### ១. បណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី គឺជាលិខិតលាយលក្ខណ៍ អក្សរដែលរៀបចំឡើងដោយដើមចោទ (ម្ចាស់បណ្តឹង) ធ្វើការអះអាងអំពីអត្ថិភាព ឬនិត្ថិភាពនៃសិទ្ធិទាមទារ តាមច្បាប់សារធាតុ(ច្បាប់នីតិវិធី) ចំពោះឲ្យភាគីម្ខាងទៀតហៅថាចុងចម្លើយ(អ្នកដែលត្រូវគេប្តឹង) ។ បណ្តឹងរដ្ឋប្បវេណី មានកម្មវត្ថុដើម្បីទាមទារឲ្យតុលាការទទួលស្គាល់អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារតាមច្បាប់សារធាតុ ។ បណ្តឹងរដ្ឋប្បវេណីមាន៣ប្រភេទ ៖

- បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក គឺជាបណ្តឹងទាមទារ ឲ្យតុលាការចេញសាលក្រម ដោយបង្គាប់ឲ្យចុងចម្លើយផ្តល់តាវកាលិក (វត្ថុ សកម្មភាព ឬ ជាកម្មវត្ថុនៃកាតព្វកិច្ច) ជាកំណត់មួយ ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារតាមផ្លូវច្បាប់ ។ ការទាមទារក្នុងបណ្តឹងនេះ អាចជាការទាមទារឲ្យប្រគល់(ប្រាក់ ឬ វត្ថុ) ទាមទារឲ្យធ្វើសកម្មភាពជាកំណត់មួយ (ឧ: តុលាការបង្គាប់ឲ្យចុងចម្លើយរុះរើសម្ភារៈចេញពីផ្ទះដួល) ឬ ទាមទារមិនឲ្យធ្វើសកម្មភាពជាកំណត់មួយ (ឧ: តុលាការបង្គាប់ឲ្យចុងចម្លើយផ្អាកការសាងសង់ផ្ទះ) ។
- បណ្តឹងទាមទារឲ្យបញ្ជាក់ គឺជាបណ្តឹងទាមទារឲ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដោយផ្អែកលើការអះអាងរបស់ដើមចោទ នូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តណាមួយ ដែលជាការទាមទារតាមផ្លូវបណ្តឹង ។ ឧទាហរណ៍៖ ដើមចោទទាមទារ ឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារបញ្ជាក់អំពីអត្ថិភាព នៃសិទ្ធិលុបចោលរបស់ដើមចោទ ចំពោះកិច្ចសន្យាលក់ទិញដីរវាងដើមចោទ ជាមួយចុងចម្លើយ ។
- បណ្តឹងទាមទារឲ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងទាមទារ ឲ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មី នូវទំនាក់ទំនងគតិយុត្ត ដោយផ្អែកលើការអះអាង អំពីអត្ថិភាពនៃសិទ្ធិ ឬ អំពីមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តកំណត់មួយ ដែលជាការទាមទារតាមផ្លូវបណ្តឹង ។ ឧទាហរណ៍៖ ដើមចោទទាមទារឲ្យតុលាការចេញសាលក្រម ដោយបង្គាប់ឲ្យដើមចោទលែងលះជាមួយចុងចម្លើយ ។

### ២. ដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណី គឺសំដៅទៅលើបុគ្គលដែលដាក់ពាក្យប្តឹងទាមទារសំណងជំងឺចិត្ត ឬសំណងរដ្ឋប្បវេណីពីជនល្មើស ដែលបានបង្កឲ្យមានការខូចខាតទៅលើភាគីជនរងគ្រោះ ។ ការខូចខាតដែលត្រូវប្តឹងទាមទារសំណងរដ្ឋប្បវេណី ឬសំណងជំងឺចិត្តមានបីចំនុចគឺដូចជា ៖

- ព្យសនកម្មតាម រូបរាងកាយ ៖ គឺជាការធ្វើអោយខូចខាត ឬប៉ះពាល់ដល់រូបរាងកាយរបស់ជនរងគ្រោះដែលបង្កើតឲ្យមានការឈឺចាប់ដោយប្រការណាមួយ ដោយសារទង្វើរបស់ជនល្មើសបានធ្វើទៅលើជនរងគ្រោះ ។

- ព្យសនកម្មតាមផ្លូវចិត្ត ៖ គឺជាទង្វើមួយដែលជនល្មើសបានធ្វើឲ្យជនរងគ្រោះ ជួបបញ្ហាវិបត្តិផ្លូវចិត្តធ្វើអោយឈឺចាប់ក្នុងចិត្ត ឬក៏ការប៉ះពាល់ដល់សតិអារម្មណ៍របស់ជនរងគ្រោះ ។
- ព្យសនកម្មតាមសម្ភារៈ ៖ គឺធ្វើអោយខូចខាតដល់របស់ប្រើប្រាស់ ឬវត្ថុផ្សេងៗ ដែលកើតចេញពីអំពើល្មើសរបស់ជនល្មើសប្រព្រឹត្តទៅលើជនរងគ្រោះ មានដូចជារបស់របប្រើប្រាស់សម្ភារៈ ទ្រព្យសម្បត្តិ ឬវត្ថុមានតម្លៃផ្សេង ។

**៣.ការចូលរួមរបស់អយ្យការក្នុងរឿងក្ដីរដ្ឋប្បវេណី**

ព្រះរាជអាជ្ញា មាននាទីជាគូក្ដីរណប ។ គូក្ដីរណប គឺជាឋានៈដែលមន្ត្រីអយ្យការកាន់កាប់នៅពេលគាត់ធ្វើអន្តរាគមន៍ នៅក្នុងរឿងក្ដីមួយដែលគាត់មិនមែនជាដើមចោទ ហើយក៏មិនមែនជាចុងចោទ ប៉ុន្តែគាត់គ្រាន់តែចូលរួមក្នុងនីតិវិធី ដើម្បីផ្ដល់ការសង្កេតរបស់គាត់លើការអនុវត្តច្បាប់ ។ តួនាទីរបស់ព្រះរាជអាជ្ញា នៅក្នុងសវនាការរដ្ឋប្បវេណីមិនមានចែងឲ្យច្បាស់ជាក់លាក់ណាមួយទេនៅក្នុងពេលបច្ចុប្បន្ននេះ ។ សារាចរលេខៈ៤ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៨៤ របស់ក្រសួងសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលតុលាការត្រូវតែយកមកសំអាងរហូតមកទល់សព្វថ្ងៃនេះ សារាចរនេះមិនបានតម្រូវតំណាងអយ្យការត្រូវតែចូលរួមនៅក្នុងសវនាការរដ្ឋប្បវេណីទេ ។ តំណាងអយ្យការស្នើសុំសំណុំ រដ្ឋប្បវេណីណាមួយមកពិនិត្យ សារាចរដដែលនេះមិនបានបញ្ជាក់ថារឿងរដ្ឋប្បវេណីសាមញ្ញតំណាងអយ្យការត្រូវមាន វត្តមានក្នុងសវនាការទេប៉ុន្តែមិនបានដឹងអំពីវត្តមានរបស់តំណាងអយ្យការក្នុងឋានៈជាកូនក្ដី ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែងរហូតមកទល់បច្ចុប្បន្ននេះ គេសង្កេតឃើញថាវត្តមានតំណាងអយ្យការនៅក្នុងសវនាការ បើមិនទាំងអស់ក៏ស្ទើរតែគ្រប់រឿងដែល ទោះបីរឿងក្ដីនោះមិនពាក់ព័ន្ធដោយលក្ខណវិនិច្ឆ័យសម្រាប់ឲ្យគាត់ដឹងខ្លួនជាគូក្ដីដើមក៏ដោយ។

# ជំពូកទី៣

# ការចោទប្រកាន់ និងមិនចោទប្រកាន់របស់តំណាងអយ្យការ

## ផ្នែកទី១៖ ការមិនចោទប្រកាន់របស់តំណាងអយ្យការ

បើយើងពិនិត្យមើលមុនពេលក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា បានអនុវត្តនូវគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ដោយច្បាប់ស្តីពីនិតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ។ តាមរយៈគោលការណ៍នេះ ព្រះរាជអាជ្ញាត្រូវតែសម្រេចធ្វើការចោទប្រកាន់គ្រប់បទល្មើសទាំងអស់ ដោយមិនអាចសម្រេចមិនចោទប្រកាន់បាននោះទេ ។ ប៉ុន្តែក្រោយមកក៏មានការវិវត្តន៍នៃបរិបទសង្គមកម្ពុជាបានទទួលយកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់មកអនុវត្តន៍វិញ តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ព្រះរាជអាជ្ញា ថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ហើយព្រះរាជអាជ្ញាបើកការស៊ើបអង្កេត ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម មុននឹងសម្រេចថា តើត្រូវធ្វើការចោទប្រកាន់ឬតម្កល់រឿងទុកឥតចាត់ការនៃបទល្មើស តាមរយៈន័យនេះដូចបានបកស្រាយខាងលើរួចមកហើយ ក្រមនីតិវិធីព្រហ្មទណ្ឌ នេះក៏បានផ្តល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញាចំពោះការសម្រេចមិនចោទប្រកាន់ផងដែរ មានន័យថា ទោះបីព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញាក៏ពិតមែន ប៉ុន្តែមិនមែនមានន័យថា ព្រះរាជអាជ្ញា មានសិទ្ធិចោទប្រកាន់ទៅលើអំពើដែលបង្កើតបានជាបទល្មើសទាំងអស់នោះទេ ។ ព្រះរាជអាជ្ញាអាចសម្រេច តម្កល់រឿងទុកឥតចាត់ការតាមរយៈការវាយតម្លៃរបស់ខ្លួន ដោយធ្វើការថ្លឹងថ្លែងទៅលើស្ថានភាពដែលពាក់ព័ន្ធនឹងអំពើ ទោះបីអំពើនោះច្បាប់បានបញ្ញត្តិថាជាបទល្មើសក៏ដោយ មានន័យថា ព្រះរាជអាជ្ញាត្រូវពិចារណាដល់អំពើដែលបង្កឱ្យមានភាពរឹករវល់ដល់សង្គមសាធារណៈក្នុងកំរិតណាមួយ និងភស្តុតាងដែលប្រមូលបានទៅតាមរយៈការស៊ើបអង្កេតជាអាទិ៍ ។ ខ្លឹមសារនៃការទាំងស្រុងនៃការតម្កល់ទុកឥតចាត់ការរបស់តំណាងអយ្យការត្រូវបានបកស្រាយយ៉ាងលំអិតទៅតាមចំណុចនីមួយៗដូចខាងក្រោមនេះ៖ **កថាខណ្ឌទី១. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ កថាខណ្ឌទី២. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ កថាខណ្ឌទី៣. យន្តការជំរុញឱ្យមានការចោទប្រកាន់ឡើងវិញ ។**

### កថាខណ្ឌទី១៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

តើអ្វីជាការតម្កល់រឿងមិនចាត់ការ? តាមន័យសាមញ្ញ ការតម្កល់រឿងទុកមិនចាត់ការមានន័យថា ព្រះរាជអាជ្ញាទទួលរឿង ចុះក្នុងបញ្ជីបណ្តឹង រួចហើយមិនចាត់ការបន្តទៅមុខទៀតទេ ដោយទុកបណ្តឹងនោះចោលក្នុងបញ្ជីចុះបណ្តឹងនោះ ។ ថ្វីត្បិតតែព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការតាមឆន្ទានុសិទ្ធ តាមរយៈការថ្លឹងថ្លែងរបស់ខ្លួន ប៉ុន្តែការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ ត្រូវផ្អែកទៅលើមូលដ្ឋានត្រឹមត្រូវ និងសមស្របដែលមានដូចជា៖ នត្ថិភាពនៃ បទល្មើស, មូលហេតុគតិយុត្តិ, ការចោទប្រកាន់ដែលមិនបានផ្តល់ផលប្រយោជន៍ ។ តើមានការលើកឡើងពាក់ព័ន្ធយ៉ាងណាខ្លះ ចំពោះការតម្កល់រឿងទុកឥតចាត់ការ ។ ដើម្បីងាយស្រួលក្នុងការបកស្រាយ

ឱ្យកាន់តែស៊ីជម្រៅនោះ យើងខ្ញុំបានបែងចែកជាបីចំណុចគឺៈ នត្ថិភាពនៃបទល្មើស(១) មូលហេតុគតិយុត្តិ(២) និង ការចោទប្រកាន់ដែលមិនបានផ្តល់ផលប្រយោជន៍(៣) ។

**១.នត្ថិភាពនៃបទល្មើស**

មុនឈានដល់ការបកស្រាយ យើងត្រូវស្វែងយល់ជាមុនថាអ្វីទៅជា "នត្ថិភាពនៃបទល្មើស"? ពាក្យថា "នត្ថិភាព" មានន័យថា ជាភាវៈគ្មាន ភាពនៃអ្វីៗដែលមិនមាន ការឥតមាន ។ សរុបមក នត្ថិភាពនៃបទល្មើស គឺសំដៅទៅលើរាល់អំពើដែលបានបង្កើតទៅជាព្យសនៈកម្ម ប៉ុន្តែមិនប្រាកដថាអំពើទាំងអស់នោះជាបទល្មើសព្រហ្មទណ្ឌនោះឡើយ ។ បើយើងពិនិត្យទៅតាមគោលការណ៍នីត្យានុកូលភាព មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះ មានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន មានន័យថា លុះត្រាតែមានអត្ថបទច្បាប់បានចែងថា អំពើនោះជាបទល្មើសទើបការចោទប្រកាន់អាចប្រព្រឹត្តទៅបាន ដូច្នេះ នត្ថិភាពនៃបទល្មើស គឺសំដៅទៅដល់ អវត្តមាននៃបទល្មើស និងធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់ ។ អ្វីទៅដែលកំណត់ថាជាអវត្តមាននៃបទល្មើស ។

**ក.អវត្តមាននៃបទល្មើស**

នៅខណៈពេលដែលព្រះរាជអាជ្ញា ធ្វើការថ្លឹងថ្លែងទៅលើបណ្តឹងដែលខ្លួនទទួលបានដោយផ្ទាល់ ឬដោយកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមកសព្វគ្រប់ ព្រមទាំងបានបើកការស៊ើបអង្កេត ឬស្រាវជ្រាវបន្ថែម ហើយតែបណ្តឹងនោះ មិនមានបទល្មើសព្រហ្មទណ្ឌទេ នោះព្រះរាជអាជ្ញានឹងតម្កល់រឿងទុកឥតចាត់ការ ។ អវត្តមានបទល្មើស គឺសំដៅទៅលើបណ្តឹងដែលធ្វើឡើងប្រឆាំងនឹងអំពើ ដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ។ ឧទាហរណ៍ថាៈ បណ្តឹងនោះជាបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានប្តឹងខុសសមត្ថកិច្ចតុលាការ ឬក៏ការបញ្ជូនកំណត់ហេតុដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយសេចក្តីសន្និដ្ឋានដោយមានការភ័ន្តច្រលំឬខុស ។ បន្តចំពោះធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់វិញ តើមានការបកស្រាយយ៉ាងណាខ្លះ?

**ខ.ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់**

ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់ គឺមានន័យថាអំពីមួយត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌលុះត្រា តែអំពើនោះមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ។ ករណីដែលមានធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ វាជាកត្តាមួយដែលនាំឱ្យព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ចំពោះអំពើនោះបានទេ កាលណាព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បាន នោះការតម្កល់រឿងទុកឥតចាត់ការត្រូវបានយកមកអនុវត្ត ។ ជាគោលការណ៍ ធាតុផ្សំនៃបទល្មើសមានបីគឺ ៖ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត ។

ធាតុនីត្យានុកូល ឬធាតុច្បាប់ គឺជាធាតុផ្សំមួយទាក់ទងនឹងច្បាប់ អំពើមួយត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ លុះត្រាតែមានច្បាប់បញ្ញត្តិចែងថា អំពើនោះជាបទល្មើស ។ ឧទាហរណ៍ៈ អំពើលួច គឺជាបទល្មើស

ព្រហ្មទណ្ឌ ព្រោះអំពើនោះត្រូវបានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌ ថាជាបទល្មើសព្រហ្មទណ្ឌ គឺមានន័យថាយើងអាចកំណត់ថាអំពើនោះជាបទល្មើសបាន លុះត្រាតែមានច្បាប់ចែង ។

ចំពោះធាតុសត្យានុម័ត ឬធាតុសម្ភារៈ ដែលជាអង្គហេតុ ឬជាហេតុការណ៍ទាំងឡាយណាដែលបង្កឱ្យមាននូវអាកប្បកិរិយាណាមួយ ដែលត្រូវបានកំណត់ក្នុងអត្ថបទច្បាប់ ដែលបញ្ជាក់ថាជាបទល្មើស ។ អង្គហេតុទាំងនោះមានច្រើនសន្ធឹកសន្ធាបណាស់ អាចជាអំពើសកម្ម អំពើអកម្ម អំពើកើតឡើងភ្លាមៗ អំពើអូសបន្លាយ អំពើកើតឡើងម្តងម្កាល ឬជាទម្លាប់ ជាអាទិ៍ ។

រីឯធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ វាគឺជាផ្នែកខាងក្នុងនៃបទល្មើស ។ ធាតុផ្សំអត្តនោម័ត គឺជាឆន្ទៈ ឬចេតនា កិរិយាផ្លូវចិត្តរបស់អ្នកប្រព្រឹត្តចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គម ដែលគេបានប្រព្រឹត្ត នឹងចំពោះព្យសនកម្មដែលកើតឡើងចំពោះអំពើនោះ ។ ជាគោលការណ៍ពុំមានបទល្មើសទេ ប្រសិនណាបើគ្មានចេតនាប្រព្រឹត្ត លើកលែងតែច្បាប់បានចែងទុកជាមុនពីបទល្មើសដែលអាចកើតពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស និងការមិនគោរពកាតព្វកិច្ចណាមួយ ។

ដូនេះក្នុងករណីដែលអំពើណាមួយកើតឡើង ហើយធាតុផ្សំណាមួយដែលបានរៀបរាប់ខាងលើមិនត្រូវបំពេញត្រូវចាត់ទុកថា ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ ដែលនាំឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការបាន មានន័យថា ប្រសិនបើព្រះរាជអាជ្ញាសិក្សាទៅលើអំពើនោះឃើញថា អំពើនោះខ្វះនៅធាតុផ្សំណាមួយក្នុងចំណោមធាតុផ្សំទាំងបីដែលបានរៀបរាប់នោះ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ សរុបមកវិញ នៅក្នុងចំណុចនត្ថិភាពនៃបទល្មើសនេះ ព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការបាន លុះត្រាតែព្រះរាជអាជ្ញាយល់ឃើញថា បទល្មើសដែលបានប្រព្រឹត្តនោះចូលក្នុងចំណុច អវត្តមាននៃបទល្មើស ឬក៏ ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់ ។ យ៉ាណាមិញ បន្ទាប់ពីបានបកស្រាយចំណុច(១) "នត្ថិភាពនៃបទល្មើស" រួចរាល់ យើងខ្ញុំនឹងឈានចូលទៅដល់ "មូលហេតុគតិយុត្តិ" នៅចំណុច(២) ។ តើមូលហេតុគតិយុត្តិសំខាន់ណាខ្លះ ដែលបណ្តាលឱ្យមានការតំកល់រឿងទុកឥតចាត់ការ ?

**២. មូលហេតុគតិយុត្តិ**

តាមរយៈគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ឬជម្រើសនៃការចោទប្រកាន់ដែលត្រូវផ្តល់ឱ្យព្រះរាជអាជ្ញាតាមរយៈបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើការចោទប្រកាន់បានដោយផ្អែកទៅលើកត្តាផ្សេងៗ តាមរយៈកាលថ្លឹងថ្លែងរបស់ខ្លួន ។ ប៉ុន្តែក្រៅពីមូលហេតុទាំងនេះ ព្រះរាជអាជ្ញាក៏ត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការផងដែរ ប្រសិនណាបើមានមូលហេតុគតិយុត្តិណាមួយដែលច្បាប់តម្រូវឱ្យតម្កល់ទុកឥតចាត់ការ ដោយមូលហេតុគតិយុត្តិទាំងនោះមានដូចជា **ការរំលត់នៃបណ្តឹងអាជ្ញា** និង**មូលហេតុគតិយុត្តិផ្សេងៗទៀត** ។

**ក.ការរំលត់នៃបណ្ដឹងអាជ្ញា**

ប្រសិនណាបើមានមូលហេតុណាមួយនៃការផុតរលត់បណ្ដឹងអាជ្ញាបានកើតឡើង ក្នុងពេលដែលនីតិវិធីបានដំណើរការដល់ដំណាក់កាលអយ្យការ នោះព្រះរាជអាជ្ញាមិនអាចចាប់ផ្ដើមធ្វើការចោទប្រកាន់បានទៀតទេ គឺត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការតាមរយៈដីការតម្កល់រឿងទុកឥតចាត់ការ ។ ហើយក្នុងករណីព្រះរាជអាជ្ញាបានចោទប្រកាន់រួចហើយក៏ដោយ នីតិវិធីនៅគ្រប់ដំណាក់កាលនៅតែបញ្ចប់ ។ មូលហេតុដែលនាំឱ្យមានកាលរំលត់នៃបណ្ដឹងអាជ្ញាជា៖ មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាស្រ្តករណ៍នៃក្រមព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ ។ ក្រៅពីមូលហេតុខាងលើ ក៏មានមូលហេតុផ្សេងទៀតដែលនាំឱ្យបណ្ដឹងអាជ្ញារលត់ផងដែរ កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ មូលហេតុទាំងនោះមានដូចជា ការសម្របសម្រួលជាមួយរដ្ឋ ការដកពាក្យបណ្ដឹង នៅក្នុងករណីដែលពាក្យបណ្ដឹងនោះជាលក្ខខណ្ឌចាំបាច់នៃការចោទជាបទល្មើសព្រហ្មទណ្ឌ និងដោយការបង់ប្រាក់ពិន័យ គឺប្រាក់ពិន័យសម្របសម្រួល ។ ការផុតរលត់បណ្ដឹងអាជ្ញាមានដូចជា ៖ មរណភាពនៃជនល្មើស(A), ការផុតអាជ្ញាយុកាល(B), ការលើកលែងទោសជាទូទៅ(C), និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ(D), អាជ្ញាអស់ជំនុំ(E), ការសម្របសម្រួលជាមួយរដ្ឋ(F), ការដកពាក្យបណ្ដឹងដោយជនរងគ្រោះ(G), និងការបង់ប្រាក់ពិន័យសរុប ឬការបង់ប្រាក់ពិន័យសម្របសម្រួល(H) ។

A.**មរណភាពនៃជនល្មើស**

មរណភាពនៃជនល្មើស គឺសំដៅទៅលើមរណភាពរបស់បុគ្គលដែលត្រូវចាត់ទុកថាជាជនដែលបានប្រព្រឹត្តបទល្មើស ឬសង្ស័យថាបានប្រព្រឹត្តដែលអាចជាជនជាប់ចោទ ឬជនត្រូវចោទ កំពុងតែស្ថិតនៅក្នុងនីតិវិធីណាមួយរបស់តុលាការ ។ កាលណាបើជនល្មើសបានទទួលមរណភាពហើយនោះ ជាធម្មតាជននោះមិនត្រូវបានកំណត់ជាប្រធាននៃនីតិក្នុងការទទួលយកសិទ្ធិ និងកាតព្វកិច្ចទៀតទេ ។ ម្យ៉ាងទៀត បើផ្អែកទៅលើគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ មានន័យថា គ្មានបុគ្គលណាក្រៅពីជនល្មើសដែលអាចទទួលចំពោះជនល្មើសបានឡើយ ហើយបើជនល្មើសបានទទួលមរណភាពទៅហើយនោះ ពុំមានបុគ្គលណាទទួលខុសត្រូវព្រហ្មទណ្ឌទៀតទេ ។ បន្ថែមពីលើនេះទៅទៀត ចំពោះរឿងព្រហ្មទណ្ឌការដាក់ទណ្ឌកម្ម គឺដើម្បីអប់រំកែប្រែដើម្បីឱ្យជនល្មើសចូលមកក្នុងសង្គមឡើងវិញ និងដើម្បីបង្ហាញឱ្យជនដទៃទៀតខ្លាចរអាក្នុងការប្រព្រឹត្តបទល្មើស មិនមែនក្នុងគោលបំណងសងសឹកនោះទេ ។ ហើយច្បាប់កម្ពុជាក៏មិនបានបញ្ញត្តិអំពីទោស ដែលប្រើប្រាស់ចំពោះសាកសពផងដែរ ព្រោះវាជារឿងមិនមានប្រយោជន៍និងមិនអាចទៅកើតនោះទេ មិនតែប៉ុណ្ណោះមហាជនអាចយល់ថាជាអំពើឃោរឃៅ និងអមនុស្សធម៌ទៀតផង ។ នេះដោយផ្អែកទៅតាមអំណះអំណាងខាងលើ មរណភាពនៃជនល្មើស គឺជាមូលហេតុដែលត្រឹមត្រូវមួយ ដោយអាចធ្វើឱ្យព្រះរាជអាជ្ញាសម្រេចមិនចោទប្រកាន់តាមរយៈដីការតម្កល់រឿងទុកឥតចាត់ការ ។

B.**ការផុតអាជ្ញាយុកាល**

យើងពិនិត្យមើលថាអាជ្ញាយុកាលនៅក្នុងរឿងព្រហ្មទណ្ឌ នៅក្នុងក្រមនីតិវិធិបានបញ្ញត្តិពីរគឺ អាជ្ញាយុកាលនៃបទល្មើស និងអាជ្ញាយុកាលនៃទោស ។ ចំពោះការផុតអាជ្ញាយុកាលត្រង់ចំណុចនេះ គឺសំដៅដល់អាជ្ញាយុកាលនៃបទល្មើសដែលជារយៈពេលកំណត់ក្នុងបណ្តឹងអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌណាមួយបន្ទាប់ពីបានប្រព្រឹត្តរួចដល់ថេរវេលាអាជ្ញាយុកាលនៃបទល្មើសនោះមានភាពខុសគ្នាទៅតាមប្រភេទបទល្មើសដែលត្រូវបានបែងចែកតាមរយៈទម្ងន់នៃបទល្មើសដែលមានដូចតទៅនេះ៖ ១៥ឆ្នាំចំពោះបទឧក្រិដ្ឋ ៥ឆ្នាំចំពោះបទមជ្ឈឹម និង១ឆ្នាំចំពោះបទលហុ ។ ប៉ុន្តែអាជ្ញាយុកាលខាងលើ មិនលើយកមកអនុវត្តឡើយចំពោះបទឧក្រិដ្ឋមួយចំនួន ដូចជាបទឧក្រិដ្ឋប្រល័យពូជសាស្ត្រ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម ប្រសិនណាបើថេរវាលាខាងលើត្រូវបានកន្លងផុត នោះការធ្វើបណ្តឹងអាជ្ញាដោយព្រះរាជអាជ្ញាក៏មិនអាចប្រព្រឹត្តទៅរួចដែរ ដូច្នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

C.**ការលើកលែងទោសជាទូទៅ**

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។ ការលើកលែងទោសជាទូទៅនេះមានអានុភាពលុបចោលនៅទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការលើកលេងទោសជាទូទៅ ហើយទោសមិនអាចយកមកអនុវត្តទេ ឯទោសដែលកំពុងអនុវត្តក៏ត្រូវបានបញ្ចប់ ។ ប៉ុន្តែចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តី ដែលបានបង់រួចហើយមិនអាចទារសំណងពីរដ្ឋវិញបានទេ ។ តាមរយៈន័យនេះ និយាយយ៉ាងខ្លីថាការលើកលែងទោសជាទូទៅមានគោលបំណងដកចេញនៅទណ្ឌកម្មទាំងឡាយ ដែលត្រូវអនុវត្តចំពោះជនល្មើស ដែលបានប្រព្រឹត្តបទល្មើស រីឯបណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឱ្យឃើញពីពិរុទ្ធភាពនៃជនល្មើសនិងផ្តន្ទាទោសជនល្មើសតាមច្បាប់កំណត់ ដូចនេះបណ្តឹងអាជ្ញាត្រូវបានធ្វើឡើងចាប់ពីចំណុចចាប់ផ្តើមដែលកើតឡើងដោយព្រះរាជអាជ្ញារហូតដល់គោលដៅចុងក្រោយ គឺធ្វើការផ្តន្ទាទោសចំពោះជនដែលបានប្រព្រឹត្តបទល្មើស ប៉ុន្តែច្បាប់ស្តីពីការលើកលែងទោសទូទៅ វាមានអានុភាពលុបបំបាត់នៅទណ្ឌកម្មដែលពាក់ព័ន្ធទៅវិញ ដែលធ្វើឱ្យការផ្តន្ទាទោសចំពោះជនល្មើសមិនអាចប្រព្រឹត្តទៅបាន ហើយបើការផ្តន្ទាទោសមិនអាចប្រព្រឹត្តទៅបាន នោះនាំឱ្យការចោទប្រកាន់ដែលជាចំណុចចាប់ផ្តើមនោះក៏គ្មានន័យដែរ ព្រោះវាផ្ទុយអំពីគោលបំណងចុងក្រោយនៃបណ្តឹងអាជ្ញា ។ ដូចនេះ ទើបការផ្តន្ទាទោសជាទូទៅត្រូវបានច្បាប់បញ្ញត្តិជាមូលហេតុនៃការផុតរលត់នៃបណ្តឹងអាជ្ញាដែលតម្រូវឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

D.**និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ**

អ្វីទៅដែលហៅថា និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ? និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ វាគឺជាការចោទប្រកាន់ ជាការច្រានចោលនៃបទបញ្ញាត្តិរបស់ច្បាប់ព្រហ្មទណ្ឌចាស់ ដែលផ្ទុយនឹងបទបញ្ញាត្តិនៃច្បាប់ព្រហ្មទណ្ឌថ្មី មានន័យ

ថានៅពេលដែលច្បាប់ព្រហ្មទណ្ឌថ្មីចូលជាធរមាន វាមានអានុភាពអនុវត្ត នេះជាការពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលសុទ្ធសាធ ។ ច្បាប់ដែលកំណត់អំពីអំពើមួយជាបទល្មើស លុះត្រាតែច្បាប់នោះនៅមានជាធរមានទើបមានអានុភាពអនុវត្ត ដោយសារច្បាប់ចាស់ត្រូវបាននិរាករណ៍ដោយច្បាប់ថ្មី ហេតុដូចនេះជាគោលការណ៍ អំពើដែលច្បាប់មុនបានកំណត់ថាជាបទល្មើស ហើយត្រូវបានច្បាប់ថ្មីបដិសេធអំពើនោះ អំពើនោះមិនអាចត្រូវចោទប្រកាន់ទៀតទេ ។ អានុភាពនៃបញ្ញត្តិថ្មីដែលលុបចោលបទល្មើសនេះ មិនត្រឹមតែហាមមិនឱ្យចោទប្រកាន់ទេតែថែមទាំងកំណត់ថា រាល់ការចោទប្រកាន់ដែលកំពុងតែប្រព្រឹត្តក៏ត្រូវបានបញ្ចប់ ហើយបើមានការប្រកាសទោសរួចហើយ ការផ្តន្ទាទោសនោះមិនត្រូវបាន អនុវត្តទេ ឬត្រូវបញ្ឈប់តែម្តង ។

E.**អាជ្ញាអស់ជំនុំ**

ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលតុលាការស្រេចឱ្យរួចខ្លួនជាស្ថាពរ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ ។ តាមរយៈគោលការណ៍នេះ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ទៅលើជនដែលមានសាលក្រមស្ថាពរតុលាការសម្រេចឱ្យរួចខ្លួនទៅហើយនោះ ទោះបីព្រះរាជអាជ្ញាធ្វើការកំណត់ឈ្មោះបទល្មើសថ្មីលើអង្គហេតុចាស់ក៏ដោយ ។ ប៉ុន្តែចំពោះដីការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ពុំមានអានុភាពនាំឱ្យមានអាជ្ញាអស់ជំនុំទេ ដូចនេះមានន័យថា ប្រសិនបើព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះអង្គហេតុណាមួយ ក្រោយមកទើបរកឃើញថាអង្គហេតុនោះជាបទល្មើសព្រហ្មទណ្ឌ ដូចច្នោះព្រះរាជអាជ្ញាអាចយកអង្គហេតុនោះមកធ្វើការចោទប្រកាន់សារជាថ្មីបាន ។

F.**ការសម្របសម្រួលជាមួយរដ្ឋ**

ការសម្របសម្រួលជាមួយរដ្ឋមានន័យដូចម្តេច? ការសម្របសម្រួលជាមួយរដ្ឋ គឺជាមូលហេតុដែលនាំឱ្យមិនមានការចោទប្រកាន់តាមរយៈការតម្កល់រឿតទុកឥតចាត់ការ ប៉ុន្តែវាអាចធ្វើទៅបានលុះត្រាតែមានច្បាប់ដោយឡែក ដែលអនុញ្ញាតឱ្យមានការសម្របសម្រួលបាន ជាទូទៅការសម្របសម្រួលនេះអាចធ្វើទៅបានលុះត្រាតែអំពើនោះ មិនធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ ទទួលស្គាល់កំហុស និងបានសន្យាណាមួយ ។ ប៉ុន្តែគួរកត់សម្គាល់ផងដែរថា ការសម្របសម្រួលរវាងជនរងគ្រោះនឹងជនល្មើស តាមរយៈការជួសជុលសំណងការខូចខាត សំណងជំងឺចិត្ត មិននាំឱ្យមានការផុតរលត់នៅបណ្តឹងនោះទេ វាអាចរលត់ត្រឹមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ។ ការសម្របសម្រួលជាមួយរដ្ឋនេះ សង្កេតឃើញថា មានការព្រមានជាលាយលក្ខណ៍អក្សរជាដើម ។ ចំពោះការដកពាក្យបណ្តឹង តើការដកពាក្យបណ្តឹងនេះវាមានអត្ថន័យយ៉ាងដូចម្តេច?

G.**ការដកពាក្យបណ្តឹងដោយជនរងគ្រោះ**

អាចធ្វើទៅបានចំពោះបទល្មើសមួយចំនួនដែលច្បាប់ដោយឡែកបានចែងដាក់លាក់ ហើយពាក្យបណ្ដឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់បទបញ្ញត្តិច្បាប់ជាធរមានមួយចំនួន ដែលបានអនុញ្ញាតឱ្យជនរងគ្រោះធ្វើការដកពាក្យបណ្ដឹង ។ ឧទាហរណ៍ ៖ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះតាមរយៈមាត្រា៣៦ ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជន ដោយបទល្មើសនោះជាបទល្មើសមជ្ឈឹមស្រាល ឬលហុ ។ តាមរយៈន័យនេះ បើមានសំណើពីជនរងគ្រោះដើម្បីកុំឱ្យមានការចោទប្រកាន់ នោះព្រះរាជអាជ្ញានឹងមិនធ្វើការចោទប្រកាន់ ចំពោះបទលហុឬមជ្ឈឹមស្រាលនោះឡើយ ។ ដោយសំណើរនេះត្រូវចាត់ទុកជាការដកពាក្យបណ្ដឹង បើសិនមានការចោទប្រកាន់រួចដែលនាំឱ្យបណ្ដឹងអាជ្ញាត្រូវរលត់ ។

H.**ការបង់ប្រាក់ពិន័យសរុប ឬការបង់ប្រាក់ពិន័យសម្របសម្រួល**

បើយើងពិនិត្យមើលមានបទល្មើសមួយចំនួន អាចបញ្ចប់បានដោយមិនចាំបាច់ធ្វើបណ្ដឹងអាជ្ញា ឬការចោទប្រកាន់ទេ គឺគ្រាន់តែបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួលតែប៉ុណ្ណោះ ។ ករណីភាគច្រើនយើងឃើញមានអនុវត្តចំពោះបទល្មើសចរាចរណ៍ ឧទាហរណ៍៖ នៅក្នុងមាត្រា ៦៥ ច្បាប់ចរាចរណ៍ផ្លូវគោកឆ្នាំ២០១៥ បទល្មើសចរាចរណ៍ ដែលត្រូវផ្ដន្ទាទោសពិន័យអន្តរកាល ជាសមត្ថកិច្ចរបស់នគរបាលចរាចរណ៍ផ្លូវគោក មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ត្រូវសម្របសម្រួលក្នុងករណីមានគ្រោះថ្នាក់ដោយសងលើសំណងដែលបង្កការខូចខាតដូចនេះ ចំពោះបទល្មើសដែលត្រូវផ្ដន្ទាទោសពិន័យអន្តរកាលអាចអនុញ្ញាតឱ្យអ្នកប្រព្រឹត្តរួចផុតពីបណ្ដឹងអាជ្ញាតាមរយៈការបង់ប្រាក់ពិន័យ ។

ក្រៅពីការរំលត់នៃបណ្ដឹងអាជ្ញា យើងសង្កេតឃើញថាមានមូលហេតុគតិយុត្តផ្សេងទៀតដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលវាជាកត្តាមួយនាំឱ្យព្រះរាជអាជ្ញាធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការបាន ។ តើមូលហេតុគតិយុត្តអ្វីខ្លះទៅ ទើបបណ្ដាលឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការនោះ?

**ខ.មូលហេតុគតិយុត្តផ្សេងទៀត**

មូលហេតុគតិយុត្ត ដែលបណ្ដាលឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការនដូចជា៖ **អភ័យឯកសិទ្ធិ អនិយ័តភាពនៃនីតិវិធី ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស** យើងខ្ញុំនឹងធ្វើការលើកយកចំណុចដែលបានរៀបរាប់ខាងលើមកអធិប្បាយឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ។

A.**អភ័យឯកសិទ្ធ**

អ្វីទៅជាអភ័យឯកសិទ្ធិ? អភ័យឯកសិទ្ធិមានន័យថា ជាសិទ្ធិរបស់បុគ្គលណាមួយដែលច្បាប់ផ្ដល់ឱ្យអំពីលក្ខខណ្ឌពិសេសទាក់ទងទៅនឹងកិច្ចនីតិវិធី ការទទួលខុសត្រូវ ឬអំពីការទទួលបាននូវស្ថានសម្រាលចំពោះអំពើល្មើសណាមួយ ។ តាមរយៈបទបញ្ញត្តិនានារបស់ប្រទេសកម្ពុជា គោលការណ៍នៃអភ័យឯកសិទ្ធិនេះ ត្រូវបានផ្ដល់

ឱ្យបុគ្គលមួយចំនួនប៉ុណ្ណោះ បុគ្គលទាំងអស់នោះមានដូចជា ព្រះមហាក្សត្រ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា តំណាងទូត និងអភ័យឯកសិទ្ធិគ្រួសារចំពោះបទល្មើសលួច ។ ដូចច្នោះ បុគ្គលដែលមានអភ័យឯកសិទ្ធិទាំងនេះ មិនអាចត្រូវបានចោទប្រកាន់បានទេ ដែលតម្រូវឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

B.**អនិយ័តភាពនៃនីតិវិធី**

បើពិនិត្យទៅលើមូលហេតុជាច្រើន អនិយ័តភាពនៃនីតិវិធី វាជាមូលហេតុមូលដែលធ្វើឱ្យព្រះរាជអាជ្ញាលើយកមកធ្វើជាសំអាងមិនធ្វើការចោទប្រកាន់តាមរយៈតាមដីសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ អនិយ័តភាពគឺសំដៅដល់ភាពមិនស្របច្បាប់នៃនីតិវិធី ក្នុងដំណើរប្រតិបត្តិការរបស់ព្រះរាជអាជ្ញាឬនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេត ឬស្រាវជ្រាវបន្ថែមរបស់នគរបាលយុត្តិធម៌ហើយនោះ ប្រតិបត្តិការនេះហាក់ដូចជាមិនស្របតាមនីតិវិធី និងមិនបានលទ្ធផល ឬគ្មានប្រយោជន៍ទេ ព្រោះព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការដោយមូលហេតុអនិយ័តភាពនៃនីតិវិធី ។

C.**ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនល្មើស**

ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ សំដៅទៅដល់ការរួចផុតអំពីទោសទណ្ឌរបស់អ្នកប្រព្រឹត្តបទល្មើសនោះ ។ ដោយមូលហេតុ ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ដោយច្បាប់ត្រូវបានពិចារណាដោយពិនិត្យទៅលើ កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ឬបុគ្គលិកលក្ខណៈរបស់ជនល្មើសដែលអាចតម្រូវឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ។ តាមរយៈក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១០ មូលហេតុដែលនាំឱ្យមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌមានដូចជា៖ វិបល្លាសស្មារតី ការអនុញ្ញាតដោយច្បាប់ឬអាជ្ញាធរ ការការពារស្របច្បាប់ សច្ចធានៃការការពារខ្លួនស្របច្បាប់ ស្ថានភាពចាំបាច់ អានុភាពនៃកំលាំងឬការបង្ខិតបង្ខំ ជនល្មើសជាអនីតិជនអាយុក្រោម១៨ឆ្នាំ .ល. ជនទាំងអស់ដែលបានរៀបរាប់ខាងលើនឹងត្រូវបានរួចផុតពិការទទួលខុសត្រូវព្រហ្មទណ្ឌ ។

**វិបល្លាសស្មារតី៖** សំដៅលើជនណាម្នាក់នៅពេលដែលប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតស្មារតីមួយដែលធ្វើឱ្យមានភាពវឹកវរ ដែលធ្វើឱ្យមានការបាត់បង់នូវការទទួលដឹងខុសត្រូវរបស់ខ្លួនជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ប៉ុន្តែបើការកើតវិបល្លាស្មារតីនោះ វាបណ្តាលបន្ថយនៅការយល់ដឹងខុសត្រូវឬវាកើតឡើងដោយសារការប្រើប្រាស់គ្រឿងស្រវឹង សារធាតុញៀនឬសារធាតុដែលច្បាប់ហាមឃាត់ នោះជននោះមិនអាចរួចផុតពិការទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

**ការអនុញ្ញាតដោយច្បាប់ឬអាជ្ញាធរ៖** មានន័យថាអំពើដែលអនុញ្ញាត្តដោយច្បាប់នោះ ឬបទបញ្ញត្តិនានាដែលបញ្ជាដោយអាជ្ញាធរស្របច្បាប់ទោះបីបង្កឱ្យមានការបទល្មើសកើតឡើងក៏ដោយ ក៏រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ លើកលែងតែពាក់ព័ន្ធបទល្មើសប្រល័យពូជសាសន៍

បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋសង្គ្រាម នឹងអំពើខុសច្បាប់ជាក់ច្បាស់ណាមួយ ។

**ការការពារស្របច្បាប់៖** គឺជាការប្រព្រឹត្តល្មើសក្នុងស្ថានភាពការពារខ្លួនស្របច្បាប់ នោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេប៉ុន្តែលុះត្រាតែការការពារខ្លួនស្របច្បាប់នោះបំពេញនៅ លក្ខខណ្ឌ ៣ គឺ៖

១.ភាពចាំបាច់ដើម្បីការពារខ្លួន អ្នកដទៃឬទ្រព្យសម្បត្តិ ដែលប្រឈមនឹងការឈ្លានពាន ។

២.អំពើល្មើសនឹងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា។

៣.គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនឹងទម្ងន់នៃការឈ្លានពាន ។

**សច្ចធានៃការការពារខ្លួនស្របច្បាប់៖** ត្រូវសន្មតថាជាការការពារខ្លួនស្របច្បាប់ ប្រសិនណាបើបទល្មើសត្រូវបានប្រព្រឹត្តដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុសទម្លាយ ដោយហិង្សា ដោយកលល្បិចក្នុងទីកន្លែងដែលមានមនុស្សនៅ ប្រព្រឹត្តដើម្បីប្រឆាំងនឹងការលួច ការប្លន់ដែលអនុវត្តដោយហិង្សា ។

**ស្ថានភាពចាំបាច់៖** ស្ថានភាពចាំបាច់នេះ ក៏រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌ២គឺ៖

១.ស្ថានភាពចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិដែលប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតឡើង ឬដែលនឹងកើតមានឡើង ។

២.គ្មានសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់ ។

**អានុភាពនៃកម្លាំង ឬការបង្ខំ៖** គឺជាការប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង និងការបង្ខំដែលមិនអាចទប់ទល់បាន បុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ បើនិយាយពីកម្លាំង និងការបង្ខំអាចចេញពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ហើយមិនអាចឃើញជាមុន និងមិនអាចជៀសវាងបាន ។

**អនីតិជនក្រោម១៤ ៖** មានន័យថាបើអ្នកប្រព្រឹត្តអំពើនោះមានអាយុតិចជាង១៤ឆ្នាំ គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ប៉ុន្តែបើអនីតិជនអាយុ១៤ឆ្នាំឡើងទៅ ក្រោម១៨ឆ្នាំ គឺនៅតែត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ។

សរុបជារួមមក ថ្វីត្បិតតែអំពើខាងលើប្រព្រឹត្តជាបទល្មើសពិតមែន ច្បាប់បានបញ្ញត្តិថា អំពើទាំងអស់នោះជាអំពើយុត្តកម្ម ដែលតម្រូវឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុនេះ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បានដែរ ដោយសម្រេចតម្កល់ទុកឥតចាត់ការ ។ ចុះចំណែកនៅក្នុងចំណុចការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍ឯនោះវិញ មានមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យមានការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍?

### ៣.ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

បើសិនណាយើងពិនិត្យមើលអំពីអំពើដែលប្រព្រឹត្ត គឺជាបទល្មើសក្តី ប៉ុន្តែព្រះរាជអាជ្ញាអាចធ្វើការថ្លឹងថ្លែងថាគួរចោទប្រកាន់ឬតម្កល់រឿងទុកឥតចាត់ការ ។ ជាទូទៅកម្មវត្ថុនៃការចោទប្រកាន់ គឺជាការទាមទារឱ្យជនល្មើសមកទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌ មិនតែប៉ុណ្ណោះក៏ចាំបាច់ផងដែរចំពោះការធានាដល់សិទ្ធិជនរងគ្រោះក្នុងបទល្មើសនោះដើម្បីទទួលបាននៅសំណងព្យសនៈកម្ម ពីអំពើល្មើសរបស់ជនល្មើស ដែលប្រព្រឹត្តមកលើខ្លួន ។ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងមើលទៅឃើញថា ការចោទប្រកាន់នោះហាក់ដូចជាមិនផ្តល់ផលប្រយោជន៍ទាំងអស់ ដូចច្នោះការចោទប្រកាន់ក៏ពុំអាចមានន័យអ្វីដែរ ដោយមូលហេតុធ្វើឱ្យការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍វាអាចបណ្តាលមកពីមូលហេតុជាច្រើន ។

មូលហេតុដែលបណ្តាលឱ្យការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍ អាចមកពីមូលហេតុផ្សេងៗដូចជា៖

- ការស្វែងរកមិនបានផលប្រយោជន៍
- ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង
- ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនៅការនូវការដឹងខុសត្រូវរបស់ជនល្មើស
- ការខកខានរបស់ដើមបណ្តឹង
- អាកប្បកិរិយារបស់ជនរងគ្រោះ
- ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស
- ព្យសនៈកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស ជាអាទិ៍ ។

សរុបមក ការចោទប្រកាន់វាមិនបានផ្តល់ផលប្រយោជន៍ សំដៅដល់ការចោទប្រកាន់ដែលធ្វើឡើងនាំឱ្យខូចខាតពេលវេលា មិនបានផ្តល់ផលប្រយោជន៍សម្រាប់ជនរងគ្រោះ ឬដើមបណ្តឹង និងមិនបានផ្តល់ផលប្រយោជន៍ជាសាធារណៈ ហើយមិនហាក់មិនអាចសម្រេចនៅកម្មវត្ថុនៃការចោទប្រកាន់ ដូចច្នោះ វានឹងក្លាយជាកម្មវត្ថុនៃការមិនពិចារណាលើការចោទប្រកាន់ ដែលនាំឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

## កថាខណ្ឌទី២៖ នីតិវិធី ទម្រង់ និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

### ១.នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

ជាបឋមព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹង ដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ប្រសិនណាបើ ព្រះរាជអាជ្ញាសម្រេចមិនចោទប្រកាន់ទៅលើបណ្តឹង ឬពាក្យបរិហាដែលខ្លួនបានទទួលនោះទេ ព្រះរាជអាជ្ញាត្រូវចេញសេចក្តីសម្រេចមួយ ទៅតាមរយៈដីការតម្កល់រឿងទុកឥតចាត់ការ ។ បន្ទាប់ពីនោះ ព្រះរាជអាជ្ញាត្រូវផ្តលដំណឹងដល់អ្នកប្តឹង អំពីសេចក្តីសម្រេចរបស់ខ្លួននៅក្នុងរយៈពេលមួយយ៉ាងខ្លីបំផុតតែយ៉ាងយូររយៈពេល២ខែគិតចាប់ពីថ្ងៃចុះពាក្យបណ្តឹងក្នុងបញ្ជី មានន័យថានៅពេលដែលព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវផ្តល់ដំណឹងដល់អ្នកប្តឹង ដែលអ្នកប្តឹងត្រង់ចំនុចនេះសំដៅដល់

ជនរងគ្រោះ អ្នកតំណាងស្របច្បាប់ និងសិទ្ធិវ៉នរបស់ជនរងគ្រោះ ហើយការជូនដំណឹងនេះត្រូវធ្វើឡើងតាមរយៈលិខិតជូនដំណឹង ។ ចំពោះការជូនដំណឹងដែលធ្វើឡើងត្រូវតែគោរពនូវសិទ្ធិរបស់អ្នកប្តឹង ដើម្បីឱ្យគេបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ដែលបានសម្រេចប្តឹងរបស់ខ្លួន ហើយក៏ដើម្បីធានានូវសិទ្ធិរបស់អ្នកប្តឹងទៅនឹងការតវ៉ាទៅនឹងសេចក្តីសម្រេចនេះផងដែរ ។ រីឯរយៈពេលនៃការអោយដំណឹង ត្រូវធ្វើក្នុងរយៈពេលយ៉ាងខ្លីបំផុតហើយ យ៉ាងយូរបំផុតរយៈពេល២ខែ គិតចាប់ពីថ្ងៃចុះពាក្យប្តឹងនៅក្នុងបញ្ជី ដូចនេះមានន័យថា ការឱ្យដំណឹងកាន់តែឆាប់គឺកាន់តែល្អសម្រាប់អ្នកប្តឹង ដើម្បីឱ្យគាត់បានទទួលដំណឹងបានលឿន ដែលនាំឱ្យមិនអាចអូសបន្លាយពេលវេលាយូសម្រាប់គាត់ ការសម្រេចចិត្តទទួលយកសេចក្តីសម្រេច ឬតវ៉ាទៅនឹងសេចក្តីសម្រេចនោះ ហើយរយៈពេលឱ្យដំណឹងនេះបើមិនអាចធ្វើឡើងឱ្យឆាប់រហ័សទេ គឺមិនអាចឱ្យលើសពីរយៈពេលពីរខែដែរ ដោយរយៈពេលខាងលើ គឺគិតចាប់ពីថ្ងៃចុះពាក្យប្តឹងដែលចុះក្នុងបញ្ជី ដែលបញ្ជីនោះជាបញ្ជីអយ្យការសម្រាប់ចុះប្តឹងនៅក្នុងសាលាជាន់ដំបូងនីមួយៗ ។ ដែលស្ថិតនៅក្រោមការកាន់កាប់របស់លេខាធិការដ្ឋានអយ្យការ អង្គការត្រួយពិនិត្យរបស់អយ្យការផ្ទាល់ ។

**២.ទម្រង់ការនៃការតម្កល់រឿងទុកឥតចាត់ការ**

ចំពោះរឿងទុកឥតចាត់ការវាត្រូវធ្វើឡើងតាមរយៈដីការតម្កល់រឿងទុកឥតចាត់ការ ទម្រង់នៃដីការតម្កល់រឿងទុកឥតចាត់ការគឺសំដៅដល់ធាតុទាំងឡាយ ដែលមានចែងក្នុងដីការតម្កល់រឿងទុកឥតចាត់ការ ដែលតម្រូវឱ្យមានដើម្បីឱ្យដីការនោះត្រឹមត្រូវ ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ពុំមានការកំណត់ទម្រង់ការនៃការតម្កល់រឿងទុកឥតចាត់ការច្បាស់លាស់នោះទេ ប៉ុន្តែគ្រាន់តែបញ្ញត្តិថា ការតម្កល់រឿងទុកឥតចាត់ការត្រូវតែមានសំអាងហេតុនិងសំអាងច្បាប់ តាមន័យនេះដីការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងហេតុនិងសំអាងច្បាប់ដែលជាលក្ខខណ្ឌដែលមិនអាចខ្វះបាន ដូចច្នេះ យើងត្រូវយល់ជាមុនសិនថាអ្វីទៅសំអាងហេតុ និងសំអាងច្បាប់? សំអាងហេតុគឺសំដៅទៅដល់ ការលើកយកនៅអង្គហេតុទាំងឡាយដែលពាក់ព័ន្ធមកធ្វើជាសំអាង ដែលជាមូលហេតុដែលនាំឱ្យមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ រីឯសំអាងច្បាប់ គឺជាការលើកយកនូវអត្ថបទច្បាប់ដែលគ្រាំទ្រដល់អង្គហាតុ និងជាមូលហេតុដែលធ្វើឱ្យមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

**៣.អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ**

បើព្រះរាជអាជ្ញាអនុវត្តទៅតាមនីតិវិធី និងទៅតាមទម្រង់នៃដីការតម្កល់រឿងទុកឥតចាត់ការរួចហើយ តើដីការនោះវាមានអានុភាពយ៉ាងមិចទៀត? ការតម្កល់រឿងទុកឥតចាត់ការវាគ្មាអាជ្ញាអស់ជំនុំទេ គោលការណ៍អាជ្ញាអស់ជំនុំគឺជនណាជនណាដែលត្រូវតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែលទោះបី ក្រោមការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ ប៉ុន្តែការតម្កល់រឿងទុកឥតចាត់ការមិនបានបង្កើតឱ្យមានអាជ្ញាអស់ជំនុំនោះទេ មានន័យថាប្រសិនណាបើព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ

ចំពោះជនណារួចហើយ មិនមែនមានន័យថាជននោះរួចខ្លួនពីការចោទប្រកាន់ជាស្ថាពរនោះទេ ក្នុងករណីដែលលេចឡើង ឬក៏ព្រះរាជអាជ្ញាទទួលបាននូវភស្តុតាងដើម្បីដាក់បន្ទុកក្នុងការចោទប្រកាន់បាននោះ ព្រះរាជអាជ្ញាអាចលើកយករឿងនោះមកចោទប្រកាន់សាជាថ្មីបាន ។ ការអនុវត្តភាពគ្មានអាជ្ញាអស់ជំនុំនេះ ព្រោះការសម្រេចចោទប្រកាន់និងការសម្រេចតម្កល់រឿងទុកឥតចាត់ការ ជាការសម្រេចមួយដោយឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញា មានន័យថា នីតិវិធីនេះគឺផ្តោតសំខាន់ទៅលើការយល់ឃើញរបស់ព្រះរាជអាជ្ញា ដូចនេះវាបានដល់ការធានាសិទ្ធិរបស់ជនរងគ្រោះ នៃអំពើល្មើសចំពោះការសើរើឡើងវិញ ចំពោះការសម្រេចសេចក្តីរបស់ព្រះរាជអាជ្ញា នៅពេលដែលព្រះរាជអាជ្ញាសម្រេចដោយមានការខុសឆ្គង ឬចន្លោះប្រហោងត្រង់ចំណុចណាមួយ ជារួមការកំណត់អំពីអាជ្ញាអស់ជំនុំ មិនអាចស្តែងឡើងបានទេដោយគ្រាន់តែមានការយល់ឃើញរបស់ព្រះរាជអាជ្ញា ហើយភាពគ្មានអាជ្ញាអស់ជំនុំនាំឱ្យព្រះរាជអាជ្ញាអាចសម្រេចចោទប្រកាន់សារជាថ្មី លើអង្គហេតុដដែលនៅពេលដែលខ្លួនយល់ឃើញថា អង្គហេតុនោះបានបង្កើតជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែលើកលែងតែមានការផុតរលត់បណ្តឹងអាជ្ញា ។

## កថាខណ្ឌទី៣៖ យន្តការជំរុញឱ្យមានការចោទប្រកាន់ឡើងវិញ

ចំពោះការតម្កល់រឿងទុកឥតចាត់ការ វាជានីតិវិធីមួយដែលមានលក្ខខណៈមិនដាច់ខាត ដែលព្រះរាជអាជ្ញាអាចសម្រេចមិនចោទប្រកាន់ជនណាមួយពីបទល្មើសព្រហ្មទណ្ឌ ការសម្រេចមិនចោទប្រកាន់អាចជាការថ្លឹងថ្លែងប្រកបទៅដោយភាពត្រឹមត្រូវ តែក៏អាចជាការខុសឆ្គងលើការសម្រេចមិនចោទប្រកាន់ខាងបទព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញាដែរ ដូចនេះដើម្បីធានាថា ទោះជាមានការតម្កល់រឿងទុកឥតចាត់ការយ៉ាងណាក៏ដោយ ក៏វាត្រូវយកមកដោះស្រាយក្នុងយន្តការបន្តលើចំណាត់ការនេះ ដោយយន្តការទាំងនោះត្រូវធ្វើឡើងតាមរយៈ **ការសើរើកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា(១) បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍(២) អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ(៣) និងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ(៤)** ដូចនេះ យើងខ្ញុំនឹងធ្វើការពន្យល់នៅក្នុងចំណុចនីមួយៗដូចខាងក្រោមនេះ ។

### ១.ការសើរើកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា

ប្រសិនណាបើព្រះរាជអាជ្ញា បានសម្រេចតម្កល់រឿងទុកឥតចាត់ការ ហើយពុំមានការតវ៉ាតាមរយៈយន្តការណាមួយធ្វើឡើងចំពោះសេចក្តីសម្រេចនេះទេ សំណុំរឿងព្រហ្មទណ្ឌនោះនឹងត្រូវបញ្ចប់ តែការតម្កល់រឿងទុកឥតចាត់ការ ពុំនាំឱ្យមានអានុភាព អាជ្ញាអស់ជំនុំកើតឡើងទេ ហើយតាមរយៈបញ្ញត្តិក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ទោះបីជាមានការសម្រេចតម្កល់រឿងទុកឥតចាត់ការក៏ដោយ ព្រះរាជអាជ្ញាក៏អាចសើរើ កែប្រែសេចក្តីសម្រេចនោះវិញបាន តែការសើរើកែប្រែនេះ អាចធ្វើក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់តែប៉ុណ្ណោះ មានន័យថា នៅពេលដែលមានការសម្រេចតម្កល់រឿងទុកឥតចាត់ការរួច ព្រះរាជអាជ្ញានៅតែអាចសើរើសំណុំរឿងព្រហ្មទណ្ឌនោះមកចោទប្រកាន់សារឡើងវិញបាន ប៉ុន្តែការចោទប្រកាន់នោះអាចធ្វើទៅបានតែក្នុងករណីបណ្តឹងអាជ្ញាមិនទាន់ផុត

វលត់បានជាមានការអនុញ្ញាតឱ្យមានការកែប្រែសេចក្តីសម្រេចបនេះ ព្រោះព្រះរាជអាជ្ញាធ្វើសេចក្តីសម្រេចចោទប្រកាន់ឬតម្កល់រឿងទុកឥតចាត់ការតាមរយៈការថ្លឹងថ្លែងរបស់ខ្លួន ។ ដូចនេះ ការសម្រេចសេចក្តីអាចមានការខុសឆ្គងដោយការខ្វះចន្លោះត្រង់ប្រការណាមួយ ដែលនាំឱ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការ ត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវ ចំណែកឯមូលហេតុដែលនាំឱ្យមានការសើរើសេចក្តីសម្រេចនោះ អាចបណ្តាលមកពីហេតុការមួយចំនួន ដែលនាំឱ្យព្រះរាជអាជ្ញាយល់ឃើញថា ការសម្រេចតម្កល់ទុកឥតចាត់ការនោះមិនត្រឹមត្រូវ ដូចជា៖ មានអង្គហេតុថ្មីត្រូវបានរកឃើញ មានភស្តុតាងណាមួយដែលបានលេចឡើងដែលអាចនាំឱ្យមានការចោទប្រកាន់ ឬនៅពេលដែលមានភាពចន្លោះប្រហោងណាមួយនៃនីតិវិធី ដែលនាំឱ្យការសម្រេចរបស់ខ្លួនមានភាពមិនត្រឹមត្រូវជាអាទិ៍ ។ ដូចច្នោះ ការបើកផ្លូវឱ្យព្រះរាជអាជ្ញាធ្វើការសើរើកែប្រែសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួននេះ គឺជានីតិវិធីមួយដែលត្រូវបានផ្តល់ឱ្យព្រះរាជអាជ្ញា ក្នុងការបំពេញតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវ ហើយដើម្បីការពារផលប្រយោជន៍របស់ជនរងគ្រោះ នៃអំពើល្មើសឱ្យទទួលបានយុត្តិធម៌ផងដែរ ។

**២.បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

វាគឺជានីតិវិធីមួយ ដែលអនុញ្ញាតឱ្យជនរងគ្រោះអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នៅពេលដែលត្រូវបានសម្រេចតម្កល់រឿងទុកឥតចាត់ការដោយព្រះរាជអាជ្ញា ឬពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវបានកំណត់នូវតួនាទីលើការឃ្លាំមើលការអនុវត្តច្បាប់ សមត្ថកិច្ចដែនដីរបស់ខ្លួន ហើយដោយសារតែតួនាទីនេះ ទើបច្បាប់សម្រេចទទួលយកអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាអ្នកទទួលបណ្តឹងពីជនរងគ្រោះ និងជាអ្នកសម្រេចសេចក្តីលើបណ្តឹងនេះ ចំពោះការធ្វើបណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវធ្វើឡើងក្នុងរយៈពេល២ខែ គិតបីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ មានន័យថា ថេរវាលាខាងលើ គឺគិតចាប់ពីថ្ងៃដែលទទួលបានបណ្តឹងពីក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរហូតដល់២ខែក្រោយ ទើបជនរងគ្រោះអស់សិទ្ធិក្នុងការធ្វើបណ្តឹងតវ៉ានេះ ។ ប៉ុន្តែគួបញ្ជាក់ផងដែរថា ក្នុងករណីដូចមានបញ្ញាត្តិក្នុងមាត្រា៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បណ្តឹងតវ៉ាអាចធ្វើឡើងនៅពេលដែលពាក្យប្តឹងរបស់ជនរងគ្រោះត្រូវបានតម្កល់រឿងទុកឥតចាត់ការ ស្ថិតនោះដោយគ្មានចម្លើយ ដូចនេះប្រសិនណាបើពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយ នោះនាំឱ្យជនរងគ្រោះមិនបានទទួលដំណឹងពីការតម្កល់រឿងទុកឥតចាត់ការដូចគ្នា រយៈពេលប្តឹងតវ៉ាខាងលើមិនអាចប្រើប្រាស់ក្នុងករណីពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយបានទេ ។ រីឯនីតិវិធីនៃការធ្វើបណ្តឹងតវ៉ា ត្រូវធ្វើឡើងដោយបណ្តឹងសាមញ្ញរបស់អ្នកប្តឹងមួយទៅអង្គការអយ្យការដែលពាក់ព័ន្ធ ។ អង្គការអយ្យការដែលពាក់ព័ន្ធនេះ សំដៅលើអង្គការអយ្យការអមសាលាដំបូងទទួលបណ្តឹងលើកទី១ នៅពេលបណ្តឹងត្រូវបានដាក់រួចព្រះរាជអាជ្ញាអមសាលាដំបូងត្រូវបញ្ជូនសំណុំរឿងនេះ មកឱ្យអគ្គ

ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដើម្បីធ្វើការសម្រេច ដោយការសម្រេចសេចក្តីនេះវាមាន២ករណី ៖ ការបដិសេធនឹងសេចក្តីសម្រេច និងការយល់ស្របនឹងសេចក្តីសម្រេច ។

-***ការបដិសេធនឹងសេចក្តីសម្រេច ៖*** បើបណ្តឹងនេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចេញអធិបញ្ញា ដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់ ។ ការអធិបញ្ញា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រោះការចោទប្រកាន់ចាំបាច់ត្រូវតែមាន ហើយព្រះរាជអាជ្ញាត្រូវតែចោទគាត់គ្មានសិទ្ធិអំណាចសម្រេចដោយខ្លួនឯងដូចពីមុននោះទេ ។

-***ការយល់ស្របនឹងសេចក្តីសម្រេច ៖*** នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍សម្រេចតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាទុកជាបានការ ហើយជូនព័ត៌មានអំពីការសម្រេចនេះ ទៅអ្នកប្តឹងឱ្យដឹង ហើយអ្នកប្តឹងមិនអនុញ្ញាតឱ្យធ្វើបណ្តឹងតវ៉ាទៀតទេ ។ ការជូនដំណឹងនេះ ដើម្បីជាឱកាសក្នុងការប្រាប់ នីតិវិធីផ្សេងទៀត ដូចជាការតាំងខ្លួនជាដើម្បីបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។

**៣.អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ**

អ្វីទៅដែលហៅថា អំណាចអធិបញ្ញា ? អំណាចអធិបញ្ញា តាមន័យទូទៅ គឺជាបញ្ជាតាមឋានានុក្រម ពីថ្នាក់លើមកថ្នាក់ក្រោម ដើម្បីឱ្យធ្វើអ្វីមួយ ។ បើយើងពិនិត្យលើមាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ សំដៅដល់ការបញ្ជាតាមឋានានុក្រមឱ្យអង្គការអយ្យការធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌណាមួយ ដោយសមាសភាពរបស់អង្គការអយ្យការក្នុងការធ្វើអធិបញ្ញាមានឋានានុក្រមដូចជា៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ។

- ***រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ៖*** មានមុខនាទីមួយ ជាតំណាងឬជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងវិស័យច្បាប់របស់សង្គមជាតិទាំងមូល ។ ច្បាប់បានផ្តល់អំណាចដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ឱ្យអគ្គព្រះរាជអាជ្ញាឬ ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលគាត់យល់ឃើញថាជាការគួរ ។

- ***អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ៖*** គឺជាអ្នកដែលឃ្លាំមើលការអនុវត្តច្បាប់ សមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន គាត់អាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬចាត់ឱ្យចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ ដូចនេះមានន័យថា អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ធ្វើការចោទប្រកាន់នៅពេលដែលមានការតម្កល់រឿងទុកឥតចាត់ការបានធ្វើឡើង ។

- ***ព្រះរាជអាជ្ញា ៖*** មិនមែនសំដៅទៅលើព្រះរាជអាជ្ញាអមតុលាការកំពូល ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទេ ព្រោះអ្នកទាំងនេះគ្មានអំណាចលើចៅក្រមអយ្យការណាមួយ ក្នុងការប្រើប្រាស់អំណាចអធិបញ្ញាទេ ហេតុនេះព្រះរាជអាជ្ញា គឺសំដៅដល់ព្រះរាជអាជ្ញាអមសាលាដំបូងតែប៉ុណ្ណោះ ។ ព្រះរាជអាជ្ញាមានអំណាចអធិបញ្ញាទៅលើចៅក្រមអយ្យការក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាក៏អាចធ្វើអធិបញ្ញាឱ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្ដីសន្និដ្ឋានតាមដែលខ្លួនយល់ឃើញថាជាការគួរ ដូចនេះមានន័យថាព្រះរាជអាជ្ញាអមសាលាដំបូង អាចធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញារងដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីនៅអមសាលាដំបូងរបស់ខ្លួន ធ្វើការចោទប្រកាន់នៅពេលដែលមានការតម្កល់រឿងទុកឥតចាត់ការបានធ្វើឡើង ។

- ***ព្រះរាជអាជ្ញារង ៖*** គឺជាចៅក្រមអយ្យការនៅអមសាលាដំបូងរាជធានីខេត្ត ដែលមានឋានានុក្រមក្រោមគេព្រះរាជអាជ្ញារងស្ថិតនៅក្រោមអំណាចព្រះរាជអាជ្ញា ប៉ុន្តែអាចប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវនិងការចោទប្រកាន់បទល្មើស ។ ដូចនេះ នៅពេលដែលមានអំណាចអធិបញ្ញា នៅពេលដែលខ្លួនតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញារងត្រូវតែគោរពតាមអំណាចអធិបញ្ញានេះ គួរកត់សម្គាល់ផងដែរថា ការធ្វើអធិបញ្ញាត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ ដាក់បញ្ចូលទៅក្នុងសំណុំរឿង ។ ហើយអំណាចអធិបញ្ញា គឺជាការសម្រេចឱ្យចោទប្រកាន់ មិនមែនជាការបញ្ជាឱ្យតម្កល់រឿងទុកឥតចាត់ការទេ ។ ចៅក្រមអយ្យការគ្រប់រូបត្រូវតែគោរពអធិបញ្ញារបស់ខ្លួនតាមឋានានុក្រម ប៉ុន្តែនៅពេលសវនាការ ចៅក្រមអយ្យការការកត់សម្គាល់ផ្ទាល់មាត់ដោយសេរី កាលដែលខ្លួនយល់ឃើញថា ស្រមទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន ហើយក៏គ្មានការចោទប្រកាន់ខាងវិន័យត្រូវបានធ្វើឡើងចំពោះចៅក្រមអយ្យការ ដោយសារតែវាចាររបស់ខ្លួនពេលសវនការនោះទេដូច្នោះប្រសិនណាបើមានការតម្កល់រឿងទុកឥតចាត់ការត្រូវបានធ្វើឡើង ជនរងគ្រោះអាចជ្រើសរើសយកជម្រើសនេះ ដោយធ្វើការប្ដឹងទៅនាយឋានានុក្រមនៃអយ្យការខាងលើដើម្បីឱ្យធ្វើអធិបញ្ញាដែលនាំឱ្យមានការចោទប្រកាន់ឡើងវិញ ប្រសិនណាបើពួកគាត់យល់ឃើញថារឿងនេះគួរចោទប្រកាន់ ។

### ៤.ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ

ក្រៅពីជម្រើសនៃការដាក់ពាក្យប្ដឹង ឬពាក្យបរិហារទៅមន្ត្រីនគរបាលយុត្តិធម៌ ឬទៅព្រះរាជអាជ្ញាផ្ទាល់ ជនរងគ្រោះនៃបទឧក្រិដ្ឋ បទមជ្ឈឹម អាចដាក់ពាក្យបណ្ដឹងដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី វាមានអានុភាពប្ដឹងដល់ចៅក្រមស៊ើសួរអំពីបណ្ដឹងអាជ្ញាដែលនាំឱ្យមានការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ និងប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ ។ នេះគឺជាយន្តការថ្មីដែលនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ មិនមានទេ ហើយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបញ្ញត្តិចំពោះការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ជាការកត់សម្គាល់ បន្ទាប់មកគឺទាក់ទងទៅនឹងការដាក់ពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ ដូច្នោះ

ពេលដែលមានពាក្យបណ្ដឹង រួចហើយ ចៅក្រមស៊ើបសួរត្រូវតែបញ្ជូនបណ្ដឹងនេះទៅព្រះរាជអាជ្ញា ព្រះរាជអាជ្ញាក្រោយពេលដែលឃើញមានពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ តាមដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ អាចធ្វើប្រឆាំងនឹងអញ្ញាត្តិជន ទោះបីបណ្ដឹងមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ ព្រះរាជអាជ្ញាក៏អាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនណាបើបណ្ដឹងអាជ្ញាត្រូវបានផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ។ ទោះបីជាមានការសុំមិនឱ្យបើកការស៊ើបសួរក៏ដោយចុះក៏ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចចំពោះការសុំមិនឱ្យបើកការស៊ើបសួរនោះដែរ ហើយចៅក្រមស៊ើបសួរនៅតែអាចសម្រេចបើកចំណាត់ការលើពាក្យសុំនោះឯករាជ្យដដែល ដោយសម្រេចមិនបើកការស៊ើបសួរ និងសម្រេចបើកការស៊ើបសួរ ។

- ***សម្រេចបើកការស៊ើបសួរ ៖*** ចៅក្រមស៊ើបសួរត្រូវចេញដីការសម្រេចមានសំអាងហេតុ ជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ។

- ***សម្រេចមិនបើកការស៊ើបសួរ ៖*** ចៅក្រមស៊ើបសួរត្រូវចេញដីការសម្រេចមានសំអាងហេតុហើយជូនដំណឹងនេះដល់ព្រះរាជអាជ្ញា ។

ដីការសម្រេចទាំងអស់ របស់ចៅក្រមស៊ើបសួរ សុទ្ធតែអាចប្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរបាន ដោយដើមបណ្ដឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញា ។

## ផ្នែកទី២៖ ការចោទប្រកាន់របស់តំណាងអយ្យការ

នៅក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌ ដំណាក់កាលនៃការចោទប្រកាន់គឺជាដំណាក់កាលមួយដែលអនុវត្តដោយព្រះរាជអាជ្ញា ។ មានតែស្ថាប័នអយ្យការទេ ដែលមានសិទ្ធិក្នុងការធ្វើបណ្ដឹងអាជ្ញា ។[36] ព្រះរាជអាជ្ញា គឺជាម្ចាស់បណ្ដឹងអាជ្ញាក្នុងការធ្វើបណ្ដឹង និងចោទប្រកាន់ជនល្មើស ។ បណ្ដឹងអាជ្ញានេះអនុវត្តលើគ្រប់បុគ្គលទាំងអស់ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុល ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិសាសន៍ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។[37] ម្យ៉ាងវិញទៀតការចោទប្រកាន់ត្រូវបានធ្វើឡើង បន្ទាប់ពីព្រះរាជអាជ្ញាទទួលបានបណ្ដឹង ដោយពាក្យបណ្ដឹង និងពាក្យបរិហារកេរ្តិ៍ ពីសំណាក់ជនរងគ្រោះដោយផ្ទាល់ ឬតាមរយៈដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ។ ជាគោលការណ៍ ព្រះរាជអាជ្ញាដែលតាំងខ្លួនជាម្ចាស់បណ្ដឹងអាជ្ញា តែងតែប្រកាន់ភ្ជាប់នៅតួនាទីរបស់ខ្លួន ក្នុងការធានាសណ្ដាប់ធ្នាប់សាធារណៈ

[36] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៣១ ថ្មី ។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤ ។

នឹងការពារផលប្រយោជន៍ទូទៅ ដូចនេះ ព្រះរាជអាជ្ញាមិនអាចបដិសេធសំណុំរឿងណាមួយដោយមិនធ្វើការចោទប្រកាន់នោះទេ បើសំណុំរឿងនោះត្រូវបានពិនិត្យឃើញថា មានអាទិភាពនៃបទល្មើស និងជនល្មើសមានពិរុទ្ធភាព ហើយមានស្ថានភាពចាំបាច់ដើម្បីសម្រេចធ្វើការចោទប្រកាន់ ។ តើអ្វីទៅជាការចោទប្រកាន់របស់ព្រះរាជអាជ្ញា ?

ការចោទប្រកាន់របស់ព្រះរាជអាជ្ញា គឺជាចំណាត់ការមួយដែលមានអានុភាពផ្ទេរសមត្ថកិច្ចពីអយ្យការទៅយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ឬម្យ៉ាងទៀតគេអាចនិយាយបានថា ជាការបញ្ជូនជនល្មើសមួយ ឬច្រើននាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ ឬចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌ ដើម្បីធ្វើការផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។ ដោយយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ការចោទប្រកាន់នេះអាចធ្វើទៅបានដោយស្តែងតាមនីតិវិធី៣យ៉ាងគឺ[38] ៖ ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

**កថាខណ្ឌទី១៖ ការបើកការស៊ើបសួរ**

អ្វីទៅដែលហៅថា ការបើកការស៊ើបសួរ ? ការបើកការស៊ើបសួរគឺជាការប្តឹងរបស់ព្រះរាជអាជ្ញា ទៅចៅក្រមស៊ើបសួរ ឱ្យធ្វើការស៊ើបសួរលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ ហើយការស្រាវជ្រាវទៅលើអង្គហេតុរបស់ចៅក្រមស៊ើបសួរ គឺមានលក្ខណៈខុសពីការស្រាវជ្រាវរបស់ព្រះរាជអាជ្ញាពីព្រោះថាព្រះរាជអាជ្ញានៅពេលដែលស្រាវជ្រាវរកព័ត៌មាន និងភស្តុតាងទាំងឡាយណាដើម្បីកំណត់ឲ្យឃើញអំពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌដើម្បីធ្វើការចោទប្រកាន់ ប៉ុន្តែនៅពេលសំណុំរឿងត្រូវបានបញ្ជូនទៅឲ្យចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នោះចៅក្រមស៊ើបសួរត្រូវតែបំពេញកិច្ចធ្វើការស្រាវជ្រាវដើម្បីស្វែងរកឲ្យឃើញការពិតអំពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើស ដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ហើយក្នុងខណៈនោះ ។ ចៅក្រមស៊ើបសួរ និងធ្វើការស្រាវជ្រាវនៅគ្រប់ទិន្នន័យឬព័ត៌មានទាំងអស់ដែលមាន ទាំងភស្តុតាងដាក់បន្ទុក និងភ័ស្តុតាងដោះបន្ទុក ។ គួរបញ្ជាក់ផងដែរថា បើការស៊ើបសួរត្រូវតែធ្វើឡើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ គ្មានកិច្ចស៊ើបសួរណាមួយដែលអាចធ្វើឡើងដោយគ្មានដីកានេះបានទេ ការស៊ើបសួរត្រូវបានបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ។ ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរនេះ ត្រូវបានទាមទារឲ្យមានការគោរពនូវលក្ខខណ្ឌអនុគ្រោះមួយចំនួន ហើយស្របទៅតាមនីតិវិធីជាក់លាក់ និងតាមទម្រង់ការនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជាដាច់ខាតនិងដើម្បីបង្កើតឲ្យមានអានុភាពផ្សេងៗ ។ តើការបើកការស៊ើបសួរនេះមានលក្ខខណ្ឌនីតិវិធីទម្រង់និងអានុភាពយ៉ាងដូចម្តេចខ្លះ?

**១.លក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរ**

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤៣ ។

បើយើងពិនិត្យមើលតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ចៅក្រមនោះបានចង្អុលបង្ហាញអំពីលក្ខខណ្ឌមួយចំនួនដើម្បីឲ្យឈានទៅដល់ការបើកការស៊ើបសួរ ដោយស្របតាមនីតិវិធីនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ។ លក្ខខណ្ឌនេះ គឺសំដៅទៅដល់ការកំណត់មើលអំពីប្រភេទនៃបទល្មើសជាមុនសិន មុននឹងព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបើកការស៊ើបសួរ បើយើងពិនិត្យមើលទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានបញ្ញត្តិអំពីប្រភេទនៃបទល្មើស ដែលអាចបើកការស៊ើបសួរមាន ២ ប្រភេទ គឺបទឧក្រិដ្ឋ និងមជ្ឈិម ។[39]

- **ចំពោះបទឧក្រិដ្ឋ** ៖ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ គ្មានបទឧក្រិដ្ឋណាមួយដែលត្រូវបានជំនុំជម្រះដោយពុំបានឆ្លងកាត់ដំណាក់កាលនៃការបើកការស៊ើបសួរនោះទេ ។ ពីព្រោះ បទឧក្រិដ្ឋជាប្រភេទបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរមានអប្បបរមានៃទោសដាក់ពន្ធនាគារ ចាប់ពី ៥ ឆ្នាំ ទៅ ៣០ ឆ្នាំ ឬអស់មួយជីវិត ។ ដោយសារកម្រិតទោសធ្ងន់ធ្ងរនេះឯងហើយ ទើបវាទាមទារនូវការស្រាវជ្រាវឲ្យបានហ្មត់ចត់ មុននឹងសម្រេចយកជនល្មើសទៅ ចំពោះមុខតុលាការធ្វើការជំនុំជម្រះ ពីព្រោះដើម្បីជៀសវាងការជំនុំជម្រះធ្វើឡើងដោយមានការភាន់ច្រឡំ ឬធ្វើឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សិទ្ធិរបស់ជនដែលត្រូវគេចោទប្រកាន់និងដើម្បីធានាឲ្យដំណើរការរឿងក្តី ប្រកបទៅដោយយុត្តិធម៌ ការស៊ើបសួរជាមុនចំពោះបទឧក្រិដ្ឋ ដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ក្នុងការស៊ើបទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ដែលចំណុចនេះ គឺដើម្បីស្វែងឲ្យដឹងជាការពិត និងលាតត្រដាងកាន់តែច្បាស់មួយកម្រិតទៀត ពីការជំនុំជម្រះរបស់យុត្តាធិការជំនុំជម្រះ ។

- **ចំពោះបទមជ្ឈិម** ៖ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានកំណត់ថា ព្រះរាជអាជ្ញាអាចប្រើនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាមចំពោះប្រភេទបទមជ្ឈិម ហើយព្រះរាជអាជ្ញាក៏អាចប្រើនីតិវិធីបើកការស៊ើបសួរបានដែរ ។[40] ជាការកត់សម្គាល់ បទមជ្ឈិម គឺជាប្រភេទនៃបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ៦ ថ្ងៃ ដល់ ៥ ឆ្នាំ ។[41] ដោយឡែក ការបើកការស៊ើបសួរចំពោះបទមជ្ឈិមនេះ គឺគេពុំអាចឬពុំបានចែងច្បាស់ថាជាប្រភេទបទមជ្ឈិមស្មុគស្មាញ ឬយ៉ាងណាទេ ក៏ប៉ុន្តែតាមស្មារតីនៃក្រមទៀត បានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញា ក្នុងការថ្លឹងថ្លែងអំពីស្ថានភាពនៃបទល្មើសប្រសិនណាបើបទល្មើសដែលជនត្រូវចោទបានប្រព្រឹត្តបទមជ្ឈិម ប៉ុន្តែមិនមានភស្តុតាងគ្រប់គ្រាន់ ឬជនល្មើសជាអញ្ញាត្រជន ពុំមានអត្តសញ្ញាណច្បាស់លាស់ ហើយសំណុំរឿងមិនទាន់ចូល ពោលគឺមិនមានលក្ខណៈគ្រប់គ្រាន់

---

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១២២ ។

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤៥ ។

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤៦ ។

ក្នុងការជំនុំជម្រះបាន ។ ដូចនេះ ព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់តាមនីតិវិធីបើកការស៊ើបសួរ ។ ឧទាហរណ៍ ៖ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៧ មានបុរសម្នាក់បានជិះម៉ូតូម៉ាកហុងដាពណ៌ខ្មៅបានឆក់យកកាបូប កញ្ញា ដានី ដែលកំពុងតែជិះម៉ូតូតាមផ្លូវបន្ទាប់ពីធ្វើសកម្មភាពឆក់ហើយ បុរសនោះក៏ជិះម៉ូតូទៅបាត់ដោយសុវត្ថិភាព ហើយពុំមាននរណាម្នាក់ស្គាល់ពីអត្តសញ្ញាណរបស់ជនសង្ស័យនោះទេ ។ ប្រសិនណាបើយើងពិនិត្យមើលអង្គហេតុនេះក្នុងករណីនេះ វាជាប្រភេទបទមជ្ឈិមហើយព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរបាន ពីព្រោះជននេះវាជាអញ្ញត្រជន ពោលគឺជនមិនស្គាល់មុខហើយត្រូវការស្រាវជ្រាវ បន្ថែមក្នុងការស្វែងរក អត្តសញ្ញាណ ភស្តុតាង ក៏ដូចជាការចាប់ខ្លួនជននោះមកចំពោះមុខចៅក្រមស៊ើបសួរ ។ ជារួមគ្រប់ស្ថានភាពនៃបទល្មើសដែលត្រូវបានចាត់ទុកជាប្រភេទនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលមានលក្ខណៈដូចដែលបានរៀបរាប់ខាងលើ គឺត្រូវតែធ្វើការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ ចំពោះនីតិវិធីនៃការបើកការស៊ើបសួរ យើងពិនិត្យមើលនៅក្នុងរឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាអាចទទួលសំណុំរឿង តាមរយៈការដាក់ពាក្យបណ្ដឹងដោយផ្ទាល់របស់ដើម ។

**២.នីតិវិធីនៃការស៊ើបសួរ**

បណ្ដឹងដែលបញ្ជូនមក លោកព្រះរាជអាជ្ញា ឬតាមរយៈការបញ្ជូនសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌មុននឹងសម្រេចបើកការស៊ើបសួរ ព្រះរាជអាជ្ញា ត្រូវធ្វើការវាយតម្លៃនិងវិនិច្ឆ័យលើសំណុំរឿង តាមប្រភពនៃការបញ្ជូននីមួយៗ ។ ដូច្នេះ យើងសិក្សាពីប្រភពនៃការបញ្ជូនពាក្យបណ្ដឹងនោះដូចតទៅ៖

**ក.ការបើកការស៊ើបសួរតាមរយៈពាក្យបណ្ដឹងបញ្ជូនមកដោយផ្ទាល់**

ការបើកការស៊ើបសួរតាមរយៈពាក្យបណ្ដឹងបញ្ជូនមកដោយផ្ទាល់ គឺដើមបណ្ដឹងអាចធ្វើការដាក់ពាក្យប្ដឹងដោយផ្ទាល់ដើម្បីឲ្យព្រះរាជអាជ្ញាធ្វើចំណាត់ការចំពោះពាក្យបណ្ដឹងនេះ បន្ទាប់មក ព្រះរាជអាជ្ញាទទួលបានពាក្យបណ្ដឹងដោយផ្ទាល់ ។ ព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងសម្រេចធ្វើការចោទប្រកាន់ទៅតាមវិធីណាមួយ ប្រសិនណាបើពិនិត្យលើអង្គហេតុនោះ វាជាបទល្មើសដោយនីតិវិធីនៃការថ្លឹងថ្លែងនូវការស្រាវជ្រាវ ឬត្រូវធ្វើឡើងតាមរយៈការសុំមន្ត្រីនគរបាលយុត្តិធម៌ ឲ្យធ្វើការស៊ើបអង្កេតបឋម ឬការកោះហៅដើមបណ្ដឹង ជនសង្ស័យសាក្សី ដើម្បីសាកសួរ និងស្ដាប់ចម្លើយដោយផ្ទាល់ ។ បន្ទាប់ពីការស៊ើបអង្កេត និងការស្រាវជ្រាវ បានបញ្ចប់ ប្រសិនណាបើអង្គហេតុនោះវាជាបទល្មើសហើយបានបំពេញលក្ខខណ្ឌនៃការបើកការស៊ើបសួរ ដូចបានបកស្រាយខាងលើនោះ ព្រះរាជអាជ្ញានឹងសម្រេចធ្វើការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ នេះជាការបើកការស៊ើបសួរតាមរយៈពាក្យបណ្ដឹងបញ្ជូនមកដោយផ្ទាល់ នឹងយើងសិក្សាបន្តនៅក្នុងចំណុច(ខ)គឺ ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ម្តង ។

**ខ.ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ម្តង**

ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ម្តង គឺមានន័យថា មន្ត្រីនគរបាលយុត្តិធម៌ទទួលបានពាក្យបណ្តឹងបរិហារ និងបណ្តឹងទាមទារក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន នៅពេលនោះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបើកការស៊ើបអង្កេតបឋម ចំពោះបណ្តឹងដែលខ្លួនបានទទួល ឬនៅពេលដឹងពីបទឧក្រិដ្ឋ និងមជ្ឈិម ឬហូតដល់មួយរួចបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។ ចំពោះករណីបទល្មើសជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌ អាចចាប់ខ្លួន និងឃាត់ខ្លួន ជនសង្ស័យរួចបញ្ជូនខ្លួនជនសង្ស័យទៅចំពោះមុខព្រះរាជអាជ្ញា ។ ដូចនេះនីតិវិធីក្នុងការធ្វើចំណាត់ការចំពោះសំណុំរឿងដែលបញ្ជូនមកដល់ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើឡើងតាមករណីដូចខាងក្រោម៖

***-ករណីដែលសំណុំរឿងគ្មានខ្លួនជនសង្ស័យ(នៅក្រៅឃុំ)៖*** សំណុំរឿងនេះគ្មានខ្លួនជនសង្ស័យ ដូច្នោះសំដៅដល់សំណុំរឿងដែលបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលជនសង្ស័យ ពុំត្រូវបានឃាត់ខ្លួនហើយបញ្ជូនមកព្រះរាជអាជ្ញានោះទេ ។ នៅពេលដែលព្រះរាជអាជ្ញាបានទទួលនូវសំណុំរឿង ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងអង្គហេតុ ដោយពិនិត្យមើលភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង របាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ និងការកោះហៅដើមបណ្តឹង ជនសង្ស័យ និងសាក្សី ដើម្បីសាកសួរ និងស្តាប់ចម្លើយ ។ បន្ទាប់មកប្រសិនណាបើអង្គហេតុខាងលើ គឺជាបទល្មើសហើយបានបំពេញលក្ខខណ្ឌ ដែលតម្រូវឲ្យព្រះរាជអាជ្ញា បើកការស៊ើបសួរ លោកព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយត្រូវកំណត់ឈ្មោះជនត្រូវចោទ ម្នាក់ ឬច្រើននាក់ ឬអនីតិជន ឲ្យឋិតនៅក្រោមការត្រួតពិនិត្យ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។

***-សំណុំរឿងមានខ្លួនជនសង្ស័យ(ឃុំខ្លួន)៖*** ក្នុងករណីសំណុំរឿងមានខ្លួន សំដៅដល់សំណុំរឿងដែលជនសង្ស័យ ត្រូវបានចាប់ និងឃាត់ខ្លួន ដោយមន្ត្រីនគរបាលយុត្តិធម៌ ហើយត្រូវនាំបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា ។ បន្ទាប់ពីផុតរយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន នៅពេលដែលជនសង្ស័យ និងវត្ថុតាង ដែលមាននោះត្រូវបានបញ្ជូនដល់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញាត្រូវធ្វើការសួរចម្លើយ និងពិនិត្យលើសំណុំរឿងនោះ ។ ដោយការពិនិត្យលើសំណុំរឿង ព្រះរាជអាជ្ញាធ្វើការពិនិត្យលើ អង្គហេតុ ឯកសារ និងភ័ស្តុតាង ដែលមាននៅក្នុងសំណុំរឿង របាយការណ៍សំយោគ របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលជាការសន្និដ្ឋានរបស់យុត្តិធម៌ និងចម្លើយរបស់ជនត្រូវចោទប្រសិនណាបើ ពិនិត្យទៅលើសំណុំរឿងនោះហើយយល់ឃើញថា នេះជាបទល្មើស និងបំពេញលក្ខខណ្ឌ នៅក្នុងការបើកការស៊ើបសួរនោះ ។ ព្រះរាជអាជ្ញា ចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរហើយ ព្រះរាជអាជ្ញាអាចសន្និដ្ឋានសុំឲ្យចៅក្រមស៊ើបសួរ សម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬសន្និដ្ឋានសុំឱ្យដាក់ជនត្រូវចោទ ស្ថិតនៅក្រោមការឃុំខ្លួនជាបណ្តោះអាសន្ន ។

**៣.ទម្រង់ការចាំបាច់ចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

ជាការចាំបាច់ ចំពោះនីតិវិធីនៃការបើកការស៊ើបសួរ ត្រូវតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយដីកានេះត្រូវធ្វើឡើងតាមទម្រង់ការមួយជាក់លាក់ ដើម្បីឲ្យនីតិវិធីមានអានុភាពស្របតាមបញ្ញត្តិនៃក្រម ។ យោងតាមមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបញ្ញត្តិអំពីទម្រង់របស់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមានដូចតទៅៈ

- ***សេចក្តីសង្ខេបអង្គហេតុ*** ៖ ចំណុចនេះមានសារៈសំខាន់ណាស់ពីព្រោះបើគ្មានអង្គហេតុណាមួយទេនោះចៅក្រមស៊ើបសួរនឹងមិនដឹងថាកិច្ចស៊ើបសួរនឹងត្រូវសម្តែងទៅលើអង្គហេតុណាមួយនោះទេ ។ ព្រោះកិច្ចស៊ើបសួរអាចបើកបានតែទៅលើអង្គហេតុណាដែល ព្រះរាជអាជ្ញាចោទប្រកាន់នៅតែប៉ុណ្ណោះ ។ ហើយម្យ៉ាងទៀត បើគ្មានអង្គហេតុការណ៍ គ្មានកិច្ចចោទប្រកាន់ណាមួយកើតមានដែរ ។
- ***ការកំណត់ឈ្មោះបទល្មើស*** ៖ ការកំណត់ឈ្មោះបទល្មើស វាមានអត្ថប្រយោជន៍សម្រាប់ជំហានដំបូងនៃកិច្ចស៊ើបសួរ ព្រោះចៅក្រមស៊ើបសួរនឹងមិនអាច ឬមិនទាន់អាចកំណត់ថាអង្គហេតុណា ជាបទល្មើសអ្វីនោះ ការបិទកិច្ចស៊ើបសួរសិនទើបមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការសម្រេចថា អង្គហេតុនេះវាជាបទល្មើសអ្វី ដូចនេះពិតណាស់ ពិតជាមានការលំបាកប្រសិនណាបើមិនមានការកំណត់ឈ្មោះបទល្មើសណាមួយសម្រាប់បើកការស៊ើបសួរ ទោះជាមានការកំណត់ពីឯករាជ្យភាពរបស់ចៅក្រមស៊ើបសួរ លើការកំណត់បទល្មើសណាមួយជាមួយក្តី នេះគ្រាន់តែជាការគិតទៅលើស្មារតីនៃផលប្រយោជន៍តែប៉ុណ្ណោះ ។ ប៉ុន្តែកត្តាចម្បង បានព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ខាងបទព្រហ្មទណ្ឌ តែមិនឃើញមានសរសេរថា ចោទពីបទណាមួយនោះទេ ដូច្នោះត្រូវចាត់ទុកថាគ្មានការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌឡើយ ។
- ***ការបង្ហាញអំពីអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ៖*** ការកំណត់នេះវាជាកត្តាមូលហេតុដែលព្រះរាជអាជ្ញាអះអាងពីឈ្មោះបទល្មើស តែបើមិនសរសេរចូលទៅក្នុងដីកា មានន័យថាគ្មាន មូលដ្ឋាននៃការអះអាងដោយការចោទប្រកាន់ទេ នេះគ្រាន់តែជាការកំណត់ពីភាពច្បាស់លាស់នៃកិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ ។
- ***កំណត់ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ៖*** ចំពោះ ការសរសេរនៅក្នុងដីកាសន្និដ្ឋាន គឺត្រូវតែកំណត់ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើមិនអាចកំណត់បានចំពោះចំណុចនេះបើបុគ្គលជាជនល្មើសត្រូវបានស្គាល់អត្តសញ្ញាណ គឺត្រូវតែមានកំណត់ឈ្មោះរបស់ជនល្មើសនោះក៏ប៉ុន្តែទោះជាមិនមានក៏មិនអីដែរ ព្រោះកិច្ចស៊ើបសួរអាចបើកការប្រឆាំងគ្រប់បុគ្គលដែលមានតម្រុយពិរុទ្ធភាព ពាក់ព័ន្ធជាមួយទោះជាមិនមានការកំណត់ឈ្មោះជនល្មើសក៏ដោយ ។ ហើយដីកានេះចាំបាច់ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា នេះជាទម្រង់រដ្ឋបាលដែលត្រូវតែមាន តែបើគ្មាន ហត្ថលេខាមានន័យថា មិនមានការទទួលស្គាល់ណាមួយរបស់ព្រះរាជអាជ្ញា ។ ដូចនេះមិនមែនជាដីកាមានអានុភាព ឬដីកានេះមិនទាន់មាន

ការសម្រេចដោយព្រះរាជអាជ្ញានៅឡើយ ដូច្នេះគ្មានកិច្ចចោទប្រកាន់ណាមួយកើតមានទេ ។ យោងតាមសារៈសំខាន់នៃទម្រង់ការដែលមិនអាចខ្វះបាន ទោះជាស្មារតីនៃផលប្រយោជន៍ ឬក៏ជាស្មារតីនៃច្បាប់ក៏ដោយ គម្រោងនេះត្រូវបានកំណត់ជាលក្ខណៈពិសេសដដែលត្រូវតែគោរពបើមិនដូច្នោះទេដីកាបញ្ជូនរឿងឲ្យស៊ើបសួរនេះត្រូវ ចិត្តទុកជាមោឃៈ ។

**៤.អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

នៅក្នុងអានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ យើងសិក្សាលើចំណុច ៣ ដែលសំខាន់ៗ គឺការផ្តល់ពេលនៃអាជ្ញាយុកាលនៃបទល្មើស(ក) ការផ្ទេរសមត្ថកិច្ចដោយចៅក្រមស៊ើបសួរឲ្យបើកការស៊ើបសួរ(ខ) និងការកំណត់អំពីដែនសមត្ថកិច្ចលើការស៊ើបសួរ(គ) ។ ចំពោះចំណុចទាំង ៣ ដែលបានរៀបរាប់ខាងលើ ជាបន្តបន្ទាប់នេះដែលទាក់ទងទៅនឹងអានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ យើងខ្ញុំនឹងធ្វើការពន្យល់ ចំណុចនីមួយៗ ដូចខាងក្រោមនេះ៖

**ក.ការផ្តល់ពេលនៃអាជ្ញាយុកាលនៃបទល្មើស**

ចិរវេលានៃអាជ្ញាយុកាលត្រូវចាប់ផ្តើមពីពេលប្រព្រឹត្តបទល្មើស អាជ្ញាយុកាលត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ មានន័យថាគ្រប់កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញាមិនថាតាមរយៈការបញ្ជូនរឿងទៅជំនុំជម្រះ រាល់ការបង្ហាញខ្លួនភ្លាម ឬការបើកការស៊ើបសួរនេះទេ វាជាសញ្ញានៃការចោទប្រកាន់មួយដែលនាំឲ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ។ រីឯកាតព្វកិច្ចនៃការស៊ើបសួរ សំដៅទៅដល់កិច្ចដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដែលកិច្ចនេះក៏មានអាជ្ញាអានុភាព ដាក់អាជ្ញាយុកាលនៃបទល្មើសនូវបណ្តឹងអាជ្ញានៃបណ្តឹងអាជ្ញាយុកាលផងដែរ ។

**ខ.ការផ្ទេរសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរឲ្យបើកការស៊ើបសួរ**

គ្មានកិច្ចស៊ើបសួរណាមួយ អាចបើកដោយគ្មានការចោទប្រកាន់របស់ព្រះរាជអាជ្ញាទេ លើកលែងតែការដាក់ឲ្យមានចលនានៃបណ្តឹងអាជ្ញាដែលជនរងគ្រោះ ។ កិច្ចស៊ើបសួរដែលបើកដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ កិច្ចស៊ើបសួរត្រូវការប្តឹងមោឃៈគឺត្រូវប្តឹងទៅសភាស៊ើបសួរគ្រប់ពេលវេលានៅពេលដែលមានការយល់ឃើញថាកិច្ចស៊ើបសួរណាមួយស្តែងក្នុងភាពខុសនីតិវិធី ។ ការចូលជាស្ថាពរនៃដីកាដំណោះស្រាយ គឺមានអនុភាពលុបលាងមោឃភាពនៃនីតិវិធីមុន មានន័យថាទោះជាកិច្ចស៊ើបសួរណាមួយ ដែលអាចជាកម្មសិទ្ធិសមូហភាពក៏ដោយ ក៏កិច្ចមោឃៈនោះមិនអាចលើកមកពិចារណាទៀតទេនៅពេលសវនាការ ។ ដីកាដែលអាចជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍មិនអាចជាកម្មវត្ថុនៃបណ្តឹងមោឃភាពទេ ។ ព្រោះការចែងពីចំណុចនេះដើម្បីការពារការចូលជាស្ថាពររបស់ដីកាដំណោះស្រាយ ដោយសារភាគីយល់ថាខ្លួនបានប្តឹងមោឃៈពីដីកានេះ តែភាគីបែរជាមិនធ្វើបណ្តឹង

ឧទ្ទរណ៍ដែលជាហេតុនាំឲ្យផុតរយៈពេលប្ដឹងបន្ត យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ ក៏បានកំណត់ថា បណ្ដឹងឧទ្ទរណ៍អាចដាក់ជាកម្មវត្ថុ នៃការពិនិត្យនិយតភាពនៃកិច្ចនីតិវិធីដោយសភាស៊ើបសួរឯកឯងដែរ ។

**គ.ការកំណត់អំពីដែនសមត្ថកិច្ចលើការស៊ើបសួរ**

ការកំណត់អំពីដែនសមត្ថកិច្ចលើការស៊ើបសួរមានន័យថា ចៅក្រមស៊ើបសួរអាចស៊ើបសួរបានតែអង្គហេតុដែលកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ ។ ករណីលេចចេញអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌ នៅពេលដែលចៅក្រមស៊ើបសួរបើកការស៊ើបសួរនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនោះទៅព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញាអាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរអំពីអង្គហេតុថ្មី ដែលបានទៅតាមរយៈនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ។[42] តែបើកិច្ចស៊ើបសួរដែលបើកដោយបំពានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញាទេនោះ គឺជាកម្មវត្ថុនៃកិច្ចមោឃភាព តែករណីមួយចំនួនមិនបាច់សុំដីកានោះក៏បានដែរ ។ បើយើងពិនិត្យឃើញថា អង្គហេតុថ្មីគ្រាន់តែជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដើម្បីដឹងថាមានអង្គហេតុណាខ្លះនោះ យើងគ្រាន់តែមើលច្បាប់ដែលអះអាងយ៉ាងជាក់លាក់ ទាក់ទងនឹងការកំណត់អំពីស្ថានទម្ងន់ទោសនៃអង្គហេតុមួយ ដោយសារមានអង្គហេតុមួយទៀត ។ ឧទាហរណ៍៖ ដូចជាបទឃាតកម្មគិតទុកជាមុនឬដោយមានស្ថានទម្ងន់ទោស ដោយសារជនរងគ្រោះឬដោយសារគោលដៅ ឬធ្វើទារុណកម្មឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈនិងអំពើផ្សេងផ្សេងទៀតដែលកំណត់នៅក្នុងច្បាប់ព្រហ្មទណ្ឌ សុទ្ធជាអង្គហេតុដែលមានលក្ខណៈជាស្ថានទម្ងន់ទោសនៃបទឃាតកម្ម ។

**កថាខណ្ឌទី២៖ ការបញ្ជូនរឿងទៅជំនុំជម្រះ**

យើងដឹងហើយការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីដែលព្រះរាជអាជ្ញាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូង ដើម្បីធ្វើការជំនុំជម្រះដោយផ្ទាល់តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។[43] ការទទួលយកការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺមានគោលបំណងធានាសិទ្ធិរបស់ជនល្មើស ក្នុងការទទួលបាននូវការជំនុំជម្រះរបស់តុលាការ ដោយទាមទារឲ្យមានការធ្វើការចោទប្រកាន់ជនល្មើស និងបញ្ជូនអង្គហេតុទៅយុត្តាធិការជំនុំជម្រះតែម្ដង ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីណាផ្សេងទៀតឡើយ ។ មិនតែប៉ុណ្ណោះ ដំណើរការនៃនីតិវិធីនេះ គឺវាមានលក្ខណៈឆាប់រហ័សពីព្រោះការចោទប្រកាន់ត្រូវបានផ្ទេរសមត្ថកិច្ចរបស់អង្គការអយ្យការទៅចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះតែម្ដង ។ យ៉ាងណាមិញ ដើម្បី

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១២៥ ។

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤៦ ។

ឲ្យនីតិវិធីនេះអាចប្រព្រឹត្តទៅបាន គឺទាមទារឲ្យមានការគោរពលក្ខខណ្ឌមួយចំនួន ហើយត្រូវអនុវត្តតាមនីតិវិធីមួយជាក់លាក់ ដែលនីតិវិធីនេះត្រូវតែធ្វើឡើងតាមទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។ មុននឹងឈានឲ្យមានអានុភាពទៅដល់ចំណាត់ការយុត្តាធិការជំនុំជម្រះ តើការបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ ត្រូវមានលក្ខខណ្ឌនីតិវិធីទម្រង់ និងអានុភាពយ៉ាងដូចម្ដេច?

**១.លក្ខខណ្ឌនៃបទល្មើស**

ចំពោះលក្ខខណ្ឌនៃបទល្មើស នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ អាចធ្វើឡើងបានចំពោះបទមជ្ឈិម និងបទលហុតែប៉ុណ្ណោះ ។

***បទមជ្ឈិម និងបទលហុ*** ៖ ចំពោះបទមជ្ឈិម ថ្វីដ្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងច្បាស់ថា ជាប្រភេទបទមជ្ឈិមបែបណា ដែលអាចអនុញ្ញាតឲ្យព្រះរាជអាជ្ញាអនុវត្តនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏ដោយ ប៉ុន្តែគេបានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញា ថ្លឹងថ្លែង ពីស្ថានភាពនៃបទល្មើសដោយឡែក ។ បើព្រះរាជអាជ្ញាមើលឃើញថាបទមជ្ឈិមនោះ មានភ័ស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីឲ្យតុលាការធ្វើការជំនុំជម្រះវិនិច្ឆ័យក្តីលើសំណុំរឿងនេះបាន ព្រះរាជអាជ្ញានឹងប្រើនីតិវិធី ការចោទប្រកាន់នេះ ។ ផ្ទុយមកវិញបទមជ្ឈិមអាចជាកម្មវត្ថុនៃការចោទប្រកាន់តាមទម្រង់ជាការបើកការស៊ើបសួរ និងជាការបង្ហាញខ្លួនភ្លាមផងដែរ ។ ព្រោះមានស្ថានភាពនៃបទល្មើសមជ្ឈិមមួយចំនួន ត្រូវបានទទួលឱ្យមានការចោទប្រកាន់តាមនីតិវិធីផ្សេងទៀតបានដូចជា ស្ថានភាពនៃបទមជ្ឈិមដែលមាន លក្ខណៈស្មុគស្មាញ ទាមទារឲ្យមានការបើកការស៊ើបអង្កេតស្វែងរកភ័ស្តុតាងគ្រប់គ្រាន់ ឬបទល្មើសដែលមិនស្គាល់អត្តសញ្ញាណជនល្មើសជាដើម ។ ឧទាហរណ៍៖ សុខាបានលួចគោរបស់អ្នកជិតខាងចំនួន២ក្បាល ដល់ថ្ងៃក្រោយមកម្ចាស់គោបានដាក់ពាក្យបណ្តឹងចោទប្រកាន់លោកសុខាដោយមានសាក្សី ២នាក់ បានឃើញយ៉ាងច្បាស់លាស់ ។ លើសពីនេះទៅទៀត នៅពេលដែលតំណាងអយ្យការបានកោះហៅសុខាមកស្តាប់ចម្លើយ សុខាក៏បានសារភាពថាពិតជាបានលួចគោនេះមែន ដោយសារតែម្ចាស់គោបានចង់ទុកចោល ហើយខ្លួនត្រូវការជាប្រាក់ជាបន្ទាន់ដើម្បីយកទៅព្យាបាលប្រពន្ធ នៅក្នុងស្ថានភាពបែបនេះ ឃើញថាភ័ស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីបទល្មើសដែល ព្រះរាជអាជ្ញាមិនចាំបាច់បើកការស៊ើបសួរទៀតនោះទេ គឺព្រះរាជអាជ្ញានឹងបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែម្តងបាន ។ ព្រះរាជអាជ្ញាត្រូវតែជ្រើសរើសយកវិធីនៃការចោទប្រកាន់នេះ មិនមានបទប្បញ្ញត្តិណាផ្សេង ដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញាបើកការស៊ើបសួរ ឬប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមចំពោះគាត់រហូតនោះទេ គឺដោយសារតែបាត់រហូតជាបទល្មើសតូចតាច ដោយមានអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈក្រោមឬស្មើ៦ថ្ងៃ និងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ ឬត្រឹមតែជាបទល្មើសដែលត្រូវផ្តន្ទាទោសដោយគ្រាន់តែពិន័យជាប្រាក់តែប៉ុណ្ណោះ ។ ដោយមើលឃើញថាបាត់រហូតជាប្រភេទនៃបទល្មើសដែលត្រូវផ្តន្ទាទោសស្រាល ដូចនេះគ្មានជម្រើសអ្វីផ្សេងដែលល្អជាងការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នោះទេ ។ ពីព្រោះវាអាចការពារមិនឲ្យមានការ

ប៉ះពាល់ដល់សិទ្ធសេរីភាព ចេញទៅធ្វើរបស់ជនជាប់ចោទនឹងផ្តល់ផលប្រយោជន៍ដល់តុលាការក្នុងការធ្វើការរឿងក្តីឲ្យបានឆាប់រហ័សផងដែរ ។ គួរបញ្ជាក់ផងដែរថា ទោះបីជាការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ចំពោះករណីហេតុឬបទមជ្ឈិមក៏ដោយការបញ្ជូនទៅជំនុំជម្រះនេះ ត្រូវតែធ្វើឡើងតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។

***លក្ខខណ្ឌសាវតារជាតិរបស់ជនល្មើស៖*** ចំពោះលក្ខខណ្ឌសាវតារជាតិដែលជាលក្ខខណ្ឌមួយ នៅក្នុងកិច្ចនៃនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ចំពោះលក្ខខណ្ឌសាវតារជាតិនេះ គឺនៅក្នុងនីតិវិធីហើយ ។ ក្រៅពីការកំណត់ឲ្យបានអំពីប្រភេទនៃបទល្មើសដែលជាលក្ខខណ្ឌនោះហើយ ព្រះរាជអាជ្ញាចាំបាច់ត្រូវរកឲ្យឃើញអំពីសាវតារជាតិរបស់ជនល្មើសនេះក៏ជាលក្ខខណ្ឌចាំបាច់មួយដែរ ។ ព្រោះវាជាស្មារតីនៅក្នុងការធ្វើបណ្តឹងអាជ្ញា គឺមានគោលបំណងមិនត្រឹមតែស្វែងរកអត្ថិភាពនៃបទល្មើសទេ អ្វីដែលសំខាន់នោះ គឺចង់ឲ្យមានការផ្តន្ទាទោសចំពោះជនល្មើសទៀតផង ។ ការចោទប្រកាន់តាមគម្រោងជាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែលមិនស្គាល់សាវតារជនល្មើស គឺមិនអាចប្រព្រឹត្តទៅបាន ម្យ៉ាងទៀតក្រមនីតិវិធីទទួលស្គាល់វិសាលភាពនៃបណ្តឹង ចំពោះជនជាប់ចោទគឺមានន័យថាតុលាការនឹងជំនុំជម្រះតែជនណា មាននៅក្នុងពាក្យដែលប្តឹងមកខ្លួនប៉ុណ្ណោះ ។ ដូចនេះការខ្វះអត្តសញ្ញាណជនល្មើសជាលក្ខខណ្ឌត្រូវតែមានដែលខ្វះមិនបាន ។

**២.នីតិវិធីនៃការពន្យល់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់**

នីតិវិធីចំនួនមិនជំនុំជម្រះផ្ទាល់ គឺជានីតិវិធីមួយដែលមិនឆ្លងកាត់ដំណាក់កាលនៃការស៊ើបសួរទេ ពោលគឺនៅពេលដែលព្រះរាជអាជ្ញាទទួលពាក្យបណ្តឹងហើយ លក្ខខណ្ឌនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ត្រូវបានបំពេញ ។ នោះព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ភ្លាម ហើយបញ្ជូនសំណុំរឿងទៅយុត្តាធិការជំនុំជម្រះតាមរយៈដីកាបញ្ជូនរឿងទៅជម្រះផ្ទាល់ នឹងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់សម្រាប់កោះហៅជនជាប់ចោទ ឲ្យចូលសវនាការដើម្បីធ្វើការជំនុំជម្រះ ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវប្រគល់ឲ្យជនជាប់ចោទក្នុងចិរវេលាដីកាកោះហៅមួយដែលកំណត់ដោយច្បាប់ និងស្របតាមរបៀបបែបបទនៃការប្រគល់មួយច្បាស់លាស់ ចៀសវាងការបង្កើតឲ្យមានមោឃភាពនៃនីតិវិធី ។

នៅក្នុងនីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់នេះគឺយើង ត្រូវយល់ដែលឆ្លងកាត់ដំណាក់កាលគឺនីតិវិធីនេះមាន៣ ។ យើងត្រូវសិក្សា អំពីចិរវេលានៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់(ក) របៀបនៃការប្រគល់ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់(ខ) និងផលវិបាកនៃការពុំបានគោរពរយៈពេលតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់(គ) ។ ដូចនេះ នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺវាឆ្លងកាត់នៅក្នុង ៣លក្ខខណ្ឌ យើងខ្ញុំសុំធ្វើការពន្យល់អំពីចំណុចនីមួយៗដូចខាងក្រោម៖

**ក.អំពីចិរវេលានៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

បើយើងគិតពីរយៈពេលដែលត្រូវគោរព រវាងការប្រគល់ដីកាកោះហៅបញ្ជូនជំនុំជម្រះផ្ទាល់ ទៅឲ្យដល់ជនជាប់ចោទ នៅថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ[44]

- ១៥ថ្ងៃ ប្រសិនណាបើជនជាប់ចោទរស់នៅក្នុងដែនដី នៃទីស្នាក់ការរបស់តុលាការជាន់ដំបូង ។
- រយៈពេល ២០ថ្ងៃ ប្រសិនណាបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ ។
- រយៈពេល ២ខែ ប្រសិនណាបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា
- ៣ខែ ប្រសិនបើកាលណាបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត ។

ទាក់ទងទៅនឹងថិរវេលានៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ចំណុចមួយទៀតគឺកត្តាក្រៅប្រទេស ពេលដែលយើងដឹងពីថេរៈវេលា នៃការប្រគល់ដីកាកោះហៅហើយ យើងខ្ញុំនឹងពន្យល់អំពីរបៀបនៃការប្រគល់ដីកាកោះហៅ ។

**ខ.របៀបនៃការប្រគល់ដីកាកោះហៅ**

ការប្រគល់ដីកាកោះហៅទៅបញ្ជូនជំនុំជម្រះផ្ទាល់នេះ ឲ្យទៅលើជនជាប់ចោទ តើប្រគល់របៀបយ៉ាងម៉េច? ចំពោះការប្រគល់ដីកាកោះ និងចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវប្រគល់ដល់ជនជាប់ចោទដោយផ្ទាល់ដៃ ដោយព្រះរាជអាជ្ញា ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវប្រគល់ចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដល់ជនជាប់ចោទ ព្រះរាជអាជ្ញាចុះនិទ្ទេសស្តីពីការបរិច្ឆេទ និងទីកន្លែងប្រគល់ដីកានៅលើដើមដីកាជនជាប់ចោទចុះហត្ថលេខានៅតាមដីកានេះ ។ ចំពោះដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចត្រូវប្រគល់ដោយអាជ្ញាសាលាបានដែរ ។ អាជ្ញាសាលាត្រូវប្រើគ្រប់មធ្យោបាយ ដើម្បីប្រគល់ដីកានេះឲ្យជនជាប់ចោទដោយផ្ទាល់ដៃ ។[45] ចំពោះរបៀបផ្សេងទៀត នៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចធ្វើឡើងតាមរយៈក្រឡាបញ្ជីឬតាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនណាបើជនជាប់ចោទត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀតតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។ ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរ ពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬអាវុធហត្ថ ដែលព្រះរាជអាជ្ញាសុំឲ្យប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា ។ នេះទាក់ទងអំពីរបៀបនៃការប្រគល់ដីកាកោះហៅ ជាបន្តទៀតចំណុចដែលយើងសិក្សាបន្ត អំពីផលវិបាកនៃការពុំគោរពរយៈពេលតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។

**គ.ផលវិបាកនៃការពុំគោរពរយៈពេលតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤៥៧ ។

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤៥៨ ។

នៅក្នុងករណីនេះ បើយើងគិតពីរយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្ហាញខ្លួនភ្លាមមិនបានគោរពទេ នោះតុលាការត្រូវបានចំណាត់ការតាមករណីដូចខាងក្រោម ៖

- ប្រសិនណាបើជនជាប់ចោទមិនចូលបង្ហាញខ្លួនទេ តុលាការពិនិត្យមើលមោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។ ដូច្នោះ តុលាការបង្គាប់ឲ្យចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់សាជាថ្មីម្តងទៀត លើកលែងតែបណ្តឹងអាជ្ញាត្រូវផុតរលត់ ។ មានន័យក្នុងករណីដែល ជនជាប់ចោទមិនចូលបង្ហាញខ្លួនភ្លាមទេ ចំណុចនេះទេផ្ទុយទៅវិញ ប្រសិនបើអ្នកប្រែជាមកបង្ហាញខ្លួននៅពេលសវនាការ តុលាការមិនចាំបាច់ទាមទារដូចការចោទប្រកាន់ជាថ្មីទេ ។
- ប្រសិនណាបើជនជាប់ចោទយល់ព្រមជាក់លាក់ឱ្យជំនុំជម្រះភ្លាម តែបើជននេះមិន អង្គជំនុំជម្រះភ្លាមទេ តុលាការបង្គាប់ឲ្យលើករឿងនេះទៅជំនុំជម្រះនៅពេលសវនាការលើកក្រោយទៀត ។ នេះទាក់ទងទៅនឹងផលវិបាកនៃការមិនគោរពទៅតាមរយៈពេលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។

## ៣.ទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ តែនៅក្នុងដីកាកោះហៅហ្នឹងវាមានទម្រង់យ៉ាងម៉េចដើម្បីឲ្យមានតម្លៃសុពលភាពនៅក្នុងការអនុវត្តនីតិវិធីនោះ ។ ទម្រង់នៃការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ បានកំណត់នូវចំណុចជាផលប្រយោជន៍សំខាន់ក្នុងការជំនុំជម្រះ ហើយគម្រោងរបស់ដីកានេះរួមមានដូចតទៅ ៖[46]

***អត្តសញ្ញាណជនជាប់ចោទ៖*** អត្តសញ្ញាណនេះសំខាន់ណាស់ គឺជាការកំណត់អំពីថាតើជនជាប់ចោទគឺជានរណា ។ ហើយវាមានផលប្រយោជន៍នៅក្នុងការជំនុំជម្រះ ក្រោមដែននៃការប្តឹងចំពោះបុគ្គល និងមានន័យគ្រប់គ្រាន់ថាជាបណ្តឹងចោទប្រកាន់ជនល្មើស ព្រោះបើគ្មានឈ្មោះជនល្មើសមានន័យថាគ្មានការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌកើតមានឡើង ។

***សេចក្តីសង្ខេបនូវនៅក្នុងអង្គហេតុ៖*** ចំពោះការកំណត់សេចក្តីសង្ខេបអង្គហេតុ គឺមានប្រយោជន៍ដល់ការជំនុំជម្រះត្រង់ដែននៃការប្តឹងចំពោះអង្គហេតុ និងនាំឲ្យយើងដឹងថា បណ្តឹងប្តឹងអំពីអ្វី ព្រោះបើមិនកំណត់អង្គហេតុមានន័យថា ព្រះរាជអាជ្ញាមិនបានចោទប្រកាន់លើអង្គហេតុនោះទេ និយាយឲ្យខ្លីឥតមានបណ្តឹង ។

***ការកំណត់ឈ្មោះបទល្មើសនៅក្នុងទម្រង់នៃដីកា៖*** គឺសំដៅទៅលើបទល្មើសដែលព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ចំពោះជនជាប់ចោទ ចំពោះបទចោទប្រកាន់តុលាការមិនជាប់កាតព្វកិច្ចចំពោះឈ្មោះបទល្មើសដោយសារតុលាការជាប់កាតព្វកិច្ចចំពោះដែននៃការប្តឹងចំពោះអង្គហេតុនិង បុគ្គលតែប៉ុណ្ណោះ ។ ដូច្នេះតុលាការអាចសម្រេចអំពីប្រភេទបទល្មើសផ្សេងដោយសេរីចំពោះអង្គហេតុនោះ លើបុគ្គលនោះ ។

---

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤៦ ។

*អត្ថបទច្បាប់ដែលកំណត់និងបង្ក្រាបបទល្មើស៖* ត្រូវបានសរសេរនៅក្នុងទម្រង់នៃដីកា គឺការកំណត់ទិសដៅកំណត់ពីអ្វី ដែលកំណត់សំដៅទៅលើបទល្មើស ដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ដោយត្រូវតែពឹងផ្អែកទៅលើ តាមមាត្រានៃច្បាប់ ។ ដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំង ទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេល នៃសវនាការផងដែរ ។ ព្រោះការជូនដំណឹងស្តែងឡើងដោយដីកានោះតែម្តង ដោយមិនចាំបាច់មានដីកាកោះហៅចូលសវនាការទេ ដីកានេះត្រូវបញ្ជាក់ថាជនជាប់ចោទអាចពឹងពាក់មេធាវីឲ្យអមខ្លួនបាន ។ ជាបន្តទៅទៀតនេះ យើងខ្ញុំនឹងពន្យល់អំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ តើមានអានុភាពយ៉ាងម៉េច?

**៤.អានុភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ**

ចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ វាបានបង្កើតនូវអានុភាពមួយចំនួនរួមមាន ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស(ក) ការផ្ទេរសមត្ថកិច្ចទៅតុលាការ(ខ) និងការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុនិងជនជាប់ចោទ(គ) ។ តើការផ្តល់អាជ្ញាយុកាលនៃបទល្មើសយ៉ាងម៉េច?

**ក.ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស**

អានុភាពនៃដីកានោះ យើងបាននិយាយរួចទៅហើយ ទាក់ទងនឹងការផ្តាច់អាជ្ញាយុកាលនៃបទល្មើស បណ្តឹងអាជ្ញាមិនអាចធ្វើបានជាដាច់ខាត ការបើកវាផុតអាជ្ញាយុកាលសម្រាប់ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ ។ អាជ្ញាយុកាលចំពោះបទល្មើស នឹងត្រូវបានផ្តល់កាលណាមានកិច្ចចោទប្រកាន់កើតមានឡើង នេះគឺជាសារៈសំខាន់ណាស់ ព្រោះថា បើមិនមានការចែងអំពីចំណុចនេះទេ អាជ្ញាយុកាលមិនត្រូវផ្តាច់ទោះបីមានការចោទប្រកាន់រួចហើយក៏ដោយ ។ ដូច្នេះអាចមានករណីនៅពេលបណ្តឹងបញ្ជូនទៅដល់តុលាការហើយ តែបែរជារំលត់បណ្តឹងអាជ្ញាទៅវិញករណីនេះ តុលាការនឹងសម្រេចឲ្យជននោះរួចខ្លួនទៅវិញ ។ អាជ្ញាយុកាលចាប់រាប់ដោយគិតចាប់ពីពេលដែលប្រព្រឹត្តបទល្មើសដោយរយៈពេល ១៥ឆ្នាំ ចំពោះបទឧក្រិដ្ឋ ៥ឆ្នាំ ចំពោះបទមជ្ឈិម និង ១ឆ្នាំ ចំពោះបទលហុនេះ ។

**ខ.ការផ្ទេរសមត្ថកិច្ចទៅតុលាការ**

អានុភាពនៃដីកានេះ គឺការផ្ទេរសមត្ថកិច្ចទៅតុលាការមានន័យថាយ៉ាងម៉េច? មានន័យថាអង្គការអយ្យការនៅពេលដែលធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់ ការកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាការចោទប្រកាន់មួយរបស់ព្រះរាជអាជ្ញា ដែលជាតំណាងរបស់អង្គការអយ្យការដែរ ។ តាមរយៈដីកានេះ បាននាំអោយមានអវត្តមាននៃកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ តែវាបានផ្ទេរសមត្ថកិច្ចពីអយ្យការទៅយុត្តាធិការជំនុំជម្រះគឺជាការផ្ទេរសមត្ថកិច្ចបាន ។

**គ.ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុនិងជនជាប់ចោទ**

ប្រសិនបើយើងពិនិត្យទៅលើក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ តាមមាត្រា៣៤៨ បានកំណត់អំពីដែនសមត្ថកិច្ចចំពោះអង្គហេតុដែលកំណត់ចំពោះអង្គហេតុនេះ មានន័យថាតុលាការអាចជំនុំជម្រះបានតែអង្គហេតុដែលមាននៅក្នុងដីកាបញ្ជាក់ ។ តុលាការអាចជំនុំជម្រះបាន ត្រឹមអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ តែប៉ុណ្ណោះ ។ ដូចដែលបានឃើញពីការកំណត់ខាងលើ ទម្រង់ការ គឺកំណត់អំពីសេចក្តីសង្ខេប នៃអង្គហេតុនេះឯង ។ តុលាការមិនអាចលើកយកអង្គហេតុទាំងឡាយណា ដែលមិនបានសរសេរនៅក្នុងដីកានោះមកជំនុំជម្រះបាននោះទេ ។ ទោះជាមានការកំណត់អង្គហេតុរួចហើយក៏ដោយ តែជួនកាលមានករណីមួយចំនួន ដែលតុលាការនឹងបង្គាប់ឲ្យបង្វិលសំណុំរឿងឱ្យព្រះរាជអាជ្ញាវិញ ។ ដោយសារករណីបទមជ្ឈិម ឬបទលហុ ត្រូវជំនុំជម្រះដោយចៅក្រមទោល ឯករណីបទឧក្រិដ្ឋចាំបាច់ត្រូវជំនុំជម្រះ ដោយក្រុមសមូហភាពដែលមានចៅក្រមបីរូប ។ ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ ចេញក្នុងករណី ចោទប្រកាន់លើបទមជ្ឈិម ដូចនេះបើតុលាការយល់ឃើញថាជាបទឧក្រិដ្ឋវិញ នោះតុលាការនឹងបង្វិលសំណុំរឿងមកព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ ។ រីឯការកំណត់ ចំពោះសមត្ថកិច្ចនៃការប្តឹងចំពោះបុគ្គលមានន័យថា តុលាការនឹងអាចជំនុំជម្រះ ចំពោះតែជនណាដែលបានចង្អុលឈ្មោះក្នុងដីកានោះតែប៉ុណ្ណោះ ។ តុលាការមិនអាចធ្វើការជំនុំជម្រះ លើជនទាំងឡាយណាដែលមិនមានការចោទប្រកាន់របស់ព្រះរាជអាជ្ញានោះទេ ។ គួរបញ្ជាក់ផងដែរថា ក្នុងករណីការចោទប្រកាន់ធ្វើឡើងដោយ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់វាគ្មានអានុភាពបង្ខំជនជាប់ចោទ ឲ្យចូលសវនាការទេ ជនជាប់ចោទមានសេរីភាពក្នុងការបង្ហាញខ្លួន នៅចំពោះមុខអង្គ សវនាការ ។

**កថាខណ្ឌទី៣៖ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម**

នីតិវិធីបង្ហាញខ្លួនភ្លាម គឺជានីតិវិធីដែលព្រះរាជអាជ្ញាបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការជាន់ដំបូងដោយផ្ទាល់ នីតិវិធីបង្ហាញខ្លួនភ្លាមនេះ គឺជានីតិវិធីដែលមានលក្ខណៈលឿនជាងនីតិវិធីផ្សេងទៀត ព្រោះវាជំរុញដល់ដំណើរការរឿងក្តីព្រហ្មទណ្ឌឲ្យបានឆាប់រហ័ស ជៀសវាងការកកស្ទះសំណុំរឿងនៅក្នុងស្ថាប័នតុលាការ ក៏ដូចជាដើម្បីសម្រួលដល់វិស័យយុត្តិធម៌កម្ពុជាផងដែរ ។ យ៉ាងណាមិញ នីតិវិធីបង្ហាញខ្លួនភ្លាមនេះ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការបំពេញនូវលក្ខខណ្ឌមួយចំនួន ហើយដំណើរការប្រព្រឹត្តទៅស្រប តាមនីតិវិធី និងឈានដល់ការបង្កើតឲ្យមានអានុភាពមួយចំនួន ។ ដូច្នោះ ទាក់ទងទៅនឹង នីតិវិធីនៃការបង្គាប់ឲ្យបង្ហាញខ្លួនភ្លាមនេះ យើងនឹងអាចប្រព្រឹត្តទៅបាន លុះត្រាតែបំពេញលក្ខខណ្ឌដូចខាងក្រោម៖

**១.លក្ខខណ្ឌនៃនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម**

នីតិវិធីនេះ ខុសនីតិវិធីនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម និងក៏អានុភាពនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ដូច្នេះដើម្បីឲ្យស៊ីជម្រៅ និងមានលក្ខណៈលំហូរនៃនីតិវិធី យើងខ្ញុំសុំធ្វើការពន្យល់នូវចំណុចនីមួយនីមួយជាបន្តបន្ទាប់ដូចខាងក្រោម លក្ខខណ្ឌនៃនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម តាមលក្ខខណ្ឌនេះគេកំណត់យ៉ាងដូចម្តេច?

នៅក្នុងនីតិវិធីនេះ ព្រះរាជអាជ្ញាអាចជ្រើសរើសយកនីតិវិធីនៃការចោទប្រកាន់ តាមរយៈការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខ ក្នុងករណីបើមានលក្ខខណ្ឌគ្រប់ដូចខាងក្រោម៖

*-បទល្មើសដាច់ខាតត្រូវតែជាបទមជ្ឈិមជាក់ស្តែង៖* បទល្មើសនេះបានបញ្ជាក់បង្ហាញយ៉ាងច្បាស់នៅក្នុងមាត្រា ៨៦ និងមាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដូច្នោះក្រៅពីបទមជ្ឈិមជាក់ស្តែងព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាមនីតិវិធីនេះបានឡើយ ឬអាចនិយាយម្យ៉ាងទៀតបានថានីតិវិធីមួយ មិនអាចអនុវត្តបានឡើយ ចំពោះករណីបទឧក្រិដ្ឋ ឬបទមជ្ឈិម មិនជាក់ស្តែង ឬបទលហុត ។

*-បទល្មើសនេះ ត្រូវតែផ្តន្ទាទោសដាក់ពន្ធនាគារ យ៉ាងតិច ១ឆ្នាំ និងយ៉ាងច្រើន ៥ឆ្នាំ ៖* ចំពោះបទល្មើសដែលមានការពាក់ព័ន្ធនៅក្នុងការដាក់ពន្ធនាគារ ដែលអ្នកសំដៅទៅលើបទល្មើសមិនមែនបាត់រហូត មិនមែនបទមជ្ឈិមដែលមានការផ្តន្ទាទោស ដែលទោសអតិបរមាតិចជាងមួយឆ្នាំ និងមិនមែនបទឧក្រិដ្ឋនោះទេ គឺសំដៅដល់បទល្មើសមជ្ឈិម ដែលមានទោសអតិបរមាយ៉ាងតិចចំនួន ១ឆ្នាំ និងយ៉ាងច្រើន ៥ឆ្នាំ ។

*-ពិនិត្យទៅលើជនជាប់ចោទជានីតិជន៖* គឺសំដៅទៅលើជនដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ វិធានការបានកម្រិតពីចំណុចជាច្រើន ដែលនាំឲ្យមានការសន្និដ្ឋានថា នីតិវិធីនេះជាវិធានការ ដែលចង់ឲ្យមានការជំនុំជម្រះឲ្យលឿន និងចង់បានវត្តមានជនល្មើសនៅពេលអនុវត្តទោសដោយអនុញ្ញាតឲ្យចៅក្រម អាចសម្រេចឲ្យមានការឃុំខ្លួនជាបណ្តោះអាសន្ន ។ ដូចនេះបើយើងយកអនីតិជនមកប្រើចំពោះនីតិវិធីបែបនេះ ហាក់បីដូចជាគំរាមគោលការណ៍នៃការយកចិត្តទុកដាក់បំផុតចំពោះផលប្រយោជន៍របស់អនីតិជនការទទួលលក្ខខណ្ឌបែបនេះ គឺជាស្មារតីនៃការទទួលស្គាល់សិទ្ធិរបស់អនីតិជន ដោយធានាថាមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពារខ្លួនបានដោយដាក់អនីតិជន ឱ្យជៀសវាងពីការបំពានលើ អនីតិជន ។

*-រឿងក្តីត្រូវតែមានលក្ខណៈគ្រប់គ្រាន់ជម្រះបាន៖* មានន័យយ៉ាងម៉េចដែរ? ថារឿងក្តីហ្នឹងមានលក្ខណៈគ្រប់គ្រាន់ល្មមជម្រះបាន ។ ចំណុចនេះដូចជាការកំណត់របស់ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែរ ដោយសារបើកសំណុំរឿងគ្មានបន្ទុកចោទប្រកាន់គ្រប់គ្រាន់ទេ ព្រះរាជអាជ្ញាមិនគួរធ្វើការចោទប្រកាន់តាមទម្រង់នេះទេ ក្នុងករណីនេះព្រះរាជអាជ្ញាគួរពិចារណាលើការបើកការស៊ើបសួរ ឬស៊ើបអង្កេតឲ្យបានគ្រប់សិន ព្រះរាជអាជ្ញាមិនត្រូវគិតថាមានការស៊ើបអង្កេតណាមួយកើតមាននៅក្នុងពេលជំនុំជម្រះទេ ព្រោះវាអាចជាមូលហេតុ នាំឲ្យជនជាប់ចោទត្រូវបានតុលាការសម្រេចក្តីឱ្យរួចខ្លួន ហើយព្រះរាជអាជ្ញានឹងមិនអាចធ្វើការចោទប្រកាន់សាជាថ្មីចំពោះអំពើដដែលលើជនដោយសារអាជ្ញាអស់ជំនុំ ។

### ២.នីតិវិធីនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

ចំពោះនីតិវិធីនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ចំណុចនេះមានលក្ខណៈពិសេសបន្តិច ពីព្រោះវាទាក់ទងនឹងការចោទប្រកាន់របស់ព្រះរាជអាជ្ញាតាមរយៈនីតិវិធីនៃការបង្ហាញខ្លួនភ្លាម វាមានលក្ខណៈពិសេសប្លែកជានីតិវិធី

ផ្សេងទៀត ពីព្រោះនីតិវិធីនេះត្រូវបានបញ្ញត្តិយ៉ាងច្បាស់លាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ជាក់ស្តែងដោយយោងតាមមាត្រា៤៨ និងមាត្រា៣០៤ នៃក្រមនីតិវិធីនីតិវិធីបង្ហាញខ្លួនភ្លាមនេះត្រូវបានចែកចេញជា២ដំណាក់កាល គឺនីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា(ក) និងនីតិវិធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ(ខ) ។ តើនីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា មានន័យយ៉ាងដូចម្តេច?

**ក.នីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា**

ជាដំហានដំបូង គឺជនជាប់ចោទចាំបាច់ត្រូវតែជាជនដែលត្រូវឃាត់ខ្លួនតាមរយៈមាត្រា៩៦ នៃក្រមនីតិវិធីឆ្នាំ២០០៧ បន្ទាប់ពីផុតរយៈពេលឃាត់ខ្លួនក្រោមការវិនិច្ឆ័យចំពោះមាត្រានេះ ។ ចំពោះរយៈពេលឃាត់ខ្លួននោះព្រះរាជអាជ្ញាសម្រេចឲ្យមានការដោះលែងវិញ ឬព្រះរាជអាជ្ញាសម្រេចឲ្យមានការបញ្ជូនខ្លួនជននោះ ។ ក្នុងករណីដែលបញ្ជូនជននេះមក ព្រះរាជអាជ្ញានឹងសម្រេចថាខ្លួននឹងប្រើនីតិវិធីណាមួយសម្រាប់ចោទប្រកាន់ក្នុងករណីដែលបំពេញលក្ខខណ្ឌគ្រប់គ្រាន់អាចប្រើការបង្ហាញខ្លួនភ្លាមនោះ ព្រះរាជអាជ្ញានឹងធ្វើដូចទៅៈ

- ត្រូវពិនិត្យអត្តសញ្ញាណរបស់ជនដែលត្រូវបានបញ្ជូនមក ធ្វើបែបនេះដើម្បីសម្គាល់ថានរណាជាជនល្មើស ហើយជននោះមានអត្តសញ្ញាណដូចអ្វីដែលបានកំណត់នៅក្នុងកំណត់ហេតុដែលបានកត់ត្រាដែរឬទេ ។
- បន្ទាប់មកទៀត ត្រូវឲ្យដំណឹងដល់ជននេះអំពីរឿងហេតុដែលចោទប្រកាន់និងឈ្មោះបទល្មើស ការទទួលយកបែបនេះព្រោះវាជាសិទ្ធិរបស់ជនជាប់ចោទ ក្នុងការដឹងឮអំពីមូលហេតុដែលគេចាប់ខ្លួនថា ជាស្មារតីលើការទទួលស្គាល់លើសិទ្ធិមនុស្សរបស់ព្រះរាជាណាចក្រកម្ពុជាយើង ។
- បន្តមកទៀតយើង ព្រះរាជអាជ្ញាត្រូវទទួលចម្លើយរបស់បុគ្គលនោះប្រសិនណាបើ សាមីខ្លួនចង់និយាយនេះក៏ជាសិទ្ធសេរីភាពរបស់ជនជាប់ចោទលើការអះអាងគ្រប់បែបយ៉ាងដើម្បីការពារខ្លួន និងលើកយកព័ត៌មានគ្រប់យ៉ាងដែលខ្លួនបានដឹង ជាផលប្រយោជន៍របស់ខ្លួន ។
- បន្ទាប់មកនៅក្នុងនីតិវិធីត្រូវធ្វើ គឺស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ដើម្បីជាការចោទប្រកាន់ទៅតុលាការ ។ ព្រះរាជអាជ្ញាត្រូវចេញកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម រួចបញ្ជូនទៅតុលាការជាន់ដំបូងដើម្បីចាត់តាំងចៅក្រមជំនុំជម្រះ នៅក្នុងអង្គសវនាការ ។ ក្នុងកំណត់ហេតុនេះ ចាំបាច់ត្រូវតែមានការចែង នៅចំណុចដែលព្រះរាជអាជ្ញាបានប្រាប់ជនជាប់ចោទអំពីសិទ្ធិក្នុងការពឹងពាក់មេធាវីដែលអាចជ្រើសរើសដោយខ្លួនឯង ឬចាត់តាំងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ ក្នុងករណីមេធាវីទៅទទួលដំណឹងភ្លាម ដើម្បីទទួលស្គាល់នូវសិទ្ធិ វាមានរយៈពេលគ្រប់គ្រាន់ដើម្បីការការពារខ្លួនរបស់ជនជាប់ចោទ ។

ទម្រង់ការដែលរៀបរាប់ខាងលើត្រូវទៅចុះនៅក្នុងកំណត់ហេតុ បើមិនដូចនេះទេនីតិវិធីត្រូវចាត់ទុកជាមោឃៈ ។ នៅពេលដែលកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមត្រូវបានធ្វើចប់សព្វគ្រប់ហើយ ជនជាប់ចោទ

នឹងត្រូវឃាត់ទុកដោយកងកម្លាំងការពារ និងបញ្ជូនជននោះព្រមទាំងសំណុំរឿងទៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅថ្ងៃនោះតែម្តង ។

**ក.នីតិវិធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ**

បន្ទាប់ពីតុលាការជាន់ដំបូង ទទួលបណ្តឹងទៅតាមរយៈកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមតុលាការនឹងៈ

- ផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទឲ្យច្បាស់លាស់ ហើយធ្វើរបាយការណ៍សង្ខេបអំពីអង្គហេតុដែលចោទប្រកាន់ តុលាការប្រាប់ដល់ជនជាប់ចោទថាខ្លួនអាចមានរយៈពេលសម្រាប់ការពារខ្លួនបន្ថែមទៀត ។ ក្នុងករណីដែលជននោះ សុំរយៈពេលការពារខ្លួននោះ ឬតុលាការយល់ឃើញថារឿងក្តីនោះមិនអាចទាន់ជំនុំជម្រះបានទេ ។
- តុលាការ អាចលើកទៅជំនុំជម្រះនៅពីក្រោយខ្នង ករណីនេះតុលាការអាចសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន ។ ដោយសារតែមានសំអាងហេតុដែលត្រូវសម្អាងនេះ គឺជាមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដូចតទៅ

១-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី ។

២-ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ។

៣-ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ។

៤-ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ។

៥-ដើម្បីការពារសន្តិភាពសន្តិសុខឲ្យជនត្រូវចោទ ។

៦-ដើម្បីធានាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានភាពច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស ។

តុលាការក៏ទាមទារក្នុងការចេញដីកាបង្គាប់ ឲ្យឃុំខ្លួនដែរ ព្រោះដីកាសម្រេចពីការឃុំខ្លួនបណ្តោះអាសន្នមានអានុភាពតែទៅលើជនជាប់ចោទនេះតែប៉ុណ្ណោះ ។ ឯដីកាបង្គាប់ឲ្យឃុំខ្លួន មានអានុភាពជាការបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួលយកនិងឲ្យឃុំខ្លួនជននោះ ។ សាលក្រមលើអង្គហេតុ ត្រូវតែប្រកាសក្នុងរយៈពេលដែលមិនអាចលើសពី ២សប្តាហ៍ គិតពីពេលដែលបង្ហាញខ្លួន នៅចំពោះមុខតុលាការ ការឃុំខ្លួនជាបណ្តោះអាសន្ន ក្រោយបញ្ចប់ដោយពេញច្បាប់ ។ ក្រោយផុតរយៈពេលនេះ មានន័យថាជនជាប់ចោទនឹងត្រូវដោះលែងឲ្យមានសេរីភាព ព្រោះវិធានការឃុំខ្លួនបណ្តោះអាសន្ន ជាវិធានការដែលបំពានដល់សិទ្ធិសេរីភាពរបស់មនុស្សយ៉ាងខ្លាំង ហើយម្យ៉ាងទៀត ជននេះមិនទាន់ត្រូវបានផ្តន្ទាទោសដោយតុលាការទេ ។ ការឃុំខ្លួនរបស់នីតិ

វិធីនេះទាមទារនូវរយៈពេលកំណត់មួយដែរ ព្រោះដើម្បីធានាថាមិនមានការបំពានណាមួយហួសហេតុដល់សេរីភាពរបស់ជននោះ ទោះដោយសារការជំនុំជម្រះ ។

**៣.អានុភាពនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម**

ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម គឺជានីតិវិធីចោទប្រកាន់ដែលស្តែងឡើងដោយកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម កំណត់ហេតុនេះវាមានអានុភាពដូចតទៅ

**ក.ការផ្តាស់អាជ្ញាយុកាលនៃបទល្មើស**

ការចេញកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ដោយព្រះរាជអាជ្ញា គឺជាការចោទប្រកាន់ជនល្មើស ។ ដូច្នោះ កិច្ចចោទប្រកាន់នេះ វាមានអានុភាពផ្តាច់អាជ្ញាយុកាលនៃបទល្មើសព្រហ្មទណ្ឌ ។ មូលហេតុដែលនាំឲ្យមានការផ្តាច់អាជ្ញាយុកាល គឺដូចគ្នានឹងដីកាកោះហើយបញ្ជូនទៅជំនុំជម្រះផ្ទាល់នឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែរ ។

**ខ.ការផ្ទេរសមត្ថកិច្ចរបស់តុលាការ**

ការផ្ទេរសមត្ថកិច្ចពីអយ្យការមកយុត្តាធិការជំនុំជម្រះ គឺតាមរយៈកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា តុលាការគ្មានសមត្ថកិច្ចលើការជំនុំជម្រះ ដរាបណាមានកិច្ចចោទប្រកាន់មកលើខ្លួន អានុភាពមួយទៀតនៅក្នុងការបង្គឲ្យចូលបង្ហាញខ្លួនភ្លាម ។

**គ.ចំណាចតុលាការចំពោះដែនបណ្តឹង ចំពោះអង្គហេតុ និងបុគ្គល**

កំណត់ហេតុ ស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា គឺមានការកំណត់ពីអង្គហេតុ និងពីបុគ្គលដែលព្រះរាជអាជ្ញាចង់ធ្វើការចោទប្រកាន់ទៅលើ ។ ដូច្នេះ តុលាការអាចជំនុំជម្រះបានទៅលើអង្គហេតុណាដែលមានចែងក្នុងកំណត់ហេតុនោះ អះអាងជំនុំជម្រះទៅលើជនណាដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់បានតែប៉ុណ្ណោះ ។

យើងខ្ញុំសុំបញ្ចប់ ចំពោះអំណាចនៃការចោទប្រកាន់របស់អយ្យការ និងជាបន្តទៅទៀត យើងខ្ញុំចូលដល់ជំពូកទី៤ ៖ **អយ្យការក្នុងដំណើរការនៃការអនុវត្តទោស** ។

# ជំពូកទី៤.
# អយ្យការក្នុងដំណើរការនៃការអនុវត្តទោស

ក្រោយសេចក្ដីសម្រេច ឬសាលក្រមរបស់តុលាការ បានក្លាយទៅជាស្ថាពរហើយនោះ ដែលតំណាងអយ្យការត្រូវតែធ្វើការអនុវត្តទោស ។ ចំពោះការអនុវត្តទោសដទៃទៀតសោត ព្រះរាជអាជ្ញានិងអគ្គព្រះរាជអាជ្ញាអាចសុំកងកម្លាំងសាធារណៈ ដើម្បីធានារ៉ាប់រងក្នុងការអនុវត្តទោស ។[47] ករណីដែលភាគីណាមួយមិនសុខចិត្តនឹងសេចក្ដីសម្រេច ឬសាលក្រមមិនទាន់ចូលជាស្ថាពរ អាចធ្វើការប្ដឹងតវ៉ា នោះបុគ្គលដែលអាចប្ដឹងឧទ្ធរណ៍បានមានដូចជា៖

- ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដំបូង
- ពិរុទ្ធជន
- ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ចំពោះផលប្រយោជន៍រដ្ឋប្បវេណី ។[48]

រយៈពេលនៃការប្ដឹងទៅឧទ្ធរណ៍នេះ ដើមបណ្ដឹងរដ្ឋប្បវេណី ដឹងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើការប្ដឹងក្នុងរយៈពេល១ខែ គិតចាប់ពីពេលក្រោយប្រកាសសាលក្រមចំពោះសាលក្រមចំពោះមុខ និង ១ខែ គិតពីពេលទទួលដំណឹងសាលក្រម ចំពោះសាលក្រមចាត់ទុកជាចំពោះមុខ ។[49] រីឯ រយៈពេលនៃការប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល ១ខែ នឹងការប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើឡើងក្នុងរយៈពេល ៣ខែ គិតចាប់ពីពេលដែលប្រកាសសាលក្រម ។ ប៉ុន្ដែប្រសិនបើភាគីណាមួយមិនបានធ្វើបណ្ដឹងឧទ្ធរណ៍ ក្នុងរយៈពេល ១ខែ នោះទេនាំឲ្យសាលក្រមរបស់តុលាការ ចូលជាស្ថាពរហើយព្រះរាជអាជ្ញានឹងធ្វើការអនុវត្តទោស ចំពោះទណ្ឌិតតាមសាលក្រមស្ថាពរ ។ ចំពោះនីតិវិធីនៃការអនុវត្តទោសនេះត្រូវបានបែងចែកជា ២គឺ **វិធានការនឹងការឃុំខ្លួន និងការដោះលែង(ផ្នែកទី១) ការផ្ដល់នីតិសម្បទាឡើងវិញ(ផ្នែកទី២) ។**

## ផ្នែកទី១៖ ការឃុំខ្លួន និងការដោះលែង

### កថាខណ្ឌទី១៖ វិធានការទាក់ទងនឹងការឃុំខ្លួន

ជាគោលការណ៍ ការឃុំខ្លួនបុគ្គលណាម្នាក់ជាដាច់ខាតត្រូវតែមានលិខិតដែលចេញដោយអាជ្ញាធរតុលាការ ។ មានន័យថាមុននឹងទទួលយកជនជាប់ឃុំចូលពន្ធនាគារ ប្រធានពន្ធនាគារ ឬមន្ដ្រីពន្ធនាគារ ដែលទទួលការ

---

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤៩៩ ។

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៣៧៥ ។

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៣៨២ ។

ចាត់តាំង ត្រូវត្រួតពិនិត្យ អត្តសញ្ញាណរបស់ជនជាប់ឃុំឱ្យបានត្រឹមត្រូវ តាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ ។[50] ប្រសិនបើភ្នាក់ងាររដ្ឋបាលពន្ធនាគារណា ដែលទទួលនឹងឃុំខ្លួនបុគ្គលណាម្នាក់ ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការនោះទេ ត្រូវជាប់ពិរុទ្ធពីបទបង្ខាំងមនុស្សដោយខុសច្បាប់ ។[51] ដោយផ្អែកតាមមាត្រា ៥០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានបញ្ញត្តិអំពីថិរវេលានៃការដាក់ពន្ធនាគារដែរ ។ ដោយទោសដាក់ពន្ធនាគារក្នុង ១ថ្ងៃ មានថិរវេលាម្ភៃ ២៤ម៉ោង ទោសដាក់ពន្ធនាគារ ក្នុង ១ខែ មានថិរវេលា ៣០ថ្ងៃ និងទោសដាក់ពន្ធនាគារលើសពី ១ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទីមួយ និងលេខរៀងនៃថ្ងៃក្នុងខែមួយទៀត ។ ចំណែកឯទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយត្រូវបានដោះលែង ក្នុងចន្លោះពី ម៉ោង ៩ព្រឹក ដល់ម៉ោង ១៨ល្ងាច ។

**១.ការគ្រប់គ្រងពន្ធនាគារ**

គោលដៅជាសារវន្តនៃការគ្រប់គ្រងបុគ្គលិក ជនជាប់ឃុំ គឺការអប់រំកែប្រែ និងស្តារនីតិសម្បទារបស់ជនជាប់ឃុំ ដែលជាស្នូលនៃក្របខ័ណ្ឌគោលនយោបាយ គោលការណ៍កំណែទម្រង់ពន្ធនាគារ[52] ហើយក្នុងការដាក់វិន័យដោយជនជាប់ឃុំត្រូវបានធ្វើឡើងក្នុងកម្រិតអប្បបរមា ដែលចាំបាច់ដើម្បីធ្វើការធានាសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់ប៉ុណ្ណោះ ។ ប្រធានពន្ធនាគារ ត្រូវទទួលខុសត្រូវក្នុងការអនុវត្តនីតិវិធី និងបទបញ្ជាផ្ទៃក្នុង នៅក្នុងពន្ធនាគារពន្ធនាគារនីមួយៗត្រូវមានបញ្ជីជនជាប់ឃុំ ដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ជនជាប់ឃុំ ហើយចុះក្នុងព្រឹត្តិការណ៍ ដោយតំណាងអយ្យការ នៅគ្រប់ទំព័រ ។[53] ចំពោះជនជាប់ឃុំ ជាស្ត្រី និងជនជាប់ឃុំ ជាអនីតិជន ត្រូវមានបញ្ជីដោយឡែកហើយត្រូវយកចិត្តទុកដាក់ ជាពិសេសដល់ការគ្រប់គ្រងជនជាប់ឃុំទាំងពីរភេទនេះ ។ យ៉ាងណាមិញចំពោះការត្រួតពិនិត្យបញ្ជី ជនជាប់ឃុំត្រូវបានធ្វើឡើងដោយតំណាងអយ្យការ ។ តំណាងអង្គការអយ្យការ និងត្រូវជូនទៅចៅក្រមដើម្បីពិនិត្យមើលតាមការស្នើសុំ និងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលបានបំពេញភារៈកិច្ច តាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។[54] លើសពីនេះទៅទៀត ការបញ្ជូនទណ្ឌិតពីពន្ធនាគារមួយ ទៅពន្ធនាគារមួយទៀត ប្រធានពន្ធនាគារត្រូវតែមាន ការអនុញ្ញាតពី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងជូនដំណឹងភ្លាមៗ ឬយ៉ាងយូរបំផុត ៣ថ្ងៃ ទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងសមត្ថកិច្ចខាង

[50] សទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ (រៀបចំដោយគណៈកម្មាការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ , បោះពុម្ពលើកទី១ ឆ្នាំ២០១១ ទំព័រទី៧០ ។

អាជ្ញាធរតុលាការ = អ្នកកាន់អំណាចតុលាការ មានចៅក្រមតុលាការ ចៅក្រមអយ្យការ ។

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥០៦ ។

[52] ច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១ ប្រកាសឱ្យប្រើថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មាត្រា ៤២ ។

[53] ច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១ ប្រកាសឱ្យប្រើថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មាត្រា ២១ ។

[54] ច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១ ប្រកាសឱ្យប្រើថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មាត្រា ២២ ។

ដែនដីទទួល ។ ដូចគ្នាដែរ និងការផ្ទេរជនជាប់ឃុំក្រៅពីទណ្ឌិត ពីពន្ធនាគារមួយ ទៅពន្ធនាគារមួយទៀត ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីទទួល ឬ អគ្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចកំពុងចាត់ការរឿងក្តីក្នុងករណីចាំបាច់នៃការផ្ទេរជនជាប់ឃុំ ក្រោយពីទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាអាចចេញដីកាបង្គាប់ឲ្យផ្ទេរតាមតម្រូវការនៃនីតិវិធី ។[55] ក្នុងករណីដែល គ្រប់ឧប្បត្តិហេតុធ្ងន់ធ្ងរដែលបានកើតឡើងដូចជាជនជាប់ឃុំ លួចរត់គេចចេញពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួន នោះប្រធានពន្ធនាគារក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ច ត្រូវធ្វើការជូនដំណឹងពីរឿងនេះជាបន្ទាន់ ទៅគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត ទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារជាពិសេសត្រូវជូនដំណឹងជាបន្ទាន់ទៅ ទីណាដែលមានសមត្ថកិច្ចខាងដែនដី ដើម្បីឲ្យព្រះរាជអាជ្ញាចេញបញ្ជាស្វែងរកចាប់ខ្លួន ដោយអនុលោមតាមបញ្ញត្តិដែលចែងក្នុងមាត្រា១៩៦ (ដីកាបង្គាប់ឲ្យចាប់ខ្លួន) និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។[56] ទន្ទឹមនឹងនេះផងដែរ ប្រធានពន្ធនាគារត្រូវរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាគណៈអភិបាលរាជធានី-ខេត្ត និងអគ្គនាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធនាគារ អំពីព័ត៌មានឬឧប្បត្តិហេតុទាំងឡាយណាដែលគំរាមកំហែងឬអាចគំរាមកំហែងដល់សន្តិសុខសុវត្ថិភាពពន្ធនាគារ ។

**២.ការធ្វើអធិការកិច្ចពន្ធនាគារ**

ចំណែកឯការធ្វើអធិការកិច្ចពន្ធនាគារវិញនោះ ដោយអនុលោមតាមមាត្រា៥០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចលើពន្ធនាគារជាប្រចាំ ។ យន្តការបង្ការថ្នាក់ជាតិ ត្រូវបានអនុញ្ញាតឲ្យធ្វើទស្សនកិច្ចតាមពន្ធនាគារនានា គ្រប់ពេលវេលា និងធ្វើការសម្ភាសជាសម្ងាត់ជាមួយនឹងជនជាប់ឃុំ ដើម្បីអាចត្រួតពិនិត្យមើលលក្ខខណ្ឌនៃការឃុំខ្លួន និងការប្រព្រឹត្តចំពោះជនជាប់ឃុំ ផ្តល់អនុសាសន៍កែលម្អ សំដៅបង្ការទារុណកម្មអំពើឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក ។[57] ការចុះពិនិត្យពន្ធនាគារ ជនដែលអាចចូលក្នុងពន្ធនាគារបានមានដូចជា៖

- តំណាងព្រះមហាក្សត្រ
- សមាជិករដ្ឋសភាជាតិ
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

---

55 ច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១ ប្រកាសឱ្យប្រើថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មាត្រា ៦២ ។

56 ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥១១ ។

57 ច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១ ប្រកាសឱ្យប្រើថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មាត្រា ៥៤ ។

- ជនទាំងឡាយដែលអនុញ្ញាតពីក្រសួងមហាផ្ទៃ
- ចៅក្រម ឬព្រះរាជអាជ្ញា
- អភិបាលខេត្តក្រុង
- ជនណាម្នាក់ឬអង្គការណាមួយដែលទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីប្រធានពន្ធនាគារ ។

**កថាខណ្ឌទី២៖ ការដោះលែងដោយមានលក្ខខណ្ឌ**

ដាក់ស្តែង មាត្រា ៧៩ នៃច្បាប់ស្តីពីពន្ធនាគារ បានចែងថា គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវបានដោះលែងដែលមានលក្ខខ័ណ្ឌ ។ ប្រសិនបើទណ្ឌិត បានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទា ដែលអាចបញ្ចូនខ្លួនទៅក្នុងសង្គមវិញបាន ។ ចំណុចត្រង់នេះបញ្ជាក់ឲ្យឃើញថា ការដោះលែងទណ្ឌិតនេះអាចប្រព្រឹត្តទៅបាន លុះត្រាតែ ទណ្ឌិតដែលត្រូវទទួលទោស មានការកែប្រែចិត្តគំនិត អត្តចរិត ក៏ដូចជាគំនិតមាយាទ ដែលរាងចាលលែងប្រព្រឹត្តបទល្មើសផ្សេងៗ តទៅទៀត ។ លើសពីនេះទៅទៀត បន្ទាប់ពីប្រធានពន្ធនាគារទទួលបានលិខិតសម្រេចពីអាជ្ញាធរតុលាការរួចមកនោះប្រធានពន្ធនាគារត្រូវធ្វើការដោះលែងជនដែលជាប់ ជាគោលការណ៍ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបានបញ្ចប់ពី ថ្ងៃសៅរ៍ឬថ្ងៃអាទិត្យឬថ្ងៃឈប់សម្រាកផ្សេងៗទៀត ដែលត្រូវបានកំណត់ដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្ត ត្រូវតែធ្វើការដោះលែងឲ្យមានសេរីភាពវិញ នៅមុនថ្ងៃដែលឈប់សម្រាកនោះ ។[58] អ្នកទោសដែលត្រូវបានដោះលែងជាបន្ទាន់ ក្នុងកាលៈទេសៈដូចតទៅ៖

- នៅពេលផុតកំណត់ទោស
- នៅពេលអនុញ្ញាតឲ្យដាក់ប្រាក់ធានាឲ្យនៅក្រៅឃុំដោះលែងដែលមានលក្ខខណ្ឌដោះលែងបណ្តោះអាសន្ន
- នៅពេលលើកលែងការចោទប្រកាន់
- នៅពេលនិរទេសខ្លួន ឲ្យអាជ្ញាធរមានសមត្ថកិច្ច ដោយការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់តុលាការ មានសមត្ថកិច្ចនៅពេលលើកលែងទោសដល់ព្រះមហាក្សត្រ ចំពោះទោសដែលនៅសេសសល់ ។

**១.លក្ខខណ្ឌផ្សេងៗក្នុងការដោះលែងទណ្ឌិត**

ដូចដែលបានរៀបរាប់ពីខាងលើរួចហើយ ការដោះលែងទណ្ឌិតអាចធ្វើទៅ លុះត្រាតែបានគោរពនូវលក្ខខណ្ឌមួយចំនួនដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ទើបទណ្ឌិតអាចត្រូវបានដោះលែងឲ្យមានសេរីភាពវិញ ។ ការដោះលែងទណ្ឌិតដោយមានលក្ខខណ្ឌនេះ ត្រូវបានបែងចែកជា ២ លក្ខខណ្ឌ មានដូចជា៖

**ក.លក្ខខណ្ឌទាក់ទងទៅនឹងគំនិតមារយាទ**

[58] ច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១ ប្រកាសឱ្យប្រើថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មាត្រា ៨០ ។

សំដៅលើគ្រប់ទណ្ឌិតដែលត្រូវបានទទួលទោសឬច្រើន ដែលត្រូវបានទទួលទោសមួយឬច្រើនអាចត្រូវបានដោះលែង ដោយមានលក្ខខណ្ឌប្រសិនបើទណ្ឌិតនោះបានបង្ហាញឲ្យឃើញថាខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ជូនខ្លួនទៅក្នុងសង្គមវិញបាន ។[59]

**ខ.លក្ខខណ្ឌទាក់ទងនឹងថេរៈវេលានៃទោសដែលត្រូវទទួលរួចហើយ**

សម្រាប់លក្ខខណ្ឌនៃការដោះលែង អាចត្រូវបានផ្តល់ឲ្យដល់ទណ្ឌិត ដែលទទួលរងទោសជាប់ពន្ធនាគារចំនួនពាក់កណ្តាលនៃទោស ប្រសិនបើទោសនោះ អាចតិចជាង ឬ ស្មើ ១ឆ្នាំ ចំនួន ២/៣ នៃទោស ។ ក្នុងករណីផ្សេងទៀត រីឯទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត អាចទទួលការដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតបានទទួលទោសជាប់ពន្ធនាគារយ៉ាងតិចបំផុត ២០ឆ្នាំ រួចមកហើយ ។[60] ហេតុនេះ អាជ្ញាធរមានសមត្ថកិច្ចសម្រាប់ផ្តល់ការលែងលះ ដែលមានលក្ខខណ្ឌទាំងពីរខាងលើនេះ ត្រូវផ្តល់ដោយ ប្រធានតុលាការជាន់ដំបូងនៃទីតាំងឃុំបន្ទាប់ពីប្រធានតុលាការ សម្រេចក្រោយពីការទទួលយោបល់ ពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌ ។

**២.សេចក្តីសម្រេចទាក់ទងទៅនឹងការដោះលែងដោយមានលក្ខខណ្ឌ**

ជាទូទៅ បន្ទាប់ពីទទួលបានយោបល់ ពីគណៈកម្មការជាតិរួចហើយ ប្រធានតុលាការសម្រេចដាក់តាមដីកាដោយមានសំអាងហេតុ ហើយសេចក្តីសម្រេចរបស់ប្រធានតុលាការនេះដែរ អាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល ៥ថ្ងៃ ។ ចំពោះបណ្តឹងតវ៉ា គឺមានតែអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឬព្រះរាជអាជ្ញានៃតុលាការសាមីតែប៉ុណ្ណោះ ដែលអាចធ្វើបណ្តឹងទាស់នេះបាន ។ នៅពេលដែល សេចក្តីសម្រេចរបស់ប្រធានតុលាការជាន់ដំបូង បង្គាប់ឲ្យដោះលែងដោយមានលក្ខខណ្ឌ នាំឲ្យសេចក្តីសម្រេចនោះ គ្មានអានុភាពអនុវត្តទេ នៅក្នុងរយៈពេល ៥ថ្ងៃ ។ បន្ទាប់ពីចេញសេចក្តីសម្រេច ប្រសិនបើមានការតវ៉ាសេចក្តីសម្រេចនេះគ្មានអនុភាពទេ រហូតដល់មានដីការបស់ប្រធានសាលាឧទ្ធរណ៍ ។ នេះបញ្ជាក់ឲ្យឃើញថា ប្រសិនបើគ្មានបណ្តឹងតវ៉ានោះទេសេចក្តីសម្រេចមានអានុភាពចាប់ពីពេលផុតរលត់ រយៈពេល ៥ថ្ងៃ នៃការតវ៉ា ។ ប៉ុន្តែករណីមានការប្តឹងតវ៉ាទៅប្រធានសាលាឧទ្ធរណ៍ សេចក្តីសម្រេចនេះគ្មានអានុភាពទៀតឡើយ ហើយសេចក្តីសម្រេចនឹងមានអានុភាពវិញ នៅពេលមានដីការបស់ប្រធានសាលាឧទ្ធរណ៍ ។[61] គួរកត់សម្គាល់ផងដែរថា ក្រោយពីបានទទួលយោបល់ពីគណៈកម្មការជាតិរួចមក ប្រធានតុលាការ ត្រូវសម្រេចតាមដីកាដែលមានសំអាងហេតុ ទើបព្រះរាជអាជ្ញា ចេញដីកាមួយប្រភេទ

---

[59] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥១២ ។

[60] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥១៣ ។

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥១៦ ។

ដែលត្រូវបានគេហៅថា "ដីកាដោះលែងទណ្ឌិត" ។ ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញានៃតុលាការនៃតុលាការសាមុី អាចបង្គាប់ឲ្យចាប់ខ្លួនទណ្ឌិត ដែលបានដោះលែងនោះបាន ដោយព្រះរាជអាជ្ញា ត្រូវជូនដំណឹងដល់ប្រធានតុលាការជាន់ដំបូងភ្លាម ។[62]

## ផ្នែកទី២៖ ការបង្ខំដល់រូបកាយ និងការផ្តល់នីតិសម្បទាឡើងវិញ

### កថាខណ្ឌទី១៖ ការបង្ខំលើរូបកាយការបង្ខំ

រូបកាយត្រូវអនុវត្តដោយពេញលក្ខណៈច្បាប់ ទៅលើបុគ្គលដែលផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ដោយមិនបង់ប្រាក់ពិន័យ ប្រាក់ពន្ធ នៃនីតិវិធី និងប្រាក់សំណងជំងឺចិត្ត ដែលត្រូវបង់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។ ពោលគឺប្រសិនបើទណ្ឌិត មិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធធនាគារ ឬប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគាជូនដំណឹងដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង ។ ក្រៅពីនេះទៀត ព្រះរាជអាជ្ញា កំណត់រយៈពេលចុងក្រោយដល់ ទណ្ឌិត ដែលរយៈពេលនេះ មិនអាចតិចជាង ១០ថ្ងៃទេ ដើម្បីនង់ប្រាក់នោះហើយ ត្រូវជូនដំណឹងថា ប្រសិនបើខ្លួនមិនបង់ទេនោះសាមុីខ្លួន ត្រូវបង្ខំដល់រូបកាយ ។ ការឲ្យជាដំណឹងនេះ ត្រូវតែធ្វើកំណត់ហេតុស្តីពីការឲ្យដំណឹង ហើយការធ្វើដំណើរនេះទៀតសោត អាចធ្វើទៅបានតាមរយៈ៖

- ដោយផ្ទាល់មាត់
- ឬតាមផ្លូវរដ្ឋបាល
- ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។[63]

ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់តាមរយៈពេលដែលបានកំណត់ទេ ព្រះរាជអាជ្ញាចេញបញ្ជាឲ្យបង្ខំ និងឃុំខ្លួនដោយមានចុះហត្ថលេខា ដោយព្រះរាជអាជ្ញាផ្ទាល់ និងបានបោះត្រាផងដែរ ។ ព្រះរាជអាជ្ញាអាចបង្អង់សេចក្តីសម្រេចនេះបាន ដោយមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជា៖ ស្ថានភាពនៃសុខភាពរបស់ទណ្ឌិត ។[64] ការចុះអន្តរាគមន៍បែបនេះ ព្រះរាជអាជ្ញាអាចសុំឲ្យកម្លាំងសាធារណៈ ចាប់ និងឃុំខ្លួនទណ្ឌិត ។

#### ១.ថិរវេលានៃការបង្ខំ

អនុលោមតាម ក្រមនីតិវិធីព្រហ្មទណ្ឌ ថិរវេលានៃការបង្ខំ ដែលរូបគេត្រូវបានកំណត់ដូចតទៅ៖

- ១០ (ដប់) ថ្ងៃ កាលណាទឹកប្រាក់ដែលបង់នោះមានចំនួនមិនលើសពី ២៥០.០០០ (ពីរសែនប្រាំម៉ឺន) រៀល ។

[62] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥១៩ ។

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥២៥ ។

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥២៦ ។

- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើទឹកប្រាក់នោះចំនួន ២៥០.០០១ (ពីរសែនប្រាំម៉ឺនមួយ) រៀល ដល់ ៥០០.០០០ (ប្រាំសែន) រៀល ។
- ១ (មួយ) ខែ ប្រសិនបើទឹកប្រាក់ចំនួន ៥០០.០០១ (ប្រាំសែនមួយ) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ។
- ២ (ពីរ) ខែ ប្រសិនបើទឹកប្រាក់នេះចំនួន ១.០០០.០០១ (មួយលានមួយ) រៀល ដល់ ២.៥០០.០០០ (ពីរលានប្រាំសែន) រៀល ។
- ៣ (បី) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួន ២.៥០០.០០១ (ពីរលានប្រាំសែនមួយ) រៀល ដល់ ៥.០០០.០០០(ប្រាំលាន) រៀល ។
- ៦ (ប្រាំមួយ) ខែ ប្រសិនបើទឹកប្រាក់នោះមានចំនួន ៥.០០០.០០១ (ប្រាំលានមួយ) រៀល ដល់ ១០.០០០.០០០(ដប់លាន) រៀល ។
- ១ (មួយ) ឆ្នាំ ប្រសិនបើទឹកប្រាក់នោះមានចំនួន ១០.០០០.០០១ (ដប់លានមួយ) រៀល ដល់ ២០.៥០០.០០០ (ម្ភៃលានប្រាំសែន) រៀល ។
- ១៨ (ដប់ប្រាំបី) ខែ ប្រសិនបើទឹកប្រាក់នោះមានចំនួន ២០.៥០០.០០១ (ម្ភៃលានប្រាំសែនមួយ) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ។
- ២ (ពីរ) ឆ្នាំ ប្រសិនបើទឹកប្រាក់នោះមានចំនួនលើសពី ៥០.០០០.០០០ (ហាសិបលាន) រៀល ។[65]

កាលណាការបង្ខំលើរូបកាយ ការធានាឥណទេយ្យ ច្រើននោះថេរៈវេលានៃការបង្ខំនោះ ត្រូវកំណត់ដោយគិតគូរតាមចំនួនសរុបនៃទណ្ឌកម្ម ។

**២.ការរួចខ្លួនពីការបង្ខំលើរូបកាយ**

ជាការពិតណាស់ការបង្ខំ ដែលគេមិនអាចធ្វើទៅលើទណ្ឌិត ដែលជាអនីតិជននៅពេលប្រព្រឹត្តបទល្មើសទៅលើស្ត្រីដែលមានអាយុចាប់ពី ៦៥ឆ្នាំ ឡើងទៅ និងធ្វើទៅលើបុរស ចាប់ពី ៧០ ឆ្នាំឡើង ។ មួយវិញទៀតនោះ ការបង្ខំរូបកាយមិនអាចធ្វើបានព្រមជាមួយគ្នា ទៅលើប្តី ប្រពន្ធ បាននោះទេ ទោះបីជាការបង្ខំនោះធ្វើឡើងដើម្បីប្រមូលធនទណ្ឌ ផ្សេងគ្នាក៏ដោយ ។[66]

**កថាខណ្ឌទី២៖ ការផ្តល់នីតិសម្បទាឡើងវិញ**

ជាទូទៅ ចំពោះបុគ្គលទាំងឡាយ ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ហើយត្រូវបានប្រកាស

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥៣០ ។

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥៣១ ។

ផ្តន្ទាទោសស្ថាពរដោយតុលាការ បុគ្គលទាំងនោះនឹងត្រូវបាត់បង់នូវនីតិសម្បទាមួយចំនួន ទៅតាមប្រភេទនៃទណ្ឌកម្មព្រហ្មទណ្ឌ ដែលបានទទួលរងចំពោះបទល្មើស ដែលខ្លួនបានប្រព្រឹត្តនោះ ។ មិនត្រឹមតែប៉ុណ្ណោះ ក្រៅពីទណ្ឌកម្មព្រហ្មទណ្ឌ ក៏មានការកត់ត្រាអំពីប្រវត្តិឧក្រិដ្ឋភាពនៃបុគ្គលនោះ ដោយការចុះនៅក្នុងបញ្ជីថ្កោលទោសជាអាទិ៍ផងដែរ ទោះបីជា បន្ទាប់ពីពួកគេបានអនុវត្តទោសព្រហ្មទណ្ឌនោះចប់សព្វគ្រប់ក៏ដោយ ។ ហេតុដូចនេះ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ថាតើមានលក្ខខណ្ឌអ្វីខ្លះដែលអាចផ្តល់ និងស្តារឱ្យមាននីតិសម្បទាឡើងវិញបាន? ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ គឺជាការស្តារឡើងវិញនូវលក្ខណៈសម្បត្តិតាមផ្លូវច្បាប់ផ្តល់ជូនដល់ទណ្ឌិត (បុគ្គលដែលត្រូវបានប្រកាសផ្តន្ទាទោសស្ថាពរ ដោយតុលាការព្រហ្មទណ្ឌ) ដែលបានអនុវត្តទោសចប់ជាស្ថាពររួចហើយ ដើម្បីឱ្យបុគ្គលនោះមានសមត្ថភាព និងសិទ្ធិសេរីភាពពេញលេញតាមច្បាប់ឡើងវិញ ព្រមទាំងផ្តល់ឱ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការសមាហរណកម្មចូលទៅរួមរស់នៅក្នុងសង្គមវិញបាន ។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ អាចត្រូវបានធ្វើឡើងតាម ២លក្ខខណ្ឌគឺ តាមរយៈផ្លូវតុលាការ និងការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់។

**១.ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ**

នេះជាលក្ខខណ្ឌពិសេសមួយ ដែលកំណត់ដោយច្បាប់ ដែលអនុញ្ញាតឱ្យទណ្ឌិតទាំងឡាយណា ដែលបានអនុវត្តទោសរួចរាល់ហើយ អាចធ្វើការដាក់ពាក្យសុំឱ្យតុលាការចេញសេចក្តីសម្រេច ប្រកាសផ្តល់ឱ្យមាននីតិសម្បទាឡើងវិញបាន ។ ការផ្តល់ឱ្យមាននីតិសម្បទាឡើងវិញតាមផ្លូវតុលាការ អាចត្រូវបានផ្តល់ឱ្យ ឬមិនផ្តល់ឱ្យដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមានការប្រកាសផ្តន្ទាទោស ដោយតុលាការនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍នេះ ។ ឧទាហរណ៍៖ ទណ្ឌិត "ក" ត្រូវបានប្រកាសផ្តន្ទាទោសដោយសាលាដំបូងរាជធានីភ្នំពេញ ។ ហេតុដូចនេះ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ជាស្ថាប័នមានសមត្ថកិច្ច ក្នុងការសម្រេចប្រកាសផ្តល់ឱ្យមាននីតិសម្បទាឡើងវិញជូនលោក "ក" ។ យោងតាម ៥៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ទណ្ឌិតអាចដាក់ពាក្យសុំផ្តល់ឱ្យមាននីតិសម្បទាតាមផ្លូវតុលាការ លុះត្រាណាតែបានផុត រយៈពេលដូចតទៅ៖

- ៥ ឆ្នាំ ចំពោះ បទឧក្រិដ្ឋ
- ៣ ឆ្នាំ ចំពោះ បទមជ្ឈិម
- ១ ឆ្នាំ ចំពោះ បទលហុ ។[67]

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥៣៥ ។

ដែលរយៈពេលនេះ ចាប់ផ្តើមគិតពីការអនុវត្តទោសរួច មានន័យថាគិតចាប់ពីបានអនុវត្តទោសព្រហ្មទណ្ឌរួចរាល់ ឬចាប់ពីការអនុវត្តដោយបង្ខំពីរូបកាយរួច ។ នៅពេលដាក់ពាក្យសុំ ឬនៅពេលសវនាការ ទណ្ឌិតត្រូវជូនភស្តុតាងដែលបញ្ជាក់ថា ខ្លួនបានអនុវត្តទោសរួចរាល់ជាស្ថាពរ បានបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និង ជំងឺចិត្តរួចហើយ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី បានបោះបង់ចោលមិនទាមទារប្រាក់សំណង ឬ ជំងឺចិត្តទណ្ឌិត ត្រូវផ្តល់ការបញ្ជាក់អំពីការបោះបង់នេះ លើកលែងតែរកដើមបណ្តឹងរដ្ឋប្បវេណីមិនឃើញ ។ ចំពោះករណី ប្រសិនបើ ទណ្ឌិតត្រូវបានបង្ខំដល់រូបកាយ ការមិនបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី ឬប្រាក់សំណង និងជំងឺចិត្ត មិនមែនជាឧបសគ្គដល់ការឱ្យមាននីតិសម្បទាឡើងវិញទេ ប្រសិនបើទណ្ឌិតបង្ហាញភស្តុតាងថា ខ្លួនស្ថិតនៅក្នុងស្ថានភាពអសាធនី (អលទ្ធភាពក្នុងការអនុវត្ត ទាំងស្រុង) ។ ប្រសិនបើអ្នកប្តឹងសុំ ត្រូវបានផ្តន្ទាទោសពីបទនិទ្ធនភាព សាមីខ្លួនត្រូវជូនភស្តុតាងដែលបញ្ជាក់ថា បានទូទាត់ប្រាក់បំណុលនៃការក្ស័យធនរួចហើយ ។ ប្រសិនបើ ម្ចាស់បំណុលបានបោះបង់ចោល មិនឱ្យទូទាត់ប្រាក់បំណុលនេះទេ ទណ្ឌិតត្រូវផ្តល់ការបញ្ជាក់ពីការបោះបង់នេះ ។ ចំពោះទម្រង់នៃពាក្យសុំ ឱ្យមានការផ្តល់នីតិសម្បទាឡើងវិញ និងនីតិវិធីនៃការដាក់ពាក្យសុំ គឺទណ្ឌិតត្រូវធ្វើពាក្យសុំជូនទៅ ព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចដែនដី ។ នៅក្នុងពាក្យសុំទណ្ឌិតត្រូវចង្អុលបង្ហាញប្រភេទនៃទណ្ឌកម្មដែលខ្លួនបានរង និងបញ្ជាក់ពីទីកន្លែងដែលខ្លួនបានរស់នៅតាំងពីពេល ដែលខ្លួនត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។[68]

**ក.នីតិវិធីនៃការសម្រេចផ្តល់នីតិសម្បទាឡើងវិញ**

នីតិវិធីនៃការសម្រេចផ្តល់នីតិសម្បទាឡើងវិញត្រូវបានធ្វើឡើងដូចខាងក្រោមៈ

- *នីតិវិធីចំពោះមុខអយ្យការអមសាលាដំបូងរាជធានី-ខេត្តៈ* បន្ទាប់ពីបានទទួលពាក្យសុំ ព្រះរាជអាជ្ញាត្រូវចាត់ធ្វើការស៊ើបអង្កេតអំពីសីលធម៌នៅគ្រប់ទីកន្លែងដែលទណ្ឌិតធ្លាប់បានរស់នៅ តាំងពីពេលខ្លួនត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។ នៅក្នុងនីតិវិធីស៊ើបអង្កេតនេះ ព្រះរាជអាជ្ញាសុំឱ្យគេប្រគល់មកខ្លួននូវៈ លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោស, លិខិតជូនដំណឹងអំពីកាលបរិច្ឆេទនៃការអនុវត្តទោសរួចហើយ, ព្រឹត្តិប័ត្រលេខ១ នៃបញ្ជីថ្កោលទោស ។ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតរួច ព្រះរាជអាជ្ញាត្រូវបញ្ជូនសំណុំរឿងដោយមានយោបល់ដែលមានសំអាងហេតុរបស់ខ្លួន ភ្ជាប់ជាមួយទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។
- *នីតិវិធីនៅចំពោះមុខសាលាឧទ្ធរណ៍ៈ* បន្ទាប់ពីបានទទួលការបញ្ជូនសំណុំរឿង អគ្គព្រះរាជអាជ្ញាត្រូវធ្វើបណ្តឹងប្តឹងទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។ បន្ទាប់មក សភាពព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ត្រូវកំណត់កាលបរិច្ឆេទសវនាការ ហើយអគ្គព្រះរាជអាជ្ញា ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់អ្នកប្តឹងសុំ និងដល់

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥៣៧ ។

មេធាវី ។ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ត្រូវសម្រេចនៅពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់ទណ្ឌិត មេធាវី និងអគ្គព្រះរាជអាជ្ញា។

**២.ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់**

ក្រៅពីលក្ខខណ្ឌ នៃការដាក់ពាក្យសុំឱ្យផ្តល់នីតិសម្បទាឡើងវិញ តាមផ្លូវតុលាការទណ្ឌិតក៏អាចមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់នៅក្នុងករណីដូចតទៅ៖[69]

- នៅពេលផុតរយៈពេល ៥ឆ្នាំ គិតពីថ្ងៃអនុវត្តទោសរួចរាល់ហើយ ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ក្នុងករណីដែលបុគ្គលនោះ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារមិនលើសពី ៥ឆ្នាំទេ ឬក៏ផ្តន្ទាទោសពិន័យ ។
- នៅពេលផុតរយៈពេល ១០ឆ្នាំ គិតពីថ្ងៃអនុវត្តទោសរួចហើយ ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាលក្នុងករណីដែលបុគ្គលនោះ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារលើពី ៥ឆ្នាំ។

សរុបមក ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ គឺជាលក្ខខណ្ឌពិសេសមួយដែលមានសារៈសំខាន់ក្នុងការផ្តល់ និងស្តារនូវសិទ្ធិសេរីភាពពេញលេញតាមផ្លូវច្បាប់ដល់ទណ្ឌិត ដែលបានអនុវត្តទោសរួចស្ពាពហើយ ដើម្បីអាចទទួលបានពេញលេញនូវសមត្ថភាព និងសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួនឡើងវិញ រួមទាំងបង្កលក្ខណៈងាយស្រួលដល់ការធ្វើសមាហរណកម្មចូលទៅក្នុងសង្គមវិញរបស់ពួកគេ ៕

---

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៧០៦/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥៤១ ។

# សន្និដ្ឋាន និងអនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវរួចមក លទ្ធផលដែលទទួលបានពីប្រធានបទ"**អង្គការអយ្យការ**" ដែលបានបង្ហាញឲ្យឃើញជាក់ស្ដែងថា អង្គការអយ្យការដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងរឿងក្ដីព្រហ្មទណ្ឌ ដោយមានព្រះរាជអាជ្ញាជាតំណាងសម្រាប់អង្គការនេះ ។ ប្រាកដណាស់ តំណាងអយ្យការពិតជាមានភាពស្មុគស្មាញយ៉ាងខ្លាំង ដោយទាមទារឲ្យមានការសិក្សាស្រាវជ្រាវត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន ម៉ត់ចត់បំផុត ដើម្បីធានាបាននូវការនូវភាពយុត្តិធម៌ ជូនដល់ជនរងគ្រោះ និងសង្គមជាតិទាំងមូល ។ ការសម្រេចចោទប្រកាន់ ឬលើកលែងការចោទប្រកាន់របស់តំណាងអយ្យការ(ព្រះរាជអាជ្ញា) មានអានុភាពធំធេងណាស់ ដល់ផលប្រយោជន៍នៃភាគីបណ្ដឹង ។ ពោលគឺអាចធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិបុគ្គល ប្រសិនបើមានការសម្រេចសេចក្ដីចោទប្រកាន់ ព្រោះថា ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ គឺមានអានុភាពធ្វើឱ្យជនណាម្នាក់ ឬច្រើននាក់ ស្ថិតក្រោមការពិនិត្យអំពីបទល្មើស ដែលក្នុងស្ថានភាពនោះ នាំឱ្យបុគ្គលអ្នកប្រព្រឹត្តក្លាយខ្លួនជាជនល្មើស និងលើសពីនេះនឹងអាចឈានទៅដល់ការដកហូតសិទ្ធិសេរីភាពជាប្រជាពលរដ្ឋ ដោយមានទោស ត្រូវបង់ប្រាក់ពិន័យ និងជាប់ពន្ធនាគារទៀតផង ។ ដោយឡែកក្នុងករណីលើកលែងចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការវិញ ប្រសិនបើព្រះរាជអាជ្ញាមានការធ្វេសប្រហែស ស្រាវជ្រាវមិនបានល្អិតល្អន់ ហើយសម្រេចសេចក្ដីមិនបានត្រឹមត្រូវនោះ ជនដែលប្រព្រឹត្តអំពើល្មើសច្បាប់នឹងត្រូវបានរួចខ្លួន ដែរជាហេតុ នាំឲ្យជនល្មើសទទួលរងគ្រោះទទួលរងនូវភាពអយុត្តិធម៌ ។ ដោយសារតែហេតុផលទាំងនេះហើយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាយើងបានកំណត់នូវបទបញ្ញត្តិជាច្រើនសម្រាប់តំណាងអយ្យការ ក្នុងការអនុវត្តតាម ដើម្បីចៀសវាង និងកាត់បន្ថយការកកើតមានឡើងនូវកំហុសផ្សេងៗក្នុងការចេញសេចក្ដីសម្រេចចោទប្រកាន់ជនណាម្នាក់ ឬច្រើននាក់ ឱ្យជាប់ទោស ឬលើកលែងការចោទប្រកាន់ ។ ជាក់ស្ដែង ដូចដែលយើងបានឃើញនៅក្នុង កថាខណ្ឌទី៧ មាត្រា២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យធ្វើការស្រាវជ្រាវ បន្ថែមជាមុនសិន មុននឹងធ្វើការសម្រេចចោទ ឬមិនចោទប្រកាន់ ។ លើសពីនេះ ក្រមព្រហ្មទណ្ឌក៏បានបញ្ញត្តិ និងលក្ខខណ្ឌទម្រង់ និងមូលហេតុមួយចំនួនសម្រាប់ព្រះរាជអាជ្ញាយកទៅវិនិច្ឆ័យ និងអនុវត្តកិច្ចការរបស់ខ្លួនតាមនោះផងដែរ ។

សរុបមកវិញ តំណាងអយ្យការ(ព្រះរាជអាជ្ញា)ក្នុងនាមជាម្ចាស់បណ្ដឹងអាជ្ញា ជាអ្នកការពារផលប្រយោជន៍រួមដល់សាធារណៈ ក៏ដូចជាសង្គមជាតិទាំងមូល តំណាងអយ្យការ(ព្រះរាជអាជ្ញា)ត្រូវតែបំពេញកិច្ចការរបស់ខ្លួនដោយមានការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ខ្ពស់ ដោយអនុលោមយ៉ាងខ្ជាប់ខ្ជួនស្របតាមស្មារតី និងនីតិវិធីនៃច្បាប់ ។ លើសពីនេះ គឺត្រូវតែអនុវត្តវិជ្ជាជីវៈរបស់ខ្លួនបានត្រឹមត្រូវ សុក្រឹត្យ យុត្តិធម៌ ដោយផ្អែកលើគោលការណ៍គតិទាំងប្រាំគឺ វិរិយសម្បយុត្ត សុចរិតយុត្តិធម៌ បញ្ញត្តិគាថា សមទណ្ឌោ និងបញ្ញាវុធវិនិច្ឆ័យ ។ ព្រមទាំង កុំលុះដោយអគតិទាំងបួន ឆន្ទាគតិ ទោសាគតិ ភយាគតិ មោហាគតិ ។

# គន្ថនិទេស

## ១.ឋានានុក្រមនៃលិខិតបទដ្ឋានគតិយុត្តិ

### ក.រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ កញ្ញា ឆ្នាំ១៩៩៣ ។

### ខ.ក្រម

- ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើ ក្រមនីតិវិធីព្រហ្មទណ្ឌ ។

### គ.ច្បាប់

- ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ។
- ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, ប្រកាសឱ្យប្រើ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ។
- ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីពន្ធនាគារ ។
- ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ប្រកាសឱ្យប្រើ ច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## ២.ឯកសារជាសៀវភៅ និងវីឌីអូមេរៀន

### ក.ឯកសារជាសៀវភៅ

- "ប្រវត្តិ និងការសិក្សាប្រៀបធៀប" កុយ នាម និង ឡុង បញ្ញាវុធ, អង្គការអយ្យការ បោះពុម្ពលើកទី១ ឆ្នាំ២០០៦ ។
- នីតិវិធីព្រហ្មទណ្ឌទូទៅ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំសិក្សា២០១៩-២០២០ ។

### ខ.ឯកសារជាវីឌីអូ

- នីតិព្រហ្មទណ្ឌទូទៅ លោកសាស្ត្រាចារ្យ ជួន ប៊ុនធី ឆ្នាំសិក្សា២០១៩-២០២០ ។

## ៣.វចនានុក្រម និងសព្ទានុក្រម

### ក.វចនានុក្រម

- សម្តេចសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ, បោះផ្សាយដោយពុទ្ធសាសនាបណ្ឌិត្យ ឆ្នាំ១៩៦៧ ។

## ខ.សទ្ធានុក្រម

- សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកព្រហ្មទណ្ឌ (រៀបចំដោយគណៈកម្មាការបណ្ឌិត្យសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់) បោះពុម្ពលើកទី១ ឆ្នាំ២០១១ ។

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៛៚

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

# ដីកាបង្គាប់ឲ្យស៊ើបអង្កេតបឋម

✦✦✦✦✦

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញរបាយការណ៍លេខៈ .../១១ តពទ.បជ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ របស់សាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាលឲ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

**សម្រេច**

**១**-បង្គាប់ឲ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណី ឈ្មោះ ... ហើយឲ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

**២**-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ ... ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការ**
អមសាលាដំបូង
ខេត្តបន្ទាយមានជ័យ

## កំណត់ហេតុទទួលវត្ថុតាង

ឆ្នាំពីរពាន់ដប់បី ខែ ... ថ្ងៃទី ពីរ វេលាម៉ោង ដប់ និង សូន្យ នាទី ។
យើង ...ក្រឡាបញ្ជីនៃអយ្យការ អមសាលាដំបូងខេត្តបន្ទាយមានជ័យ ។
លោក ... ជាមន្ត្រីនគរបាលយុត្តិធម៌នៃស្នងការនគរបាលខេត្តបន្ទាយមានជ័យ
ជាអ្នកប្រគល់រួមជាមួយនិងឈ្មោះ ....ឈ្មោះ ....ឈ្មោះ ...ពីបទៈជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន

បានពិនិត្យភិនភាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ឃើញដូចខាងក្រោមៈ

១-កញ្ចប់ពណ៌សបិទជិតមានស្នាមមេដៃឈ្មោះ ....ឈ្មោះ ...និងហត្ថលេខាលោក ...លោក ...និងលោក ... ។

២-ទូរស័ព្ទចំនួន ០៦ គ្រឿង មួយគ្រឿងម៉ាក់ SAMSUNG ពណ៌ខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់NOKIA E99I ពណខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់ NOKIA X1 ពណ៌ខ្មៅ(ចិន) .មួយគ្រឿងទៀតម៉ាក់ NOKIA ចុចពិលពណ៌ផ្កាឈូកលាយពណ៌ស (ចាស់) .មួយគ្រឿងម៉ាក់ NOKIA ចុចពិលពណ៌ខ្មៅបិទស្កុតពណ៌ទឹកប្រាក់ និងមួយគ្រឿងទៀតម៉ាក់ HUAWEI ពណ៌ខ្មៅលាយពណ៌ស។

៣-កាបូបលុយចំនួនមួយពណ៌ខៀវ(គ្មានលុយ).ដែកកេះចំនួនពីរ.កាបូបស្ពាយតូចចំនួនមួយពណ៌ប្រផេះ.សំបកប្រអប់ស្រោមអនាម័យOKចំនួនមួយ.ថង់តូចពណ៌សមួយចំនួន.បំពុងទុយយចំនួនពីរ.កំរបដបទឹកចោះដាក់ទុយយមួយ។

៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួនពីរ.មួយមានលេខៈ...របស់ឈ្មោះ...និងមួយទៀតមានលេខៈ... របស់ឈ្មោះ ...។

៥-លុយខ្មែរចំនួន ៥០០០០ រៀល និងលុយដុល្លារចំនួន ១០ ដុល្លារ។

៦-ម៉ូតូមួយគ្រឿងម៉ាក់ VIVA ពណ៌ខ្មៅសេរីឆ្នាំ ២០១០ គ្មានកញ្ចក់ .គ្មានកន្រ្តក ពាក់ផ្លាក់លេខៈ ...លេខម៉ាស៊ីន ...។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង ដប់និងសែសិប នាទី នាថ្ងៃ ខែឆ្នាំដដែល ។

| អ្នកប្រគល់ | ក្រឡាបញ្ជី | ជនជាប់សង្ស័យ |
|---|---|---|

បានឃើញ
បន្ទាយមានជ័យ.ថ្ងៃទី ... ខែ ...ឆ្នាំ ២០១៣
**ព្រះរាជអាជ្ញារង**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តពោធិ៍សាត់

*សំណុំរឿង៣ហ្មទណ្ឌ*

*លេខ..........*

*ចុះថ្ងៃទី ... ខែ... ឆ្នាំ២០១៦*

## កំណត់ហេតុស្ដាប់ចម្លើយ

ឆ្នាំ ពីរពាន់ដប់ប្រាំមួយ ខែធ្នូ ថ្ងៃទីពីរ វេលាម៉ោង ដប់ និងសូន្យ នាទី។

យើង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់ អមដោយលោកជាក្រឡាបញ្ជី ។

យើងបានស្ដាប់ចម្លើយឈ្មោះ...ជាជនសង្ស័យដោយមានលោក...ជាមេធាវីការពារ។

បានមកបង្ហាញខ្លួន នៅចំពោះមុខយើង ដែលមានអត្តសញ្ញាដូចខាងក្រោម:

នាមត្រកូល ៖ ... នាមខ្លួន ៖ ...

ភេទ: ប្រុស

កើតថ្ងៃទី ៖ អាយុ ... ឆ្នាំ

ទីកន្លែងកំណើត ៖ភូមិ...ខេត្តពោធិ៍សាត់

អាសយដ្ឋាន ៖ភូមិ...ខេត្តពោធិ៍សាត់

មុខរបរ ៖ ...

សាសនា: ព្រះពុទ្ធ

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្ដី ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ... "រ" ម្ដាយឈ្មោះ ៖ ... "រ"

អនីតិជន ☐ ឬ នីតិជន ☐

ប្រវត្តិនៃការផ្ដន្ទាទោសពីមុនគ្មាន

ជននេះ ៖ ☐ ចេះនិយាយ ☐ ចេះអាន ☐ ចេះសរសេរអក្សរខ្មែរ

ជននេះ ៖ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ មិនចេះសរសេរអក្សរខ្មែរ

**សួរ-ឆ្លើយ៖** នៅថ្ងៃទី... ខែ... ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជា២១ជាង មិត្តភក្តិរបស់ខ្ញុំមានគ្នាបីនាក់ ១.ឈ្មោះ ...២.... ៣.ឈ្មោះ ... ជិះម៉ូតូ០២គ្រឿងមកបបួលខ្ញុំនៅផ្ទះ

នៅភូមិ...ខេត្តពោធិ៍សាត់ ថាទៅដុតត្រីហុប ពេលនោះខ្ញុំនិងមិត្តភក្តិរៀបចេញដំណើរ ស្រាប់តែសមត្ថកិច្ចមកដល់ ហើយបានហៅពួកខ្ញុំទាំងបួននាក់ មកអធិការដ្ឋាននគរបាលក្រុងពោធិ៍សាត់ សមត្ថកិច្ចបានឆែកឆេរក្នុងម៉ូតូ របស់ខ្ញុំ ឃើញមានក្រដាសអាលុយមីញ៉ូម ហើយទុយយូមួយដើម និងពិនិត្យទឹកនោមខ្ញុំ ឃើញមានសារធាតុញៀន ។

**សួរ.ឆ្លើយ៖** ខ្ញុំធ្លាប់ប្រើប្រាស់ថ្នាំញៀន ហើយប្រើប្រាស់លើកចុងក្រោយមុនថ្ងៃចាប់ខ្លួនពីរឬបីថ្ងៃ ប្រើម្នាក់ឯងក្នុងផ្ទះរបស់ខ្ញុំ។ថ្នាំញៀនដែលខ្ញុំប្រើប្រាស់នេះ ទិញពីឈ្មោះ ... ណាត់យកមកឲ្យនៅផ្លូវ...ខេត្តពោធិ៍សាត់ ទិញតំលៃ៣ម៉ឺនរៀល។

**សួរ.ឆ្លើយ៖** ពួកម៉ាកបីនាក់ទៀត សមត្ថកិច្ចបានឆែកឆេរអត់ឃើញមានអីពាក់ ពន្ធ័បានឲ្យទៅផ្ទះវិញ ។

**សួរ.ឆ្លើយ៖** ខ្ញុំមិនដែលរកស៊ីជួញដូរ និងចែកចាយថ្នាំញៀនទេ។

**សួរ.ឆ្លើយ៖** នៅក្នុងថ្ងៃខែមិនចាំ ក្នុងឆ្នាំ... ពេលយប់មិនចាំម៉ោង ខ្ញុំបានជិះម៉ូតូម៉ាកស៊ីរូស អត់មានផ្លាកលេខ ចេញពីផ្ទះដើម្បីទៅទិញមីនិងបារីជក់ ពេលជិះមកដល់ស្ពានដែក (ផ្លូវរថភ្លើង) តាមផ្លូវមាត់ស្ទឹង ស្រាប់តែមានរថយន្តតូចមួយគ្រឿង បានជិះមកគៀរម៉ូតូរបស់ខ្ញុំបណ្តាលឲ្យដួល ហើយឃើញគេចុះពីលើឡានរួចស្រែកឲ្យខ្ញុំឈប់ ឃើញដូច្នេះខ្ញុំក៏រត់ចោលម៉ូតូ មកដេកផ្ទះ ។

**សួរ.ឆ្លើយ៖** ពេលបាត់ម៉ូតូខ្ញុំមិនបានប្តឹងសមត្ថកិច្ចទេ ក្រោយមកលឺដំណឹងថាម៉ូតូរបស់ខ្ញុំ នៅប៉េអឹមហើយពាក់ពន្ធ័និងថ្នាំញៀន លឺដូចឆ្នេះខ្ញុំមិនហ៊ានទៅសុំម៉ូតូវិញទេ ព្រោះខ្លាចគេចោទ ថាជួញដូរថ្នាំញៀន ។

**សួរ.ឆ្លើយ៖** ពេលខ្ញុំរត់ចោលម៉ូតូ ខ្ញុំមិនមានថ្នាំញៀនទេហើយថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាន ខ្ញុំមិនដឹងថាជារបស់អ្នកណាឡើយ ។

*បញ្ចាប់កំណត់ហេតុវេលាម៉ោង ដប់ និង សែសិបប្រាំនាទី នាថ្ងៃ ខែ ឆ្នាំ ដដែល។*

យើងបានប្រាប់ជននេះឱ្យអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុង កំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ផ្តិតម្រាមដៃលើកំណត់ហេតុនេះ ។

បានអានចប់សព្វគ្រប់ ហើយជននេះមិនមានបដិសេធចំណុចណាទេ និង ចុះហត្ថលេខា ឬ ផ្តិតម្រាម ដៃជាមួយយើង ។

| | | |
|---|---|---|
| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

កំណត់ហេតុស្រុះស្រួល

ឆ្នាំពីរពាន់ដប់ពីរ ខែ មេសា ថ្ងៃទី ពីរ វេលាម៉ោង ពីរ និង ដប់ នាទី នៅអយ្យការអម សាលាដំបូងខេត្តបន្ទាយមានជ័យ។

បានធ្វើការស្រុះស្រួលរវាងដើមចោទ និងជនជាប់សង្ស័យ ដូចតទៅ:

-ភាគីដើមចោទឈ្មោះ ... ភេទ ប្រុស អាយុ ... នៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ បានប្តឹងឈ្មោះ ... ភេទ ... ឲ្យប្រគល់ដី ស្រែចំនួន កន្លះហិចតា ឲ្យមកខ្លួនវិញ។

-ជនជាប់សង្ស័យឈ្មោះ ... ភេទ ... អាយុ ... ឆ្នាំ រស់នៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ បានស្រុះស្រួលជាមួយដើមបណ្តឹងដោយយល់ព្រមប្រគល់ដីស្រែចំនួន កន្លះ ហិចតា នេះស្ថិតនៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ ឲ្យដើមបណ្តឹងឈ្មោះ ... ដើម្បីគ្រប់គ្រង និងបានយល់ព្រមសងស្រូវទៅដើមបណ្តឹងវិញចំនួន ០៦ បាវ។

ការស្រុះស្រួលគ្នានេះ ដើមបណ្តឹងឈ្មោះ ... សុខចិត្តដកពាក្យបណ្តឹងឈប់ប្តឹងពីជនជាប់សង្ស័យឈ្មោះ ... វិញហើយ។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោង ពីរ និងហាសិប នាទី នាថ្ងៃ ខែ ឆ្នាំដដែល រួច បានអានឲ្យស្តាប់ ឆ្លើយថាត្រឹមត្រូវ និងយល់ព្រមផ្តិតមេដៃ និងចុះហត្ថលេខាទុកចំណាំ។

ដើមបណ្តឹង ជនជាប់សង្ស័យ

បានឃើញ

ថ្ងៃទី ខែ ... ឆ្នាំ ២០១២

ព្រះរាជអាជ្ញា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូង ខេត្តពោធិ៍សាត់**

*សំណុំរឿងព្រហ្មទណ្ឌលេខ ...*

*ចុះថ្ងៃទី ... ខែ ... ឆ្នាំ...*

**ដីកាកោះ**

*យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់*

*បង្គាប់មកឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ ជាសាក្សី ។*

*ទីលំនៅបច្ចុប្បន្ននៅភូមិ...ខេត្តពោធិ៍សាត់ ។*

*ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់*

*នៅវេលាម៉ោង២០០រសៀល ថ្ងៃទី ... ខែ... ឆ្នាំ... ។*

*ដើម្បី* ***សួរយកចម្លើយ***

*ពីដំណើររឿង* ***បង្ក្រាបបទល្មើសព្រៃឈើ កាលពីថ្ងៃទី ... ខែ... ឆ្នាំ ... នៅ ចំណុច...ភូមិ...ខេត្តពោធិ៍សាត់។***

*សាម៉ី*

*ខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿង ខាងលើ មកជាមួយផងប្រសិនបើមាន។*

*ធ្វើនៅពោធិ៍សាត់, ថ្ងៃទី ... ខែ ... ឆ្នាំ ...*

**ព្រះរាជអាជ្ញារង**

យើង..........................................................................បានប្រគល់ដីកាកោះនេះដល់

ឈ្មោះ.....................................ទីលំនៅបច្ចុប្បន្ននៅភូមិ.................... ឃុំ/សង្កាត់ ............................................ ស្រុក/ខណ្ឌ...............ខេត្ត/ក្រុង..........................នៅថ្ងៃទី .........ខែ..................ឆ្នាំ....................................ហើយយើងបានប្រាប់ថា ឱ្យយកចុង ដីកានេះទៅ ប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះ មុខសាលាដំបូងខេត្តពោធិ៍សាត់។

**អ្នកទទួល** **អ្នកប្រគល់**

**ហត្ថលេខា ឬ ស្នាមមេដៃ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**៣៧**

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

# ដីកាផ្ទេរសមត្ថកិច្ច

**\+\+\+\+\+**

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាលឱ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

**សម្រេច**

**១**-បង្គាប់ឱ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណីឈ្មោះ ... ហើយឱ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

**២**-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ មករា ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

អយ្យការអម

*សាលាដំបូងខេត្ត*

**បន្ទាយមានជ័យ**

**********

លេខ: អក.បជ

# ដីកាបញ្ជាស្វែងរកចាប់ខ្លួន

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត **បន្ទាយមានជ័យ**

បានឃើញ: មាត្រា ៥១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រ កម ០៨ ០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញ:របាយការណ៍លេខ: ... ព.គ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១២ ស្តីពីទណ្ឌិតឈ្មោះ ... ភេទប្រុស អាយុ ... ឆ្នាំ ពុំមានឃុំខ្លួននៅក្នុងពន្ធនាគារ (រត់គេចខ្លួន)។

## យល់ឃើញថា:

-ទណ្ឌិតឈ្មោះ ...ភេទប្រុស អាយុ... ឆ្នាំ ជាប់ចោទពីបទ: ជួញដូរគ្រឿងញៀនខុស ច្បាប់ ហើយត្រូវបានសាលាដំបូងខេត្តបន្ទាយមានជ័យ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០០៣ ។

-តាមរបាយការណ៍របស់ពន្ធនាគារបានបញ្ជាក់ថា: ទណ្ឌិតរូបនេះមិនបានជាប់ឃុំនៅក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យ (រត់គេចខ្លួន) ។

-តាមកំណត់ហេតុស្តីពីការចុះត្រួតពិនិត្យពន្ធនាគារ ចុះថ្ងៃទី... ខែ...ឆ្នាំ២០១១ បញ្ជាក់ថា ទណ្ឌិតឈ្មោះ ...នៅព្យាបាលជម្ងឺនៅប្រទេសវៀតណាម តែពុំមានកំលាំងពន្ធនាគារការពារ នោះទេ ។

-តាមមាត្រា ៥១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់ថា: ក្នុងករណីដែលអ្នកទោសរត់ចេញពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួននោះ ព្រះរាជអាជ្ញាចេញបញ្ជាស្វែងរកចាប់ខ្លួន និងចាត់វិធានការជាបន្ទាន់ដើម្បីអនុវត្តបញ្ជាស្វែងរកចាប់ខ្លួន ។

## ហេតុដូច្នេះសម្រេច

-បង្គាប់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ និងកងកំលាំងសាធារណៈស្រាវជ្រាវរកចាប់ខ្លួន និងនាំខ្លួនទណ្ឌិតខាងលើនេះទៅក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យ ក្នុងរយៈពេលយ៉ាងខ្លីបំផុតដើម្បីធ្វើការឃុំខ្លួន ។

បន្ទាយមានជ័យ ថ្ងៃទី ខែ... ឆ្នាំ២០១២

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តពោធិ៍សាត់**

លេខ......................អយ/១៧

**លិខិតអញ្ជើញ**

**យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត**

អញ្ជើញ លោក ... ភេទប្រុស ជានាយកមន្ទី... ។

ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

នៅវេលាម៉ោង ២.០០ រសៀល ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៧ ។

ដើម្បី បំភ្លឺ ពីដំណើររឿង **បង្ក្រាបបទល្មើសព្រៃឈើ កាលពីថ្ងៃទី... ខែ... ឆ្នាំ ២០១៦ នៅចំណុច... ភូមិ... ឃុំ... ស្រុក... ខេត្តពោធិ៍សាត់ ។**

សាមីខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿង ខាងលើ មកជាមួយផងប្រសិនបើមាន។

ធ្វើនៅពោធិ៍សាត់, ថ្ងៃទី ... ខែ ....ឆ្នាំ ២០១៧

**ព្រះរាជអាជ្ញារង**

យើង......................................................................បានប្រគល់ដីកាអញ្ជើញនេះដល់

ឈ្មោះ...................................ទីលំនៅបច្ចុប្បន្ននៅភូមិ.................... ឃុំ/សង្កាត់ .......................................... ស្រុក/ខណ្ឌ................ខេត្ត/ក្រុង..........................នៅថ្ងៃទី .........ខែ..................ឆ្នាំ.....................................ហើយយើងបានប្រាប់ថា ឱ្យយកចុងដីកានេះទៅ ប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះ មុខសាលាដំបូងខេត្តពោធិ៍សាត់។

**អ្នកទទួល** **អ្នកប្រគល់**

**ហត្ថលេខា ឬ ស្នាមមេដៃ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការ អម

សាលាដំបូងខេត្ត ពោធិ៍សាត់

លេខ.................

# លិខិតជូនដំណឹង

យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

សូមជូនដំណឹងលោក ... អាយុ ... ឆ្នាំ មានទីលំនៅ ភូមិ.... ឃុំ... ស្រុក... ខេត្តបាត់ដំបង អោយបានជ្រាបថា:

ពាក្យបណ្តឹងរបស់លោក ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៣ ដែលបាន ប្តឹងលោក ... អាយុ...ឆ្នាំមានទីលំនៅភូមិ... ឃុំ... ស្រុក... ខេត្តកំពង់ឆ្នាំង ថា: **បានបង្កគ្រោះថ្នាក់ចរាចរណ៍** ប្រព្រឹត្តនៅភូមិ... ឃុំ... ស្រុក... ខេត្តពោធិ៍សាត់ ដែលមានសំណុំរឿងព្រហ្មទណ្ឌ លេខ:... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៣ នោះត្រូវបានតំណាងអយ្យការតម្កល់រឿងទុកឥតចាត់ការ តាមដីការតម្កល់រឿងទុកឥតចាត់ការ លេខ:... អយ/១៦ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ហើយ សូមលោកជ្រាប។

លោកមានសិទ្ធិប្តឹងតវ៉ារយៈពេលពីរខែគិតចាប់ពីថ្ងៃលោកបានទទួលដំណឹងនេះ។

ពោធិ៍សាត់, ថ្ងៃទី... ខែ... ឆ្នាំ ២០១៦

**តំណាងអយ្យការ**

អង្គហេតុនេះជាបទល្មើស: ***រំលោភលំនៅដ្ឋាន*** តាមមាត្រា ២៩៩ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ... សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី... ខែ ... ឆ្នាំ ២០១៤។

-យើងបានទទួលចម្លើយសារភាពអំពីជនជាប់ចោទឈ្មោះ ... ថា: ពីថ្ងៃទី... ខែ... ឆ្នាំ ២០១៤ ឪពុកម្តាយរបស់ខ្លួនឈ្លោះប្រកែកគ្នា ខ្លួនធុញពេកក៏បានចូលទៅផ្ទះរបស់គេនៅម្តុំបេន

ឡានដោយយកដែកគាស់ជញ្ជាំងហើយលូនចូលទៅក្នុង បន្ទាប់មកខ្លួនបានរុញទូររបស់គេទៅកៀនដើម្បីយកកន្លែងដេកបណ្តាលឲ្យទូរបែកកញ្ចក់ ពេលនោះម្ចាស់គេមកដល់ក៏ចាប់ខ្លួនឲ្យសមត្ថកិច្ចតែម្តង។

យើងបានប្រាប់ដល់ជននេះថា: ខ្លួនមានសិទ្ធពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ខ្លួន រឺ ស្នើសុំឲ្យ មានការចាត់តាំងមេធាវី ដោយអនុឡោមតាមបញ្ញត្តិច្បាប់ ។

ជននេះបានឆ្លើយថា:

☐ខ្ញុំជ្រើសរើសលោក-លោកស្រីមេធាវី.........................................................។

☐ ខ្ញុំសូមស្នើសុំឲ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ ។

☐ ខ្ញុំមិនត្រូវការមេធាវីទេនៅពេលនេះ ។

យើងបានបញ្ជាក់ថា:

☐ លោក-លោកស្រីមេធាវី ................................................អាចពិនិត្យសំណុំរឿង នឹងទាក់ជា មួយជនត្រូវចោទ

☐ យោងលើសំណើសុំ ឲ្យមានការចាត់តាំងមេធាវី ស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី គំណាងគណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។

☐លោក-លោកស្រីមេធាវី...........................................................អវត្តមាន ។

បានឃើញមាត្រា ៤៧ , ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**យល់ឃើញថា:** បទល្មើសជាបទល្មើសមជ្ឈិមជាក់ស្តែង

**យល់ឃើញថា:** ជនជាប់ចោទជានីតិជន ។

**យល់ឃើញថា:** រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

សម្រេច

-បញ្ជូនជនជាប់ចោទឈ្មោះ ... ភេទ ប្រុស អាយុ ... ឆ្នាំ ទៅតុលាការដើម្បីជំនុំជម្រះពីបទ: ***រំលោភលំនៅដ្ឋាន*** តាមមាត្រា ២៩៩ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ... សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី... ខែ ... ឆ្នាំ ២០១៤

តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះអង្គហេតុ និង បទល្មើសខាងលើ ។

ក្រោយពីបានអាន ជនជាប់ចោទបានផ្តិមមេដៃ ជាមួយយើង ។

ជនជាប់ចោទ　　　　　　　　　　តំណាងអយ្យការ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ........................

# ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង ............តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ:...................ចុះថ្ងៃទី........ខែ.........ឆ្នាំ២០១....
.របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា។

**១- អវត្តមានបទល្មើស**

☐ ១.១. អវត្តមានបទល្មើស

**២- ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់**

☐ ២.១. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

**៣- មូលហេតុគតិយុត្ត**

☐ ៣.១. ការដកពាក្យបណ្ដឹង

☐ ៣.២. ការលើកលែងទោសជាទូទៅ

☐ ៣.៣. មរណភាពជនល្មើស

☐ ៣.៤. ផុតអាជ្ញាយុកាល

☐ ៣.៥. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

☐ ៣.៦. អាជ្ញាអស់ជំនុំ

☐ ៣.៧. ការសម្របសម្រួលជាមួយរដ្ឋ

☐ ៣.៨. ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល

☐ ៣.៩. អភ័យឯកសិទ្ធ

☐ ៣.១០. អនិយ័តភាពនៃនីតិវិធី

☐ ៣.១១. ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

**៤- ការចោទប្រកាន់មិនផ្តល់ប្រយោជន៍**

☐ ៤.១. ការស្វែងរកមិនបានផល

☐ ៤.២. ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

☐ ៤.៣ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

☐ ៤-៤ ការខកខានរបស់ដើមបណ្តឹង

☐ ៤.៥. អាកប្បកិរិយារបស់ជនរងគ្រោះ

☐ ៤.៦. ជនរងគ្រោះមិនចាប់អារម្មណ៍ នឹងបទល្មើស

☐ ៤.៧. និយ័តកម្មដោយឯកឯង[3]

☐ ៤.៨. ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

**៥- នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា**

☐ ៥.១. ការជួសជុលការខូចខាតដោយ/ដល់អនីតិជន

☐ ៥.២. សន្ធានកម្ម[4]

☐ ៥.៣. អចិបញ្ជាផ្តល់ការព្យាបាល

☐ ៥.៤. ជនរងគ្រោះ/ដើមបណ្តឹងបោះបង់បណ្តឹង តាមការស្នើសុំរបស់ព្រះរាជអាជ្ញា

☐ ៥.៥. និយ័តកម្មតាមសំណើររបស់ព្រះរាជអាជ្ញា

☐ ៥.៦. ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[5]

☐ ៥.៧. ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាព នៃសង្គម ឬវិជ្ជាជីវៈ

☐ ៥.៨. ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

**៦- នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗ**

---

[1] ) ដូចជាមូលហេតុ វិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[2] ) ដើមបណ្តឹងឈប់ប្តឹង

[3] ) សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និង ស្តារស្ថានភាពឡើងវិញ

[4] ) ករណីចែងដោយច្បាប់

[5] ) ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើស តាមកំណត់ច្បាប់ និងធ្វើការព្រមានឲ្យឈប់ប្រព្រឹត្ត

[6] ) ករណីចែងដោយច្បាប់

☐ ៦.១. ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

**៧-ជនល្មើសមិនត្រូវបានស្គាល់**

☐ ៧.១. ជនល្មើសមិនត្រូវបានស្គាល់

**៨-ជំនួយការអប់រំ**

☐ ៨.១. ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ការអង្កេតផ្សេងៗ ៖**កាលពីថ្ងៃទី...........................................................................................

..........................................................................................................................................

..............................................................................................................................

**បានឃើញ:**

-កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងឈ្មោះ

-កំណត់ហេតុស្តាប់ចម្លើយជនសង្ស័យឈ្មោះ ។

-ពាក្យស្នើសុំដកបណ្តឹងរបស់ឈ្មោះ ចុះថ្ងៃទី ............ខែ ............ ឆ្នាំ ............។

**យល់ឃើញថា:**

-តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ

**ហេតុដូច្នេះ សម្រេច**

-តម្កល់រឿងព្រហ្មទណ្ឌលេខ ............ ថ្ងៃទី ..... ខែ ............ ឆ្នាំ ............ ទុកឥតចាត់ការតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី... ខែ....... ឆ្នាំ........

**ព្រះរាជអាជ្ញារង**

អយ្យការអម

សាលាដំបូងខេត្ត

*ពោធិ៍សាត់*

*លេខ៖*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

យើង ............ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០ ។

បានឃើញមាត្រា ៤៣ និង ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជ ក្រមលេខ: នស/រ កម ០៨ ០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា ៖**

១-នាមត្រកូលនាមខ្លួន ៖ ភេទ សញ្ជាតិ ៖ ខ្មែរ

កើតថ្ងៃទីខែឆ្នាំ ៖

ទីកន្លែងកំណើត ៖ភូមិ ឃុំ ស្រុក ខេត្ត

អាស័យដ្ឋានសព្វថ្ងៃ:ភូមិ ឃុំ ស្រុក ខេត្ត

មុខរបរ ៖ ប្តីឬប្រពន្ធឈ្មោះ ៖ កសិករ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖ "រ"

អនីតិជន ☐ ឬ ☐ នីតិជន

**ឃើញថា:**

កាលពីថ្ងៃទី ខែ ឆ្នាំ ២០១៤

ពីបទ: ដែលល្មើសមាត្រា នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

-ឯកសារនានាទាក់ទងសំណុំរឿង លេខ: ចុះថ្ងៃទី ខែ ឆ្នាំ ២០១៤ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ

-តាមរបាយការលេខ:

**យល់ឃើញថា:**

-

-អង្គហេតុខាងលើ មានលក្ខណៈមូលសព្វគ្រប់ និងភស្តុតាងដែលប្រមូលបានអាចកំណត់អំពីធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ហេតុ ដូច្នេះគប្បីសម្រេចបញ្ជូនសំណុំរឿងនេះដោយផ្ទាល់ទៅសាលាដំបូង ខេត្ត បន្ទាយមានជ័យ ដើម្បីជំនុំជម្រះតាមច្បាប់ជាធរមាន។

**ហេតុដូច្នេះសម្រេច ៖**

**បញ្ជូនជនជាប់ចោទ** ឈ្មោះ ភេទ អាយុ ឆ្នាំ ពីបទៈ ដែលល្មើសមាត្រា ប្រព្រឹត្តនៅភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ខែ ឆ្នាំ ២០១៤។**ទៅសាលាដំបូងខេត្ត បន្ទាយមានជ័យ ដើម្បីជំនុំជម្រះ តាមនីតិវិធីកោះហៅបញ្ជូនទៅជំនុំជំម្រះផ្ទាល់ ចំពោះអង្គហេតុខាងលើ ។**

បន្ទាយមានជ័យ ថ្ងៃទី ខែ ឆ្នាំ ២០១

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្ត
*ពោធិ៍សាត់*
*លេខ៖..........*

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង ........... តំណាងអយ្យការអម សាលាដំបូងខេត្ត ពោធិ៍សាត់
បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១...
បានឃើញរបាយការណ៍របស់អធិការដ្ឋាននគរបាលស្រុកក្រគរ លេខ: ...
ចុះថ្ងៃទី... ខែ... ឆ្នាំ២០១... ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា មានតម្រុយសន្មតបានថា:**

១-នាមត្រកូល ៖ ... នាមខ្លួន ...........ហៅគា ភេទ...
អាយុ ៖ ....ឆ្នាំ
ទីកន្លែងកំណើត៖ ............................................................................
អាសយដ្ឋាន ៖ ................................................................................
មុខរបរ ៖ ...
☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ..............
សញ្ជាតិ ៖ ខ្មែរ
ឪពុកឈ្មោះ ៖........... "ស" ម្តាយឈ្មោះ ៖ ........... "ស"
អនីតិជន ☐ ឬ នីតិជន ☐

២-នាមត្រកូល ៖........... នាមខ្លួន ........... ភេទ...........
អាយុ ៖ ...........ឆ្នាំ
ទីកន្លែងកំណើត៖ ............................................................................
អាសយដ្ឋាន៖ ...........................................................................
មុខរបរ ៖ ...........
☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ...........

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ........... "ស" ម្ដាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

៣-នាមត្រកូល ៖ ........... នាមខ្លួន ........... ភេទ...........

អាយុ ៖ ...........ឆ្នាំ

ទីកន្លែងកំណើត៖ .........................................................................

អាសយដ្ឋាន ៖ .........................................................................

មុខរបរ ៖ ...........

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ...........

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ........... "ស" ម្ដាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

## បានប្រព្រឹត្តអំពើដូចតទៅ ៖

កាលពីថ្ងៃទី........... ខែ...........ឆ្នាំ........... វេលាម៉ោង...........និង...........នាទី មានបទល្មើស........... ........... ...........នៅតំបន់........... ........... ស្ថិតនៅភូមិ...........ឃុំ...........ស្រុក........... ខេត្តពោធិ៍សាត់ បង្កឡើងដោយជនសង្ស័យចំនួន០៧នាក់ ១.ឈ្មោះ...........ភេទ........... អាយុ ...........ឆ្នាំ ជា...........២.ឈ្មោះ ........... ភេទ........... ហៅ........... ភេទ........... អាយុ ...........ឆ្នាំ ៣.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ ៤. ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៥.ឈ្មោះ ........... ភេទ........... អាយុ...........ឆ្នាំ ៦.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៧.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ។ ពេលទទួលបានបណ្ដឹងពីប្រជាពលរដ្ឋ លោកអធិការបានបញ្ជាឲ្យលោកអធិការរងទទួលផែនការយុត្តិធម៌ ដឹកនាំផ្នែកជំនាញ ដោយសហការជាមួយប៉ុស្តិ៍........... ចុះទៅកន្លែងកើតហេតុដើម្បីធ្វើការស្រាវជ្រាវ បន្ទាប់ពីទៅដល់កន្លែងកើតហេតុលោកអធិការរងទទួលផែនការយុត្តិធម៌ ដឹកនាំផ្នែកជំនាញ និងប៉ុស្តិ៍........... ធ្វើការស្រាវជ្រាវកំណត់មុខសញ្ញា ។លុះដល់ថ្ងៃទី........... ខែ........... ឆ្នាំ........... កំលាំងអធិការដ្ឋាននគរបាលស្រុក........... ធ្វើការឃាត់ខ្លួន ១.ឈ្មោះ........... ភេទ........... អាយុ ...........

ឆ្នាំ ជាប្រធានអង្គការ............ ២.ឈ្មោះ ............ភេទ............ ហៅ............ភេទ............ អាយុ ............ឆ្នាំ ៣.ឈ្មោះ ............ ភេទ............ អាយុ............ឆ្នាំ ៤.ឈ្មោះ ............ ភេទ ............ អាយុ ............ឆ្នាំ ៥.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ ៦.ឈ្មោះ ............ ភេទ............ អាយុ ............ឆ្នាំ ៧.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ ០៦នាក់ជាសមាជិក............។

អំពើខាងលើជាបទល្មើសៈ កំហែងយក តាមមាត្រា ៣៦៣,៣៦៤ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅ............ ស្ថិតនៅភូមិ............ឃុំ............ស្រុក............ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី............ខែ............ ឆ្នាំ............។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**សម្រេច ៖**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង:

1.ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើ ៖

ក. ឈ្មោះ ............ហៅ............ អាយុ ............ឆ្នាំ

ខ.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

គ.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

ឃ.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

ង.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

ច.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

ឆ.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

ពីបទៈ កំហែងយក តាមមាត្រា ៣៦៣,៣៦៤ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅ ........................ ស្ថិតនៅភូមិ........... ............ ............ ............ ............ .............កាលពីថ្ងៃទី ............ ខែ............ ឆ្នាំ............។

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ធ្វើនៅពោធិ៍សាត់,ថ្ងៃទី........ ខែ ........ ឆ្នាំ ............

**តំណាងអយ្យការ**

អយ្យការអម
សាលាដំបូងខេត្ត
*ពោធិ៍សាត់*
*លេខ៖*

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបទល្មើសថ្មីបន្ថែម

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ។

-បានឃើញនីតិវិធីស៊ើបសួរលើឈ្មោះ ... ឈ្មោះ... និង ឈ្មោះ...ជាជនត្រូវចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ និង នៅខណ្ឌ... ក្រុង ... កាលពីថ្ងៃទី... ខែ ... ឆ្នាំ ២០១៦។

**ឃើញថាអង្គហេតុ:** តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ... បានឆ្លើយសារភាពថា ៖ កាលពីអំឡុង ខែ... ឆ្នាំ២០១៥ខ្លួនធ្លាប់បានទៅទិញថ្នាំញៀនពីឈ្មោះ ... ហៅ ... ចំនួនពាក់កណ្តាលកន្លះជ្រុង តម្លៃ១២០០០០០រៀល(មួយលានពីរសែនរៀល) ហើយឈ្មោះ...យកថ្នាំមកចនៅភូមិរលាប សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុង ខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនកន្លះហ៊ុន នៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុងខែ... ឆ្នាំ២០១៥ខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ... ចំនួនមួយហ៊ុន ហើយឈ្មោះ...យកថ្នាំមកចនៅភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់។ នៅចុងខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនមួយជ្រុង តម្លៃ៧០០ដុល្លា (ប្រាំពីររយ) ទិញនៅភូមិ... សង្កាត់.... ក្រុង... ខេត្តពោធិ៍សាត់។

☐ ដែលត្រូវបានចៅក្រមស៊ើបសួររកឃើញ ហើយបានជូនដំណឹងតាមលិខិតលេខ... ចុះថ្ងៃទី ... ខែ... ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ។

-បានឃើញលិខិតជូនដំណឹងលេខ... ចុះថ្ងៃទី ...ខែ... ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរ ស្តីពីលេចចេញនូវអង្គហេតុថ្មី។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា មានតម្រុយសន្និដ្ឋានថា:**

**១**-នាមត្រកូល ៖... នាមខ្លួន ៖ ហៅ ... ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ ភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

**២**-នាមត្រកូល ៖ ... នាមខ្លួន ៖ ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ ភូមិ

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

**៣**-នាមត្រកូល ៖ ... នាមខ្លួន ៖ ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ សង្កាត់... ក្រុង.... ខេត្តពោធិ៍សាត់

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

៤-នាមត្រកូល ៖ ... នាមខ្លួន ៖ ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ ភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

## បានប្រព្រឹត្តអំពើដូចតទៅ ៖

តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ.... បានឆ្លើយសារភាពថា ៖ កាលពីអំឡុង ខែ... ឆ្នាំ២០១៥ខ្លួនធ្លាប់បានទៅទិញថ្នាំញៀនពីឈ្មោះ... ហៅ ... ចំនួនពាក់កណ្តាលកន្លះជ្រុង តម្លៃ១២០០០០០រៀល(មួយលានពីរសែនរៀល) ហើយឈ្មោះ...យកថ្នាំមកឲនៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុង ខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនកន្លះហ៊ុន នៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុងខែ... ឆ្នាំ២០១៥ខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ... ចំនួនមួយហ៊ុន ហើយឈ្មោះ...យកថ្នាំមកឲនៅភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់។ នៅចុងខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនមួយជ្រុង តម្លៃ៧០០ដុល្លា (ប្រាំពីររយ) ទិញនៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់។

- អំពើខាងលើជាបទល្មើស៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅ ក្រុង... ខេត្តពោធិ៍សាត់ កាលពីអំឡុង ខែ... ខែ... ខែ... ខែ.... ឆ្នាំ ២០១៥។

**យល់ឃើញថា**

-តាមចម្លើយសារភាពរបស់ជនត្រូវចោទឈ្មោះ.... ឃើញថា លេចចេញនូវអង្គហេតុថ្មី ហើយអង្គហេតុថ្មីនេះតំណាងអយ្យការមិនទាន់បានបើកការស៊ើបសួរនៅឡើយ។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**សម្រេច ៖**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង:

☐ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើ ៖

១-ឈ្មោះ ... ហៅ...ភេទ ប្រុស

ពីបទ ៖ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្ត កាលពីអំឡុង ខែ... ឆ្នាំ២០១៥ នៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។

២-ឈ្មោះ ... ភេទ ប្រុស

ពីបទ ៖ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅអំឡុង ខែ... ឆ្នាំ២០១៥ នៅភូមិ... សង្កាត់... ក្រុង ... ខេត្តពោធិ៍សាត់ ។

៣-ឈ្មោះ ... ភេទ ប្រុស

ពីបទ ៖ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តកាលពីអំឡុងខែ... ឆ្នាំ២០១៥ នៅភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន ៖ ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការ ចាត់ការតាមនីតិវិធី។

ធ្វើនៅ,ពោធិ៍សាត់ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៦

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្ត*ពោធិ៍សាត់*
*លេខ៖*

## ដីកាស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម

យើង ... តំណាងអយ្យការអមសាលាដំបូងខេត្ត ពោធិ៍សាត់។

-បានឃើញមាត្រា ២៤៦ និង ១៣២នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសអោយប្រើ

-តាមព្រះរាជក្រមលេខ នស. រកម . ០៨០៧.០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១៥។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ ២០១៥។

**ដែលបានបើកការស៊ើបសួរលើ:**

១-ឈ្មោះ ... ភេទ ប្រុស អាយុ...ឆ្នាំ

២-អញ្ញាតជន

ពីបទ៖ អំពើលួច ,ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៣៥៣ ,៣៥៦នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា៤៥ ,៤០នៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ។

ប្រព្រឹត្តិនៅសង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី... ,ទី...ខែ.... ឆ្នាំ២០១៥។

**បានឃើញ** ៖ដីកាបញ្ជូនអោយឆ្លើយដើម្បីបិទបញ្ចប់ការស៊ើបសួរលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ។

## យល់ឃើញថា:

-ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរលេខ ... ចុះថ្ងៃទី...ខែ..។ ឆ្នាំ២០១៥ បានបើកការស៊ើបសួរលើ អញ្ញាតជន ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិ... សង្កាត់...ក្រុង... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី... ខែ... ឆ្នាំ០១៥។

- ចៅក្រមស៊ើបសួរពុំទាន់បានបំពេញកិច្ចស៊ើបសួរ រកសាវតាជាតិរបស់អញ្ញាតជននៅឡើយ

## ហេតុដូច្នេះសម្រេច

១-ស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរបន្ថែម ៖

-បំពេញកិច្ចស៊ើបសួររកសាវតាជាតិរបស់ជនត្រូវចោទ (អញ្ញាតជន) ទៅតាមនីតិវិធី

២-បញ្ជូនសំណុំរឿងលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ ២០១៥ ទៅចៅក្រមស៊ើបសួរដើម្បីបំពេញកិច្ចស៊ើបសួរបន្ថែម។

ធ្វើនៅពោធិ៍សាត់ ថ្ងៃទី ខែ ... ឆ្នាំ ២០១៦

**តំណាងអយ្យការ**

អយ្យការ អម

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌ

លេខ:

# ដីកាសន្និដ្ឋានសុំដល់ចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរ

យើង ...តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ:...ចុះថ្ងៃទី...ខែ ...ឆ្នាំ ២០១២របស់ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ មាត្រា១៣៧ មាត្រា១៣៨ និង មាត្រា ១៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណា ចក្រកម្ពុជា។

-បានឃើញ ដីកាសម្រេចលេខ៖...ព.ស/ព្រ.ទ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១២របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ លើពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

## ក្រោយពីបានពិនិត្យឯកសារខាងលើ:

០១-នាមត្រកូល និងនាមខ្លួន: ...
ភេទប្រុស អាយុ ...ឆ្នាំ សញ្ជាតិ...
ទីកន្លែងកំណើត: ខេត្ត...
ទីលំនៅបច្ចុប្បន្ន: ភូមិ...ខេត្តបន្ទាយមានជ័យ
មុខរបរ: នៅផ្ទះ (ចាស់ជរា) សាសនា ព្រះពុទ្ធ
ប្រពន្ធឈ្មោះ ... (ស្លាប់)
ឪពុកឈ្មោះ ... (ស) ម្តាយឈ្មោះ ... (ស)
នីតិជន ☑ ឬអនីតិជន □

០២-នាមត្រកូល និងនាមខ្លួន: ...
ភេទប្រុស កើតថ្ងៃទី ... ខែ... ឆ្នាំ ... សញ្ជាតិខ្មែរ
ទីកន្លែងកំណើត: ភូមិ...ខេត្តស្វាយរៀង
ទីលំនៅបច្ចុប្បន្ន: ភូមិ... ខេត្តបន្ទាយមានជ័យ
មុខរបរ: ...សាសនា ព្រះពុទ្ធ
ប្រពន្ធឈ្មោះ ...

ឪពុកឈ្មោះ ... (ស) ម្តាយឈ្មោះ ... (រ)
នីតិជន ☑ ឬអនីតិជន □

**ការសង្កេតផ្សេងៗ៖**

កាលពីថ្ងៃទី ...ឈ្មោះ ...ហៅ ...ភេទប្រុស បានមកដាក់ពាក្យប្តឹងនៅ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដោយប្តឹងឈ្មោះ ...ថា៖ បានធ្វើ និង ប្រើប្រាស់នូវឯកសារក្លែងក្លាយលើពាក្យស្នើ សុំដីស្រែ ចុះថ្ងៃទី...ខែ... ឆ្នាំ១...ដើម្បីយកមកធ្វើជាឯកសារយោងសំរាប់ចេញប័ណ្ណសំគាល់សិទ្ធកាន់កាប់ អចលនវត្ថុហើយ នៅក្នុងនោះមានឈ្មោះ ...ជាមេឃុំ... បានចូលរួមបញ្ជាក់ និងប្រព្រឹត្តអំពើក្លែងឯកសារនេះ ផងដែរ។ លុះថ្ងៃទី... ខែ... ឆ្នាំ... ឈ្មោះ ...ហៅ ...បានមកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹង
រដ្ឋប្បវេណីតាមផ្លូវអន្តរាគន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៖... ចុះថ្ងៃទី... ខែ ... ឆ្នាំ... មក ចៅក្រមស៊ើបសួរ ។

**យល់ឃើញថា:**

-ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី
តាមផ្លូវអន្តរាគមន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ៖
... ចុះថ្ងៃទី...ខែ...ឆ្នាំ២... របស់ឈ្មោះ ...ហៅ ...បានប្តឹងមកចៅក្រមស៊ើបសួរហើយតាមរយៈដីកាសម្រេចលើ
ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ៖... ចុះថ្ងៃទី... ខែ...ឆ្នាំ... របស់ចៅក្រមស៊ើបសួរបានបញ្ជូនមក
អយ្យការដើម្បីអោយតំណាងអយ្យការធ្វើការពិនិត្យនិងសម្រេច។
បន្ទាប់ពីតំណាងអយ្យការទទួលបានពាក្យ បណ្តឹងសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ...ហៅ......តាមដីកាបញ្ជូនលេខ៖ ...រប/សលដ.បជ ចុះថ្ងៃទី ... ខែ... ឆ្នាំ ... របស់សាលាដំបូងខេត្តបន្ទាយមានជ័យ និងក្រោយពីបានអង្កេតបឋមរួចរាល់តំណាងអយ្យការបានសម្រេចតម្កល់រឿងទុកឥតចាត់ការលើសំណុំរឿងព្រហ្មទណ្ឌ លេខ ៖ ... ចុះថ្ងៃទី ... ខែ ...ឆ្នាំ ... របស់ អយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ដោយមូលហេតុផុតអាជ្ញាយុកាលនៃបទល្មើសតាមដីកា លេខ៖... ចុះថ្ងៃទី... ខែ ...ឆ្នាំ...របស់អយ្យការអមសាលាដំបូងខេត្ត បន្ទាយមានជ័យ។

-តាមមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) វាក្យខ័ណ្ឌ៣ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជ អាជ្ញា អាចសុំ ដល់ ចៅក្រមស៊ើបសួរ កុំអោយស៊ើបសួរ លើពាក្យបណ្តឹងសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ...ហៅ ...ដោយហេតុថា៖ នៅក្នុងពាក្យបណ្តឹងរបស់ឈ្មោះ...បានប្តឹង ពីឈ្មោះ...និង ឈ្មោះ.. ថាបានក្លែងដោយសិកសៀតអក្សរលើពាក្យ ស្នើ សុំ ដីស្រែ របស់ ឈ្មោះ...ចុះថ្ងៃ ទី... ខែ ... ឆ្នាំ ...

ដែលពាក្យស្នើសុំនេះកើតមានឡើងតាំងពី ឆ្នាំ..... មកម្ល៉េះ ដោយយោងតាមមាត្រា ៦១០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌបានចែងថា៖ ″អាជ្ញាយុកាលនៃ បណ្តឹង អាជ្ញា និង អាជ្ញាយុកាលនៃទោស ចំពោះបទល្មើស ដែលត្រូវបានប្រព្រឹត្ត នៅមុនក្រម នេះចូលជា ធរមាន ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ចាស់″ ហេតុនេះ អាជ្ញាយុកាលនៃបទល្មើសត្រូវអនុវត្តតាមច្បាប់ព្រហ្មទណ្ឌអន្តរកាល។ តាមមាត្រា៣០នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាលបានចែងថា″ អាជ្ញាយុកាលសំរាប់បទមជ្ឈឹមមានរយៈពេល០៣ឆ្នាំ រីឯអាជ្ញាយុកាលសំរាប់បទ ឧក្រិដ្ឋមានរយៈពេល១០ឆ្នាំ″ ដូចនេះនាំអោយផុតអាជ្ញាយុកាលនៃបទល្មើស ព្រោះថា បើគិតរយៈពេល ពីឆ្នាំ១៩៩៥មកដល់ថ្ងៃដែល ឈ្មោះ ...ហៅ ... បានដាក់ពាក្យប្តឹងគឺមានរយៈពេល១៦ឆ្នាំហើយ (ប្រសិនបើមើលទៅមាត្រា ១០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌវិញ ចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា១៥ ឆ្នាំចំពោះបទឧក្រិដ្ឋ ចំណែកឯ បទមជ្ឈិម រយៈ ពេល ៥ឆ្នាំ ដូចនេះបើតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ អាជ្ញាយុកាលនៃបទល្មើសក៏បានផុតហើយដែរ)កន្លងមក ឈ្មោះ ... ហៅ ... ពុំបានប្តឹងតវ៉ាអំពីការក្លែងលិខិតនេះដែរ ហេតុនេះ ថេរវេលា នៃ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាបានផុតហើយ គប្បីរំលត់បណ្តឹងអាជ្ញា (តាមមាត្រា ៧នៃ ក្រ.ន.ព្រ)។

## ហេតុដូច្នេះសម្រេច

-ស្នើសុំដល់ចៅក្រមស៊ើបសួរ
កុំអោយស៊ើបសួរលើពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមផ្លូវអន្តរាគមន៍ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១២ របស់ឈ្មោះ...ហៅ...ដែលបាន ចុះនៅក្នុង សំណុំរឿងព្រហ្មទណ្ឌ លេខ ៖ ...ចុះថ្ងៃទី ... ខែ ...ឆ្នាំ ២... របស់អយ្យការអមសាលាដំបូងខេត្ត - បន្ទាយមាន ជ័យ ដោយ មូលហេតុនៃការផុតរំលត់អាជ្ញាយុកាលនៃបទល្មើស។

ធ្វើនៅ បន្ទាយមានជ័យ, ថ្ងៃទី ខែ ...ឆ្នាំ ...

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តពោធិ៍សាត់**
**សំណុំរឿងព្រហ្មទណ្ឌលេខ: ...**
**ចុះថ្ងៃទី...ខែ... ឆ្នាំ..**
**លេខ:......................អ.យ/០១៦**

**ដីកាសន្និដ្ឋានស្ថាពរ**

**យើង........... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ។**

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់តំណាងអយ្យការអមសាលាដំបូងពោធិ៍សាត់ ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ:... ចុះថ្ងៃទី ... ខែ... ឆ្នាំ... របស់សាលាដំបូងខេត្តពោធិ៍សាត់ ។

បានឃើញ ដីកាបញ្ជូនឲ្យឆ្លើយដើម្បីបិទបញ្ចប់ការស៊ើបសួរលេខ: ... ពស ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

ឃើញថា:

១-នាមត្រកូល៖...នាមខ្លួន ... ហៅ... ភេទ... កើតនៅឆ្នាំ ...
-សញ្ជាតិ៖... សាសនា ៖ មុខរបរ៖... ទោសពីមុនគ្មាន
-ទីកន្លែងកំណើត៖ ភូមិ... ខេត្តពោធិ៍សាត់
-ទីលំនៅបច្ចុប្បន្ន៖ ភូមិ...ខេត្តពោធិ៍សាត់
-ឪពុកឈ្មោះ ... (រ) ម្តាយឈ្មោះ ... (រ) នៅលីវ ជានីតិជន។
២-នាមត្រកូល៖... នាមខ្លួន ... ភេទប្រុស កើតនៅឆ្នាំ ...
-សញ្ជាតិ៖... សាសនាព្រះពុទ្ធ ៖ មុខរបរ៖ធ្វើស្រែ ទោសពីមុនគ្មាន
-ទីកន្លែងកំណើត៖ ភូមិ...ខេត្តពោធិ៍សាត់
-ទីលំនៅបច្ចុប្បន្ន៖ ភូមិ...ខេត្តពោធិ៍សាត់
-ឪពុកឈ្មោះ ... (រ) ម្តាយឈ្មោះ ... (រ) នៅលីវ ជានីតិជន។
៣-នាមត្រកូល៖... នាមខ្លួន ... ភេទប្រុស កើតនៅឆ្នាំ ...
-សញ្ជាតិ៖ សាសនា៖

-ទីកន្លែងកំណើត៖ ភូមិ...ខេត្តពោធិ៍សាត់

-ទីលំនៅបច្ចុប្បន្ន៖ ភូមិ...ខេត្តពោធិ៍សាត់

-ឪពុកឈ្មោះ៖ ... (រ) ម្តាយឈ្មោះ៖... (ស) ប្រពន្ធឈ្មោះ ... (រ)

កាលពីថ្ងៃទី...ខែ...ឆ្នាំ...វេលាម៉ោង...នាទីរសៀល មានអំពើ...របស់ជនរងគ្រោះឈ្មោះ...ដែលបានចងទុកនៅក្រោមផ្ទះនៅភូមិ...ខេត្តពោធិ៍សាត់។ ដល់ថ្ងៃខែឆ្នាំដដែល វេលាម៉ោងប្រហែល...និង...នាទី ឈ្មោះ...ហៅ... និងឈ្មោះ...បានហៅឈ្មោះ ...ឲ្យយកឡានមកដឹកក្របី ពេលកំពុងរៀបចំយកក្របីនោះដាក់ឡាន ពេលនោះឈ្មោះ...បានឃើញក៏រាយការណ៍ប្រាប់សមត្ថកិច្ច រួចសម្តកិច្ចក៏ចុះដេញតាមឡានដឹកក្របីដល់ភូមិ ...ខេត្តពោធិ៍សាត់ បានតាមទាន់ហើយ ក៏ឃាត់ខ្លួនឈ្មោះ ...ហៅ... និងឈ្មោះ... ជាអ្នកបើកឡានដឹកក្របី។

បានឃើញ ឈ្មោះ ...ត្រូវបានឃុំខ្លួនបណ្តោះអាសន្នតាមដីកាលេខៈ ...ចុះថ្ងៃទី...ខែ... ឆ្នាំ...របស់ចៅក្រមស៊ើបសួរ។ (ឯកសារលេខៈ ...)

បានឃើញ ឈ្មោះ ...ត្រូវបានឃុំខ្លួនបណ្តោះអាសន្នតាមដីកាលេខៈ ... ចុះថ្ងៃទី...ខែ...ឆ្នាំ... របស់ចៅក្រមស៊ើបសួរ។ (ឯកសារលេខៈ...)

បានឃើញ កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ... ថាខ្លួនមិនបានកត់កំណត់ហេតុថា ក្របីខ្លួនបានពេលណា រកឃើញពេលណាទេ គ្រាន់តែនគរបាល ហៅឲ្យយកក្របី។ ក្របីនោះខ្លួនទាក់បង្កន់ក្របី(ក្រោល) ព្រឹកឡើងលែងចោលដោយដើរមើល។ ក្របីខ្លួនមានចំនួន ០៤ក្បាល ពេលព្រឹកឡើងឃើញបាត់មួយនៅសល់ ០៣ក្បាល។ ការបាត់នោះដោយដឹកខ្សែដើរចេញតែមួយ។ក្របីនោះរកឃើញវិញហើយ ខ្លួនមិនទាមទារសំណងទេ សុំធ្វើតាមច្បាប់។ ខ្លួនមិនថាអ្នកណាចូលលួចទេ ហើយក៏គ្មានសង្ស័យអ្នកណាទេ ពេលដែលសមត្ថកិច្ចចាប់បានក្របី និងមនុស្ស គឺមនុស្សនោះដែលមិនមែនជាអ្នកភូមិខ្លួនទេ ដែលអ្នកនោះមិនស្គាល់ខ្លួន ហើយខ្លួនមិនស្គាល់គាត់ ដែលមើលទៅមិនមែនជាអ្នកលួចដឹកពីផ្ទះខ្លួនទេ ព្រោះគេមិនដែលឃើញ និងស្គាល់ផ្ទះខ្លួនទេ។ តាមខ្លួនគិតគឺមានអ្នកជិតភូមិខ្លួនជាអ្នកដឹកដើរចេញពីក្រោយរបស់ខ្លួន ចំណែកអ្នកដែលសមត្ថកិច្ចចាប់ខ្លួននេះមិនដឹងថាទំនាក់ទំនងជាមួយអ្នកនៅជិតៗខ្លួនយ៉ាងណាទេ។ សំណូមពរសុំផ្តន្ទាទោសតាមច្បាប់។

បានឃើញ កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់សាក្សី ឈ្មោះ...ខ្លួនធ្លាប់ស្គាល់ឈ្មោះ... រយៈពេល...ឆ្នាំហើយ។ តាំងពីស្គាល់គាត់ ឃើញគាត់ប្រកបមុខរបរជាអ្នកទិញ

គោក្របី។ កន្លងមកឈ្មោះ......ធ្លាប់ទិញក្របីយកមកផ្ញើនៅផ្ទះខ្លួនម្តង ហើយក្របីនោះបាន រួចពីចំណង ហើយដេញចាប់ភ្លាមៗ មិនមានបាត់ទេ ក៏ឡើងឡានបាត់ទៅ។ក្រោយមក ប្រហែល២អាទិត្យវេលាម៉ោង ប្រហែល ១០ ទៅ ១១ ថ្ងៃត្រង់ ឈ្មោះ...បានចូលលេងផ្ទះខ្លួន ហើយក៏បាននិយាយថាឈ្មោះ... នៅ...បានហៅឲ្យទៅទិញក្របី ដោយឈ្មោះ... នៅ... គាត់ទិញបានក្របីមួយ ហើយហៅឈ្មោះ...ទៅមើល និងទិញបន្ត។ ពេលនោះឈ្មោះ... ទៅបាត់មួយ ប្រហែលម៉ោង ... រសៀលក៏ឈ្មោះ...ទូរស័ព្ទប្រាប់ថានគរបាលបានចាប់។ខ្លួន ធ្លាប់ស្គាល់ឈ្មោះ...នៅ...នោះដែរ ធ្លាប់ទៅលេងកន្លែងខ្ទមស្រែរបស់ឈ្មោះ... នៅកន្លែង ស្រែតែមិនស្គាល់នោះទេ។ ឈ្មោះ... នោះខ្លួនធ្លាប់ជួបមុខចំនួន២ ដងហើយ ស្គាល់មុខ ច្បាស់។ កន្លងមកឈ្មោះ...ជាអ្នកទិញពីណាពីណីមកហើយទើបលក់ឲ្យឈ្មោះ...។កាលពី ថ្ងៃដែលគេចាប់ខ្លួននោះ គឺឈ្មោះ...បានប្រាប់ខ្លួនថា មានលុយចំនួន ៨.០០០.០០០ (ប្រាំលានរៀល) ហើយដើររកក្របី នៅភូមិខ្លួនផង និងកន្លែងផ្សេងៗ។ពេលនគរបាលចាប់ នោះខ្លួនទៅមើលឈ្មោះ...បានប្រាប់ថាលុយបានឲ្យទៅឈ្មោះ ... នៅ...អស់ហើយ។ កន្លង មកការរាប់អានគ្នា ខ្លួនធ្លាប់បានដើរលេង ជាមួយឈ្មោះ...ពេលគេទិញក្របីដែរ ដោយ ឃើញមានលិខិតស្នាមត្រឹមត្រូវ តែចំពោះថ្ងៃដែលគេចាប់ខ្លួននេះមិនដឹងថាមានសំបុត្រអត់ នោះទេ។ ក្របីនោះខ្លួនជឿជាក់ថាឈ្មោះ... ទិញពីឈ្មោះ...នៅ...ចំពោះការចាប់ខ្លួន ឈ្មោះ...ខ្លួននិងសហការ។

បានឃើញ កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ឈ្មោះ...ហៅ... ខ្លួនជាអ្នក ប្រកបមុខរបរលក់ទិញគោក្របីអស់ រយៈពេល ៣-៤ ឆ្នាំហើយ។កាលពីថ្ងៃទី មិនចាំខែ ធ្នូ ឆ្នាំ២០១៥វេលាម៉ោង ១០ព្រឹក ឈ្មោះ... អ្នករកស៊ីទិញគោ ក្របី បានដឹកខ្ញុំដោយម៉ូតូគាត់ ដើម្បីទៅមើលក្របីនៅកំរែង។ ពេលនោះខ្លួនមិនបានសួរអំពីដំណើរទំនងអំពីក្របីនោះ ឡើយដោយខ្លួននិងឈ្មោះ...ធ្លាប់រកស៊ីជាមួយ ហើយកន្លងមកឈ្មោះ...ជាអ្នកផ្ញើ។ ខ្លួនបាន ព្រមព្រៀងជាមួយឈ្មោះ... ក្នុងតម្លៃ៣.០០០.០០០(បីលានរៀល)។ ខ្លួនមិនបានផ្ចិតមេដៃពី ឈ្មោះ... ឡើយ។ ឈ្មោះ... មានផ្ទះនៅផ្ទុំភូមិ...ខេត្តពោធិ៍សាត់ ដែលខ្លួនកូនប្រុសគាត់ម្នាក់ ឈ្មោះ...(កំលោះ)នៅម្តុំផ្លូវកោង ទូរស័ព្ទលេខ ០៩៧...។ពេលនោះនគរបានលបានចាប់ខ្លួន បានប្រាប់នគរបាលតាមដំណើររឿង ហើយនគរបាលបានយក ទូរស័ព្ទខ្លួនទៅទាក់ទង ឈ្មោះ... ហើយឈ្មោះ... បាននិយាយជាមួយនគរបាលថាគាត់ធានា ឲ្យខ្លួនទៅទៅតែ ដោយគ្មានសំបុត្រនគរបាលមិនឲ្យទៅទេ។ការទិញនេះឈ្មោះ... បានឲ្យសំបុត្រដែលទិញ

ក្របីពីគេនោះមកខ្លួនកាន់ដែរ តែពេលជិះតាមផ្លូវជ្រុះបាត់ ដោយខ្លួនដាក់ជាមួយទូរស័ព្ទក្នុងហោប៉ៅ។ ក្រោយពីបិទទូរស័ព្ទ ដែលទាក់ទងគ្នាម្តងរួចហើយ ទាក់ទងគ្នាលែងចូលរហូត។ ចំណែកអ្នកស៊ីឈ្នួលដឹកគាត់បានទារថ្លៃ១០.០០០០(ដបម៉ឺនរៀល) ហើយគាត់សួរខ្លួនថាមានសំបុត្រទេ ខ្លួនប្រាប់ថាមាន ព្រោះសំបុត្រនោះខ្លួនមានមែនខ្លួនទទួលពីឈ្មោះ... មកខ្លួនមិនបានមើលទេខ្លួនបានដាក់ជាមួយទូរស័ព្ទក្នុងហោប៉ៅ ហើយបាត់ទៅ។

បានឃើញ កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ឈ្មោះ...ពេលនោះខ្លួនបានសួរអំពីដមណើរទំនងអំពីក្របីនោះ គាត់ថាមានច្បាប់ត្រឹមត្រូវអស់ហើយ។ក្រោយពីតថ្លៃដប់ម៉ឺនរៀល ខ្លួនក៏ចេញទៅ ពេលទៅដល់ឃើញគាត់ មានគ្នា២នាក់ ហើយបន្ទាប់ពីឡើងក្របីរួចខ្លួនក៏សួររកក្រដាសស្នាម គាត់ថាមាន ហើយគាត់ទាញឲ្យខ្លួនមើលដោយមិនចេះអក្សរ ឃើញគាត់ដកឯកសារមកជាច្រើនខ្លួនក៏ជឿទៅ ដោយមិនបានដឹងថាក្រដាសនោះ ពីថ្ងៃណានោះទេ។ ពេលដឹកប្រហែលបាន ៣ គីឡូម៉ែត ខ្លួនឃើញនគរបាលបានជិះម៉ូតូតាមក្រោយ ហើយស៊ីផ្លេខ្លួនឃើញតាមកញ្ចក់ខ្លួនក៏ឈប់ ហើយគាត់ទារមើលឯកសារ (គឺឈ្មោះ...កំពុងជិះម៉ូតូជាមួយខ្លួនក៏បានបង្ហាញឯកសារ) មិនដឹងថាឯកសារនោះយ៉ាងណាទេ ក៏គេឲ្យមកប៉ុស្តិ៍នគរបាលទាំងអស់គ្នា។ ពេលនគរបាលសួរខ្លួនឆ្លើយតាមដំណើររឿងដូចឆ្លើយនៅពេលនេះដែល ចំណែកចម្លើយឈ្មោះ... នោះយ៉ាងណាខ្លួនមិនដឹងទេ។ ខ្លួនមិនបានដឹងថាក្របីនោះ ខុសច្បាប់នោះទេ បើខ្លួនដឹងថាខុសច្បាប់ខ្លួនក៏មិនដឹកឡើយ ឈ្មោះ... អះអាងថាមានសំបុត្រ(ច្បាប់)។

យល់ឃើញថា

- មានភស្តុតាងគ្រប់គ្រាន់លើឈ្មោះ ...ភេទប្រុស អាយុ ...ឆ្នាំ និងឈ្មោះ...ភេទប្រុស អាយុ ...ឆ្នាំ ពីបទៈ អំពើលួច ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី... ...ខែ... ឆ្នាំ២...បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាម បញ្ញត្តិមាត្រា ៣៥៣,៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-មិនមានភស្តុតាងគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ ...ភេទប្រុស អាយុ ...ឆ្នាំ

ពីបទៈសមគំនិតក្នុងអំពើលួច តាមមាត្រា ២៩,៣៥៣,៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ... ខែ... ឆ្នាំ២...

<u>ដូច្នេះសម្រេច</u>

I. ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចៈ

១.បញ្ជូនជនត្រូវចោទលើ ៖

ក-ឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ

ខ-ឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ

ពីបទ: អំពើលួច តាមមាត្រា៣៥៣,៣៥៦ ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី...ខែ... ឆ្នាំ២... ទៅ ជំនុំ ជម្រះ។

២.លើកលែងជនត្រូវចោទះ

- ឈ្មោះ...ភេទប្រុស អាយុ ... ឆ្នាំ

ពីបទះ សមគំនិតក្នុងអំពើលួច តាមមាត្រា២៩,៣៥៣,៣៥៦នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ...ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ... ខែ... ឆ្នាំ២...។

ធ្វើនៅអយ្យការ, ថ្ងៃទី.........ខែ........... ឆ្នាំ២...

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

លេខ:...........................................

**********

## ដីកាសម្រេចឱ្យយកជនជាប់ចោទមកជំនុំជំរះ

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី ...ខែ ... ឆ្នាំ ២០១២ ដែលមានជនជាប់ចោទ:

១-ឈ្មោះ ... ភេទ ប្រុស អាយុ ... ឆ្នាំ (ក្នុងឃុំ)
២-ឈ្មោះ ... ភេទ ប្រុស អាយុ ... ឆ្នាំ (ក្នុងឃុំ)
៣-ឈ្មោះ ... ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

ជាប់ចោទពីបទ**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិគីឡូម៉ែត្រលេខ...សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី... ខែ... ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤៥** និងមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។

### ហេតុដូច្នេះសម្រេច

**ឱ្យជនជាប់ចោទ**

១-ឈ្មោះ .... ភេទប្រុស អាយុ ... ឆ្នាំ
២-ឈ្មោះ .... ភេទប្រុស អាយុ ... ឆ្នាំ

ទៅកាន់សាលាដំបូងខេត្តបន្ទាយមានជ័យ ទីកន្លែងជំនុំជម្រះសាលាដំបូងខេត្ត **នៅថ្ងៃទី... ខែ... ឆ្នាំ២០១២ វេលាម៉ោង ៨. ០០ នាទី ព្រឹក** ដើម្បីជំនុំជម្រះពីបទដែលបានចែងដូចខាងលើ ។

**ចៅក្រមជំនុំជំរះ**

- លោក ... ចៅក្រមសាលាដំបូងខេត្ត

**តំណាងអយ្យការ**

- លោក ... ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

- លោក .... ក្រឡាបញ្ជី

ឱ្យដំណឹងដល់ជនជាប់ចោទស្តីពីសិទ្ធិរបស់ខ្លួន
នៅចំពោះមុខតុលាការដូចតទៅ:
- សិទ្ធិពីការដឹងឮពីដីកាសន្និដ្ឋានស្ថាពរ និងដីកាកោះឱ្យចូលរួមសវនាការ
- សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬសំណូមពរផ្សេងៗ
- សិទ្ធិប្តឹងជំទាស់ចិត្តចៅក្រមជំនុំជម្រះ

- សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់មេធាវីជួយការពារ

បន្ទាយមានជ័យ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០១២

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្ត បន្ទាយមានជ័យ**
**លេខ:**

**តំណាងអយ្យការអមសាលាដំបូងខេត្ត បន្ទាយមានជ័យ**

**<u>សូមគោរពជូន</u>**

**ឯកឧត្តមអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍**

**<u>កម្មវត្ថុ:</u>** របាយការណ៍បណ្ដឹង ឧទ្ធរណ៍ នឹងដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នលេខ: ... ចុះថ្ងៃទី ...

ខែ ... ឆ្នាំ ២០១៤។

**<u>យោង:</u>** -សំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១៤ ។

-ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤ ។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជំរាបជូន ឯកឧត្តម មេត្តាជ្រាបថា: លោកចៅក្រម ស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចមិនឃុំខ្លួនជនត្រូចចោទឈ្មោះ ... ដែលដាក់ ឲ្យស្ថិតនៅក្រោមការពិនិត្យ ពីបទ:អំពើហិង្សាដោយចេតនា(ស្ថានទម្ងន់ទោស) តាមដីកាសំរេចលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤ តំណាងអយ្យការមិនយល់ស្របដោយសំអាងថា:

-តាមចម្លើយរបស់ដើមបណ្ដឹងឈ្មោះ ... និងចម្លើយសាក្សីឈ្មោះ ... .ឈ្មោះ... ឈ្មោះ ... .ឈ្មោះ ... .ឈ្មោះ ... មានភាពស៊ីសង្វាក់គ្នាបញ្ជាក់ថា:កាលពីថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤ នៅចំណុចភូមិ... សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ មានការទាស់គ្នា រវាងក្រុមជនរងគ្រោះ និងក្រុមជនត្រូវចោទ ឈ្មោះ ... មានការវាយ និងកាប់ចាក់គ្នា ដោយពេលទាស់គ្នានោះជនត្រូវចោទឈ្មោះ ... បានយកកាំបិត ចាក់ទៅលើជនរងគ្រោះឈ្មោះ ... ហើយជនរងគ្រោះឈ្មោះ ... បានយកដៃរងបណ្ដាលឲ្យមុតដៃតែម្ដង មិនមែនជនរងគ្រោះដួលទៅប៉ះ កាំបិទដែលជនត្រូវចោទកាន់ បណ្ដាលឲ្យរបួស ដូចចម្លើយរបស់ជនត្រូវ ចោទឆ្លើយដោះសារនោះទេ ។

-ការប្រព្រឹត្តរបស់ជនត្រូវចោទមានបក្សពួកជាក្រុម និងមានអាវុធ បណ្តាលឲ្យប៉ះពាល់ដល់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងព្យសនៈកម្មធ្ងន់ធ្ងរ។

-ជនត្រូវចោទជាកម្មករ មានទីលំនៅមិនច្បាស់លាស់ ការសម្រេចមិនឃុំខ្លួន ជនត្រូវចោទនិង មិនចូលមកបង្ហាញខ្លួនទៅតាមនីតិវិធីឡើយ ។

-ជនត្រូវចោទជាកម្មករ មានបក្សពួកច្រើន ជាក្រុមទំនើងការមិនឃុំខ្លួន ជនត្រូវចោទអាចនិងទៅបង្កបទល្មើសជាថ្មីទៀត។

-ជនត្រូវចោទប្រព្រឹត្តបទល្មើសមានគ្នាច្រើន ការអោយជនត្រូវចោទនៅក្រៅឃុំអាចត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនត្រូវចោទ ធ្វើឲ្យបាត់ភស្តុតាង និងអាចជនត្រូវចោទទៅគាបសង្កត់លើសាក្សី ឬជនរងគ្រោះធ្វើឲ្យមានការលំបាកដល់ការស៊ើប អង្កេតប្រមូលភស្តុតាង។

-ដោយផ្អែកលើមូលហេតុទាំងអស់នេះ ទើបតំណាងអយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ប្តឹងឧទ្ធរណ៍និងដីកាសម្រេចមិនឃុំខ្លួនលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤។

សេចក្តីដូចបានជំរាបជូនខាងលើសូមឯកឧត្តម **អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍** មេត្តាជ្រាបជារបាយការណ៍ ។

សូម ឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅ បន្ទាយមានជ័យ , ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

លេខ:............................................ **ដីកាកោះឱ្យចូលរួមសវនាការ**

**********

យេង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានជនជាប់ចោទ:

១-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

២-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

ជាប់ចោទពីបទ **បើកបរបង្កឲ្យគ្រោះថ្នាក់ស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិ... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី...ខែ... ឆ្នាំ... បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៨១.៨២** នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

**ហេតុដូច្នេះសម្រេច**

បង្គាប់ឱ្យឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំជាតិខ្មែរ ទីលំនៅបច្ចុប្បន្នរស់នៅភូមិ...ខេត្តបន្ទាយមានជ័យ ឱ្យចូលទៅកាន់សាលាដំបូងខេត្តបន្ទាយមានជ័យ **នៅថ្ងៃទី... ខែ... ឆ្នាំ...វេលាម៉ោង ២ᵸ០០** រសៀល ជាកំហិត ដើម្បីឆ្លើយដោះសាពីការចោទប្រកាន់មកលើខ្លួនដូចខាងលើ ។

**ចៅក្រមជំនុំជម្រះ**

- លោក ...ចៅក្រមសាលាដំបូងខេត្ត

**តំណាងអយ្យការ**

- លោក ... ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

- លោក ...ក្រឡាបញ្ជី

**សិទ្ធិរបស់ជនជាប់ចោទមានដូចតទៅ:**

- សិទ្ធិពីការដឹងឮពីលិខិតចោទប្រកាន់ទោស និងដីកាកោះឱ្យចូលរួមសវនាការ
- សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬសំណូមពរផ្សេងៗ

- សិទ្ធិប្តឹងជិតចិត្តទៅក្រមជំនុំជម្រះ
- សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់មេធាវីជួយការពារ

បន្ទាយមានជ័យ, ថ្ងៃទី ... ខែ ... ឆ្នាំ ...

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

លេខ:.............................................

**********

## <u>ដីកាកោះឱ្យចូលរួមសវនាការ</u>

យើង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានជនជាប់ចោទ:

១-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

២-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

ជាប់ចោទពីបទ **បើកបរបង្កឲ្យគ្រោះថ្នាក់ស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិ... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី...ខែ... ឆ្នាំ... បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៨១.៨២** នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

### <u>ហេតុដូច្នេះសម្រេច</u>

បង្គាប់ឱ្យឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំជាតិខ្មែរ ទីលំនៅបច្ចុប្បន្នរស់នៅភូមិ...ខេត្តបន្ទាយមានជ័យ ឱ្យចូលទៅកាន់សាលាដំបូងខេត្តបន្ទាយមានជ័យ **នៅថ្ងៃទី... ខែ... ឆ្នាំ...វេលាម៉ោង** ២^h00 រសៀល ជាកំហិត ដើម្បីឆ្លើយដោះសាពីការចោទប្រកាន់មកលើខ្លួនដូចខាងលើ ។

<u>ចៅក្រមជំនុំជម្រះ</u>

- លោក ...ចៅក្រមសាលាដំបូងខេត្ត

<u>**តំណាងអយ្យការ**</u>

- លោក ... ព្រះរាជអាជ្ញារង

<u>ក្រឡាបញ្ជីសវនាការ</u>

- លោក ...ក្រឡាបញ្ជី

**សិទ្ធិរបស់ជនជាប់ចោទមានដូចតទៅ:**

- សិទ្ធិពីការដឹងឮពីលិខិតចោទប្រកាន់ទោស និងដីកាកោះឱ្យចូលរួមសវនាការ

- សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬសំណូមពរផ្សេងៗ
- សិទ្ធិប្តឹងជិតចិត្តទៅក្រមជំនុំជម្រះ
- សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់មេធាវីជួយការពារ

បន្ទាយមានជ័យ, ថ្ងៃទី ... ខែ ... ឆ្នាំ ...

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការ**
អមសាលាដំបូង
ខេត្តបន្ទាយមានជ័យ
លេខ:            អក

## ដីកាឲ្យដំណឹងពីសេចក្តីសម្រេចរបស់តុលាការ

យើង ... ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១០ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ ... (គ) ចុះថ្ងៃទី... ខែ... ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។

បានឃើញមាត្រា ៤៨២ និងមាត្រា ៤៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**<u>ជូនដំណឹងមក</u>**

ឈ្មោះ ... ភេទប្រុស ឆ្នាំកំណើត ... (អាយុ ... ឆ្នាំ) សញ្ជាតិ ខ្មែរ មានទីលំនៅ ភូមិ... សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ ជាជនជាប់ចោទឲ្យបានជ្រាប ថាៈ រឿងក្តីរបស់លោក ត្រូវបានសាលាដំបូងខេត្តបន្ទាយមានជ័យធ្វើការជំនុំជម្រះ និងសម្រេចសេចក្តីរួចហើយ តាមរយៈសាលក្រម ដូចបានយោងខាងលើ និងភ្ជាប់ជាមួយស្រាប់ ។

អាស្រ័យហេតុនេះសូមលោកជ្រាបបើលោកមិនសុខចិត្តនឹងការសម្រេចសេចក្តីតាមសាលក្រមខាងលើនេះទេលោកមានសិទ្ធិប្តឹងទាស់និង សាលក្រមខាងលើនេះបានក្នុងរយៈពេល **១៥ថ្ងៃ** ដោយគិតចាប់ពីថ្ងៃ បានទទួលដីកាឲ្យដំណឹង នេះតទៅនិងមានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល **០១ខែ** គិតចាប់ពីថ្ងៃផុតកំណត់ នៃការប្តឹងទាស់។

ជូនភ្ជាប់មកជាមួយនូវសាលក្រមព្រហ្មទណ្ឌលេខៈ ... (គ) ចុះថ្ងៃទី... ខែ... ឆ្នាំ២០១១ របស់ សាលាដំបូងខេត្តបន្ទាយមានជ័យ ។

បន្ទាយមានជ័យ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤

**ព្រះរាជអាជ្ញារង**

យើង.................................................ជា.................................................................

បានប្រគល់ដីកាឲ្យដំណឹងនេះដល់ឈ្មោះ.........................ទីលំនៅសព្វថ្ងៃភូមិ.............................

ឃុំ/សង្កាត់.............................ស្រុក/ខណ្ឌ...........................ខេត្ត/ក្រុង..........................

នៅថ្ងៃទី.............ខែ...................ឆ្នាំ២០.......... រួចហើយ ។

| | |
|---|---|
| **អ្នកទទួល** | **អ្នកប្រគល់** |
| **ហត្ថលេខា ឬ ផ្តិតមេដៃ** | **ហត្ថលេខា** |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៙

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

## ដីកាដោះលែងទណ្ឌិត

+++

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញមាត្រា ៤៩៦.៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ ... (ត) ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១២ នៃសាលាដំបូងខេត្ត បន្ទាយមានជ័យ។

**<u>យើងចេញដីកាដោះលែងឈ្មោះដូចខាងក្រោម</u>**

-នាមត្រកូល-នាមខ្លួនៈ ...ជាតិ ខ្មែរ សាសនា

-កើតថ្ងៃទី ខែ ឆ្នាំ (អាយុ ៣៦ ឆ្នាំ) ភេទ ប្រុស

-ស្រុកកំណើតភូមិ...ខេត្តបាត់ដំបង

-ទីលំនៅមុនពេលជាប់ទោសភូមិ...ខេត្តបន្ទាយមានជ័យ

-ជាប់ពីបទ **អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ**

-ត្រូវបានវិនិច្ឆ័យទោសចំនួន ០២ឆ្នាំ ដោយអនុវត្តទោសក្នុងពន្ធនាគារកំណត់ ០១ ឆ្នាំ គិត ចាប់ពីថ្ងៃទី ... ខែ ... ឆ្នាំ ...។

បច្ចុប្បន្នទណ្ឌិតរូបនេះ បានអនុវត្តទោសគ្រប់ចំនួនអស់ហើយ ។

ឈ្មោះ ...នេះត្រូវវិលត្រឡប់ទៅរស់នៅមូលដ្ឋាន ដើម្បីប្រកបការងារចិញ្ចឹមជីវិតជាមួយគ្រួសារវិញ។

លោកប្រធានពន្ធនាគារខេត្តបន្ទាយមានជ័យ មានភារកិច្ចអនុវត្តតាមដីកានេះប្រសិនបើទណ្ឌិតរូបនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ មករា ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

យើង……………………………………......ប្រធានមន្ទីរឃុំឃាំងខេត្តបន្ទាយមានជ័យបាន
ដោះលែងឈ្មោះ……………………………ភេទ………………អាយុ……………ឆ្នាំលេខខ្លួន
………………………ចុះថ្ងៃទី                    ខែ…………… ឆ្នាំ ……………ប្រព្រឹត្តបទល្មើស
……………………………………………………នៅចំណុចភូមិ ……………………ឃុំ……………
ស្រុក……………………………ខេត្ត បន្ទាយមានជ័យ កាលពីថ្ងៃទី ………ខែ ………………
ឆ្នាំ…………តាមអំណាចដីកានេះថ្ងៃទី……ខែ…………ឆ្នាំ…………រួចហើយ។

បន្ទាយមានជ័យ ថ្ងៃទី ………ខែ……… ឆ្នាំ………

ប្រធានមន្ទីរឃុំឃាំង